# អភិធម្មត្ថសង្គហៈ

# បរិច្ឆេទទី ៨

*វត្តនិគ្រោធវ័ន "គល់ទទឹង"*

*រៀបរៀងដោយ* **ភិក្ខុ អគ្គធីរោ គង់ សុមិត្ត**

*ព.ស. ២៥៥៥*

# សម្ដែងព្រះអភិធម្ម នៅឋានតាវត្តិង្ស

កាលព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ចាំព្រះវស្សាទី៧ នៅឋានតាវត្តិង្សទេវលោក ក្នុងគ្រាដែលបានសំដែងយមកបាដិហារ្យផ្ចាញ់ពួកតិរ្ថិយរួចហើយ បានគង់លើសិលាសនៈ ឈ្មោះបណ្ឌុកម្ពល ក្រោមដើមបារិឆត្ត ទ្រង់ព្រះសិរីសោភា ដូចព្រះអាទិត្យឧទ័យឡើងលើភ្នំយុគន្ធរ ដែលពួកនៃទេវតាទាំងឡាយក្នុងម៉ឺនចក្រវាឡបានមកប្រជុំគ្នា ហែហមសម្ដេចព្រះបរមសាស្ដាចារ្យ ទ្រង់ធ្វើសន្តុសិតទេវបុត្រដែលធ្លាប់ជាពុទ្ធមាតា ឱ្យជាប្រធាននៃពួកទេវតាទាំងឡាយ ហើយត្រាស់កថាមគ្គព្រះអភិធម្មថា "**កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា**"ជាដើម ទ្រង់សម្ដែងដោយន័យនេះ ជាប់តរហូតអស់មួយព្រះវស្សា ដោយតេជៈនៃព្រះសព្វញ្ញុតញ្ញាណនោះ ។ ក៏កាលដែលទ្រង់សម្ដែងធម៌នោះ ក្នុងវេលាភិក្ខាចារទ្រង់និម្មិតព្រះពុទ្ធនិមិត្តដោយទ្រង់អធិដ្ឋានថា "ព្រះពុទ្ធនិមិត្តនេះ ចូរ

សម្ដែងធម៌ ឈ្មោះប៉ុណ្ណោះ ដរាបដល់តថាគតមក" ហើយក៏ស្ដេចយាងទៅព្រៃហេមពាន្ត ទ្រង់ទំពាឈើស្ទន់ ឈ្មោះនាគលតា ខ្ពុរព្រះឱស្ឋក្នុងស្រះអនោតត្ត នាំបិណ្ឌបាតអំពីឧត្តរកុរុទ្វីប បានធ្វើភត្តកិច្ចក្នុងរោងធំទូលាយហើយ ។ ព្រះសារីបុត្រទៅធ្វើវត្តចំពោះព្រះសាស្ដាក្នុងទីនោះ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ជាទេវតារបស់ទេវតា ជាអ្នកនាំវិសេសអង្គនោះ កាលទ្រង់សំដែងអភិធម្មណា ដល់ទេវតាទាំងឡាយហើយ ក៏បានត្រាស់ប្រាប់ដល់ព្រះសារីបុត្តត្ថេរ អ្នកឧបដ្ឋាកព្រះមហេសីជាម្ចាស់ ក្នុងអនោតត្តស្រះ ដោយន័យ (សង្ខេប) ទៀតថា "ម្នាលសារីបុត្រ ថ្ងៃនេះតថាគតបានសម្ដែងធម៌ឈ្មោះប៉ុណ្ណោះ អ្នកចូរប្រាប់ដល់ (ភិក្ខុ ៥០០) ជាកូនសិស្សរបស់អ្នក" ព្រះថេរៈបានស្ដាប់ហើយ ក៏បាននិមន្តមកកាន់លំនៅឋាន ហើយប្រាប់ដល់ភិក្ខុទាំងឡាយ, ព្រះអភិធម្មនោះ ដែលភិក្ខុទាំងឡាយបានទ្រទ្រង់ចាំទុកហើយដោយប្រការយ៉ាងនេះ ។

# ជីវប្រវត្តិសង្ខេប

ភិក្ខុ **គង់-សុមិត្ត** គង់នៅពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន គល់ទទឹង

ញោមប្រុស ឈ្មោះ គង់-តិក(ស្លាប់) ញោមស្រី ឈ្មោះ ហុក-តាង រស់នៅក្នុងភូមិទ្វិត ឃុំព្រែកខ្ពប ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។

កើតនៅថ្ងៃព្រហស្បតិ៍ ៩ កើត ខែមិគសិរ ឆ្នាំ ថោះ ព.ស. ២៥១៩ - គ.ស. ១៩៧៦ ។ មានបងប្អូន ៧ នាក់ គឺ ប្រុស ៥ នាក់ ស្រី ២ នាក់. ជាកូនពៅ

ក្នុងកុមារ បានចូលរៀនសាលារដ្ឋ (ក្តាំងផា និង ព្រែកហ្លួង)ដល់ថ្នាក់ទី ៨ ។

ក្នុងព.ស.២៥៣៧ មានអាយុ១៩ឆ្នាំ បួសជាសាមណេរ ក្នុងសំណាក់ឧបជ្ឈាយ៍ ព្រះនាម ឡយ-លឿង វត្តស្លាកែត មកគង់នៅវត្តក្តាំងផា ខេត្តបាត់ដំបង ។

ព.ស. ២៥៣៨ មានអាយុគ្រប់ ២០ បានឧបសម្បទាជាភិក្ខុភាវៈ ។ ព.ស. ២៥៣៩ មកគង់នៅវត្តសមសាន្ត (ខេត្តបាត់ដំបង) រៀនវិន័យ-អភិធម្ម ។ ព.ស. ២៥៤០ មកនៅវត្តនិគ្រោធវ័ន ខេត្តកណ្តាល រៀនធម៌វិន័យបន្ត ។ ព.ស. ២៥៤១ ចេញទៅគង់នៅវត្តខេមវ័ន (ខេត្តកំបាម) បង្រៀនធម៌វិន័យ ។ ព.ស. ២៥៤៥ បានត្រឡប់មកវត្តនិគ្រោធវ័នវិញហើយលាសិក្ខា បានរិតរំ រៀបចំ និងជួយសរសេរសៀវភៅធម៌-វិន័យ ។ ព.ស. ២៥៤៦ បានបួសជាសាមណេរវិញទៀត ក្នុងសំណាក់ព្រះឧបជ្ឈាយ៍ ព្រះនាម ឃី-ទិត វត្តកោះក្របី ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល បានជួយបង្រៀនព្រះវិន័យដល់ព្រះសង្ឃ ក្នុងវត្តនិគ្រោធវ័ន ។ ព.ស. ២៥៤៧ បានឧបសម្បទាជាភិក្ខុ បានបង្រៀនព្រះវិន័យដល់ព្រះសង្ឃ បង្រៀនអភិធម្មដល់ដូនជី ក្នុងវត្តនិគ្រោធវ័ន និងរិតរំរៀបចំសៀវភៅធម៌-វិន័យរហូតមក ។

# អភិធម្មត្ថសង្គហកថា

គម្ពីរអភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ ព្រះអនុរុទ្ធាចារ្យ បានចងក្រងឡើង ។

អភិធម្មត្ថសង្គហៈ មាន ៩ បរិច្ឆេទ គឺ

បរិច្ឆេទទី១ ចិត្តសង្គហវិភាគ ការសម្តែងសង្គ្រោះនិងចែកចិត្ត ៨៩ ឬ១២១

បរិច្ឆេទទី២ ចេតសិកសង្គហវិភាគ ការសម្តែងសង្គ្រោះនិងចែកចេតសិក ៥២

បរិច្ឆេទទី៣ បកិណ្ណកសង្គហៈ ការសម្តែងសង្គ្រោះនិងចែកបកិណ្ណក ៦ ពួក

បរិច្ឆេទទី៤ វិថីសង្គហវិភាគ ការសម្តែងសង្គ្រោះនិងចែកវិថីចិត្ត

បរិច្ឆេទទី៥ វិថីវិមុត្តសង្គហវិភាគ ការសម្តែងសង្គ្រោះនិងចែកវិថីវិមុត្ត

បរិច្ឆេទទី៦ រូបសង្គហវិភាគ-និព្វានបរមត្ថ ការសម្ដែងសង្គ្រោះ និងចែករូបនិងនិព្វាន

បរិច្ឆេទទី៧ សមុច្ចយសង្គហវិភាគ ការសម្ដែងសង្គ្រោះនិងចែកពួកធម៌ជាក្រុម ៗ

បរិច្ឆេទទី៨ បច្ចយសង្គហវិភាគ ការសម្ដែងសង្គ្រោះនិងចែកបច្ច័យ១២ និង២៤

បរិច្ឆេទទី៩ កម្មដ្ឋានវិភាគ ការសម្ដែងចែកកម្មដ្ឋាន ៤០ និងវិបស្សនា ។

សៀវភៅអភិធម្មនេះ ព្រះអនុរុទ្ធាចារ្យបានប្រមូលចងក្រងអំពីបិដក និងអដ្ឋកថា ហើយបានចែកជាបរិច្ឆេទតាមប្រភេទនៃបរមត្ថធម៌ ដើម្បីងាយស្រួលក្នុងការសិក្សា គឺ បរិច្ឆេទទី១ សម្ដែងចិត្តបរមត្ថ, បរិច្ឆេទទី២ សម្ដែងចេតសិកបរមត្ថ, បរិច្ឆេទទី៣, ៤, ៥ សម្ដែងចិត្តបរមត្ថ និងចេតសិកបរមត្ថរួមគ្នា, បរិច្ឆេទទី ៦ សម្ដែងរូបបរមត្ថ, និងនិព្វានបរមត្ថ, បរិច្ឆេទទី៧, ៨, ៩ សម្ដែងបរមត្ថទាំង ៤ រួមគ្នា ។

# បុព្វកថា

សៀវភៅអភិធម្មនេះ ខ្ញុំបានសរសេរក្នុងព.ស. ២៥៤៥ ចប់នៅក្នុងព.ស. ២៥៤៧ ។ ព.ស. ២៥៥២ បានរៀបចំជាសៀវភៅធំ ឈ្មោះថា អភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ ។ ព.ស. ២៥៥៥ ដោយសេចក្ដីត្រូវរបស់អ្នកសិក្សា ក៏បានចែកតាមបរិច្ឆេទនីមួយ ៗវិញ ដើម្បីងាយកាន់សិក្សា ។

ការរៀបចំសៀវភៅអភិធម្មត្ថសង្គហៈនេះ បានចប់សព្វគ្រប់ ហើយ បើមានពាក្យឬសេចក្ដីណានៅខុស ក៏សូមអភ័យទោស និងសូមមេត្តាកែ សម្រួលផងចុះ ។

គម្ពីរព្រះអភិធម្ម ជាគម្ពីរដែលសម្ដែងឡើងនូវធម៌ពិត គឺ សច្ចធម៌ បរមត្ថធម៌ និងបង្ហាញនូវផ្លូវបដិបត្តិឆ្ពោះទៅរកទីរំលត់ទុក្ខ គឺ ព្រះនិព្វាន ។ សត្វលោកដែលកើតមកសុទ្ធតែមានអវិជ្ជា និងតណ្ហាគ្រប់គ្នា មានតែព្រះពុទ្ធនិងព្រះបច្ចេកពុទ្ធទេ ដែលអាចត្រាស់ដឹងនូវធម៌ពិត កម្ចាត់អវិជ្ជាបានដោយខ្លួនព្រះអង្គឯង ក្រៅពីនោះ ត្រូវតែអាស្រ័យ

ព្រះពុទ្ធ ដែលទ្រង់មានព្រះទ័យមហាករុណាសម្តែងប្រាប់ ទើបអាចយល់ដឹងស្គាល់ធម៌ពិត និងបានឃើញផ្លូវបដិបត្តិដល់ព្រះនិព្វានជាទីរំលត់ទុក្ខបាន ។

កាលបើពុទ្ធបរិស័ទទាំងអស់ សិក្សានូវព្រះអភិធម្មបានយល់ដឹងហើយ បញ្ញាក៏កើតឡើង បានឃើញនូវសភាវធម៌ពិតទាំងដែលយើងសព្វថ្ងៃបានជួប បានទាន់ព្រះធម៌កំពុងឋិតនៅសម្រាប់គ្រេបជញ្ជក់ធម្មរស ហើយធ្វើឱ្យយើងមានសម្រស់ក្នុងជីវិត មិនឋិតនៅក្នុងភាពស្ងិតស្រពោន និងសម្រេចមគ្គផលតាមឧបនិស្ស័យដែលយើងបានសន្សំមក, ព្រោះហេតុដូច្នេះទើបខ្ញុំព្យាយាមរៀបចំសៀវភៅនេះឡើង ។ ម្យ៉ាងទៀត សៀវភៅនេះ ក៏ដូចជាសាវកមួយអង្គដែលឈ្លាសវៃនាំយកព្រះពុទ្ធដីកាមកប្រាប់ ហើយពន្យល់សេចក្តីនោះ ឱ្យយើងបានយល់ដឹងឬចាត់ថា ជាគ្រូក៏បាន ។

ការរៀបចំសៀវភៅធម៌នេះ ជាបុណ្យកុសលមួយ

យ៉ាងល្អប្រសើរ ដែលខ្ញុំព្រះករុណា អាត្មាភាព និងពុទ្ធបរិស័ទទាំងឡាយ បានរួបរួមសាមគ្គីជួយឧបត្ថម្ភ ដោយកម្លាំងកាយចិត្ត និងថវិកា ជាចេតនាមហាកុសលថ្នាក់ធម្មទាន និងធម្មបូជា យ៉ាងពេញចិត្តគ្រប់ ៗគ្នា ។ ដោយអំណាចនៃបុណ្យនេះ នឹងនាំឱ្យបានទទួលនូវសេចក្ដីសុខ ជាពិសេស គឺបាននូវបញ្ញាដែលជាពន្លឺញ៉ាំងជីវិតឱ្យរុងរឿងគ្រប់ ៗ ជាតិ រហូតដល់បានលះបង់នូវមន្ទិលគឺ កិលេស ដែលយើងគ្រប់ ៗ គ្នាចង់បាននូវ ការត្រាស់ដឹងនូវសច្ចធម៌ ឃើញច្បាស់នូវព្រះនិព្វាន ដែលជាទីបំផុតទុក្ខ ។ ម្យ៉ាងទៀត បញ្ញានេះឯង អាចឱ្យសម្រេចតាមសេចក្ដីប្រាថ្នានោះបាន ។

ខ្ញុំព្រះករុណាអាត្មាភាព សូមអនុមោទនានូវបុណ្យកុសលរបស់ពុទ្ធបរិស័ទ ទាំងអស់ ដែលបានឧបត្ថម្ភថវិកាជាធម្មទាន និងការខិតខំសិក្សានេះ ។ ម្យ៉ាងទៀត សូមពុទ្ធ

បរិស័ទទាំងអស់ អនុមោទនាយកនូវបុណ្យដែលខ្ញុំព្រះករុណាអាត្មាភាព បានរៀបចំបោះពុម្ពព្រះអភិធម្មនេះផងចុះ ។ សូមឱ្យពុទ្ធបរិស័ទទាំងអស់ មានបញ្ញា ភ្លឺថ្លាមោះមុត ជាគ្រឿងត្រាស់ដឹងនូវសច្ចធម៌ សូមបានសម្រេចនូវសម្បត្តិលោកិយៈ និងលោកុត្តរៈ មានចិត្តល្អបរិសុទ្ធរួចផុតចាកទុក្ខដល់ព្រះនិព្វានគ្រប់ ៗ គ្នា កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអនុមោទនា !!!

ថ្ងៃ១៥កើត ខែស្រាព ឆ្នាំថោះ ត្រីស័ក ព.ស.២៥៥៥

# បញ្ជីមាតិកា អភិធម្មត្ថសង្គហៈ

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**


*សម្ដេចព្រះអភិធម្ម នៅឋានតាវត្តិង្ស ... ... ... ... ក*

*ជីវប្រវត្តិសង្ខេប ... ... ... ... ... ... ... ... ... ... ... ... គ*

*អភិធម្មត្ថសង្គហកថា ... ... ... ... ... ... ... ... ... ... ង*

*បុព្វកថា ... ... ... ... ... ... ... ... ... ... ... ... ... ... ... ឆ*

*បញ្ជីមាតិកា ... ... ... ... ... ... ... ... ... ... ... ... ... ជ*


**អភិធម្មត្ថសង្គហៈ បរិច្ឆេទទី ៨ បច្ចយសង្គហវិភាគ**


*សង្គហគាថាទី១ ... ... ... ... ... ... ... ... ... ... ... ... ១*

*បច្ច័យសង្គហៈ មាន ២ ន័យ ... ... ... ... ... ... ... ... ... ... ១*

*១. បដិច្ចសមុប្បាទន័យ ... ... ... ... ... ... ... ... ... ៤*

*សង្គហគាថាទី២ ... ... ... ... ... ... ... ... ... ... ... ... ៥*

*សង្គហគាថាទី៣-៤ ... ... ... ... ... ... ... ... ... ... ... ៧*

*២. បដ្ឋានន័យ ... ... ... ... ... ... ... ... ... ... ... ... ... ៨*

*សង្គហគាថាទី៥-៦ បច្ចយធម៌ មាន៦ ... ... ... ... ៩*

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ


១-នាមជាបច្ច័យដល់នាម ៦ យ៉ាង ... ... ... ... ១០

២-នាមជាបច្ច័យដល់នាមរូប ៥ យ៉ាង ... ... ... ១១

៣-នាមជាបច្ច័យដល់រូប ១ យ៉ាង ... ... ... ... ... ១១

៤-រូបជាបច្ច័យដល់រូប ១ យ៉ាង ... ... ... ... ... ១២

៥-បញ្ញត្តិនាមនិងរូបជាបច្ច័យដល់នាមប៉ុណ្ណោះ ២យ៉ាង ១២

៦-នាមរូបជាបច្ច័យដល់នាមរូប ៩យ៉ាងតាមសមគួរ ១៣

សហជាតប្បច្ច័យ មាន ៣ យ៉ាង ... ... ... ... ... ១៤

អញ្ញមញ្ញប្បច្ច័យ មាន ៣ យ៉ាង ... ... ... ... ... ១៥

និស្សយប្បច្ច័យ មាន ៣ ... ... ... ... ... ... ... ... ១៥

អាហារប្បច្ច័យ មាន ២ យ៉ាង ... ... ... ... ... ... ១៥

ឥន្ទ្រិយប្បច្ច័យ មាន ៣ ... ... ... ... ... ... ... ... ១៦

វិប្បយុត្តប្បច្ច័យ មាន ៣ ... ... ... ... ... ... ... ... ១៦

អត្ថិបច្ច័យមាន ៥ យ៉ាង ... ... ... ... ... ... ... ... ១៧

សង្គហគាថាទី៧ ... ... ... ... ... ... ... ... ... ... ... ... ១៧

សរុបបច្ច័យ ២៤ ... ... ... ... ... ... ... ... ... ... ... ១៨

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ


សង្គហគាថាទី៨-៩ ... ... ... ... ... ... ... ... ... ... ... ១៩

បញ្ញត្តិនោះ មាន ២ យ៉ាង ... ... ... ... ... ... ... ... ២០

បញ្ញាបីយត្តាបញ្ញត្តិ ៦ ... ... ... ... ... ... ... ... ... ២០

នាមបញ្ញត្តិនេះ មាន ៦ យ៉ាង ... ... ... ... ... ... ... ២២

សង្គហគាថាទី១០-១១ ... ... ... ... ... ... ... ... ... ២៤

អធិប្បាយ សេចក្តីជ្រាលជ្រៅនៃបច្ច័យ ២ ន័យ ... ... ២៥

អធិប្បាយ បដិច្ចសមុប្បាទន័យ ... ... ... ... ... ... ... ... ... ៣២

១- អវិជ្ជា ... ... ... ... ... ... ... ... ... ... ... ... ... ៣២

២- សង្ខារ ... ... ... ... ... ... ... ... ... ... ... ... ... ៣៣

៣- វិញ្ញាណ ... ... ... ... ... ... ... ... ... ... ... ... ... ៣៣

៤- នាមរូប ... ... ... ... ... ... ... ... ... ... ... ... ... ៣៤

៥- សឡាយតនៈ ... ... ... ... ... ... ... ... ... ... ... ៣៥

៦- ផស្ស ... ... ... ... ... ... ... ... ... ... ... ... ... ... ៣៥

៧- វេទនា ... ... ... ... ... ... ... ... ... ... ... ... ... ៣៦

៨- តណ្ហា ... ... ... ... ... ... ... ... ... ... ... ... ... ៣៦

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**


៩- ឧបាទាន ... ... ... ... ... ... ... ... ... ... ... ... ... ៣៦

១០- ភព ... ... ... ... ... ... ... ... ... ... ... ... ... ... ៣៨

១១-ជាតិ ១២-ជរាមរណៈ ... ... ... ... ... ... ... ៤០

អធិប្បាយ បច្ច័យក្នុងបដិច្ចសមុប្បាទ ... ... ... ... ... ... ... ៤២

សរុបអត្ថនៃបដិច្ចសមុប្បាទន័យ ... ... ... ... ... ... ៤៥

អធិប្បាយពាក្យថា អទ្ធាជាដើម ... ... ... ... ... ... ៤៦

អធិប្បាយ អាការ ២០ ... ... ... ... ... ... ... ... ... ៤៨

អធិប្បាយ សង្គហគាថាទី ២ ... ... ... ... ... ... ... ៤៩

អធិប្បាយ សន្ធិ ៣ យ៉ាង ... ... ... ... ... ... ... ... ៥០

អធិប្បាយសង្ខេបជាដើម ... ... ... ... ... ... ... ... ... ៥១

អធិប្បាយ សង្គហគាថាទី ៣-៤ ... ... ... ... ... ... ៥៣

លក្ខណាទិចតុក្កៈរបស់អវិជ្ជា ... ... ... ... ... ... ... ៥៤

លក្ខណាទិចតុក្កៈរបស់សង្ខារ ... ... ... ... ... ... ... ៥៥

លក្ខណាទិចតុក្កៈរបស់វិញ្ញាណ ... ... ... ... ... ... ... ៥៥

លក្ខណាទិចតុក្កៈរបស់នាម ... ... ... ... ... ... ... ... ៥៥

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ


លក្ខណាទិចតុក្កៈរបស់រូប ... ... ... ... ... ... ... ... ៥៦

លក្ខណាទិចតុក្កៈរបស់សឡាយតនៈ ... ... ... ... ... ៥៦

លក្ខណាទិចតុក្កៈរបស់ផស្សៈ ... ... ... ... ... ... ... ៥៧

លក្ខណាទិចតុក្កៈរបស់វេទនា ... ... ... ... ... ... ... ៥៧

លក្ខណាទិចតុក្កៈរបស់តណ្ហា ... ... ... ... ... ... ... ៥៨

លក្ខណាទិចតុក្កៈរបស់ឧបាទាន ... ... ... ... ... ... ... ៥៨

លក្ខណាទិចតុក្កៈរបស់កម្មភវៈ ... ... ... ... ... ... ... ៥៩

លក្ខណាទិចតុក្កៈរបស់ឧប្បត្តិភវៈ ... ... ... ... ... ... ៥៩

លក្ខណាទិចតុក្កៈរបស់ជាតិ ... ... ... ... ... ... ... ... ៥៩

លក្ខណាទិចតុក្កៈរបស់ជរា ... ... ... ... ... ... ... ... ៦០

លក្ខណាទិចតុក្កៈរបស់មរណៈ ... ... ... ... ... ... ... ៦១

លក្ខណាទិចតុក្កៈរបស់សោកៈ ... ... ... ... ... ... ... ៦១

លក្ខណាទិចតុក្កៈរបស់បរិទេវៈ ... ... ... ... ... ... ... ៦២

លក្ខណាទិចតុក្កៈរបស់ទុក្ខ ... ... ... ... ... ... ... ... ៦២

លក្ខណាទិចតុក្កៈរបស់ទោមនស្ស ... ... ... ... ... ... ៦៣

## មាតិកា  អភិធម្មត្ថសង្គហៈ  ទំព័រ

លក្ខណាទិចតុក្កៈរបស់ឧបាយាសៈ ... ... ... ... ... ៦៣
អធិប្បាយ បច្ច័យ ២៤ ក្នុងបដ្ឋានន័យ ... ... ... ... ... ... ... ៦៤
១- ហេតុ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ៦៤
២- អារម្មណប្បច្ច័យ ... ... ... ... ... ... ... ... ... ... ៦៦
៣-អធិបតិប្បច្ច័យ ... ... ... ... ... ... ... ... ... ... ... ៦៧
៤-អនន្តរប្បច្ច័យ ៥-សមនន្តរប្បច្ច័យ ... ... ... ... ៦៧
៦-សហជាតៈ ៧-អញ្ញមញ្ញប្បច្ច័យ ... ... ... ... ... ៧១
៨-និស្សយៈ ៩-ឧបនិស្សយប្បច្ច័យ ... ... ... ... ... ៧៣
១០-បុរេជាតៈ ១១-បច្ឆាជាតប្បច្ច័យ ... ... ... ... ... ៧៤
១២-អាសេវនប្បច្ច័យ ... ... ... ... ... ... ... ... ... ... ៧៦
១៣-កម្មប្បច្ច័យ ១៤-វិបាកប្បច្ច័យ ... ... ... ... ... ៧៧
១៥-អាហារប្បច្ច័យ ... ... ... ... ... ... ... ... ... ... ៧៩
១៦-ឥន្ទ្រិយប្បច្ច័យ ... ... ... ... ... ... ... ... ... ... ៨០
១៧-ឈានប្បច្ច័យ ... ... ... ... ... ... ... ... ... ... ... ៨១
១៨-មគ្គប្បច្ច័យ ... ... ... ... ... ... ... ... ... ... ... ... ៨១

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ

១៩-សម្បយុត្ត ២០-វិប្បយុត្តប្បច្ច័យ ... ... ... ៨២
សម្បយោគលក្ខណៈមាន ៤ គឺ ... ... ... ... ... ... ៨២
វិប្បយុត្តៈ មាន ២ គឺ ... ... ... ... ... ... ... ... ... ៨៣
២១- អត្ថិប្បច្ច័យ ២២- នត្ថិប្បច្ច័យ ... ... ... ៨៤
២៣-វិគត ២៤-អវិគតប្បច្ច័យ ... ... ... ... ... ... ៨៦
អធិប្បាយ សង្គហគាថាទី ៥-៦ ... ... ... ... ... ... ៨៨
វិនិច្ឆ័យជវ័នដល់ភាពជាអាសេវនប្បច្ច័យ ... ... ... ៨៩
អធិប្បាយ កពជាបច្ច័យរបស់នាមរូប ... ... ... ... ៩១
បញ្ញត្តិ នាមរូប ជាបច្ច័យដល់នាម ២ យ៉ាង ... ៩៥
ចិត្ត និងចេតសិកជាបច្ច័យដល់គ្នានិងគ្នា ... ... ... ... ១០២
អធិប្បាយ សង្គហគាថាទី ៧ ... ... ... ... ... ... ... ១០៦
ព្រះនិព្វានទៅមានគ្រប់កាល ... ... ... ... ... ... ... ... ១០៦
សរុបបច្ច័យ ២៤ សល់តែ ៤ យ៉ាង ... ... ... ... ១០៨
អធិប្បាយសហជាតរូប ២ យ៉ាង ... ... ... ... ... ... ១០៩
បច្ច័យ២៤ ដោយសង្ខេបតាំងនៅដោយអាការ៣ ... ១១០

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**


អធិប្បាយ បញ្ញត្តិ ២ យ៉ាង ... ... ... ... ... ... ... ១១១

បញ្ញាបីយត្តា បញ្ញត្តិ ៦យ៉ាង ... ... ... ... ... ... ... ១១៣

១-សន្តានប្បញ្ញត្តិ ... ... ... ... ... ... ... ... ... ... ... ១១៣

២-សមូហប្បញ្ញត្តិ ... ... ... ... ... ... ... ... ... ... ... ១១៣

៣-សម្មតិបញ្ញត្តិ ... ... ... ... ... ... ... ... ... ... ... ... ១១៤

៤-ទិសាកាលប្បញ្ញត្តិ ... ... ... ... ... ... ... ... ... ... ១១៤

៥-អាកាសប្បញ្ញត្តិ ... ... ... ... ... ... ... ... ... ... ... ១១៥

៦-និមិត្តប្បញ្ញត្តិ ... ... ... ... ... ... ... ... ... ... ... ... ១១៥

នាមប្បញ្ញត្តិនោះ មាន ៦ យ៉ាង ... ... ... ... ... ... ១១៨

អធិប្បាយគាថាទី ១០-១១ ... ... ... ... ... ... ... ... ១២០

អង្គធម៌របស់បច្ច័យ ២៤ ... ... ... ... ... ... ... ... ១២៣

អវសានគាថា ... ... ... ... ... ... ... ... ... ... ... ... ១៤២

# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ៨ បច្ចយសង្គហវិភាគ

*នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។*

## សង្គហគាថា

១. យេសំ សង្ខតធម្មានំ　　យេ ធម្មា បច្ចយា យថា

តំវិភាគំ មិហេធានិ　　បវក្ខាមិ យថារហំ ។

*ឥឡូវនេះ ខ្ញុំនឹងពោលការចែកធម៌ទាំងឡាយ ដែលជាបច្ច័យដល់សង្ខតធម៌ទាំងឡាយ ដោយការប្រព្រឹត្តិទៅបានក្នុងបច្ចយសង្គហៈនេះ តាមសមគួរ ។*

## បច្ច័យសង្គហៈ មាន ២ ន័យ

*១-បដិច្ចសមុប្បាទន័យ　　២-បដ្ឋានន័យ*

*បណ្ដាន័យទាំង ២ នោះ ន័យដែលលោកកំណត់ទុកដោយ*

ត្រឹមតែអាការ គឺ ភាវៈនៃធម៌ដែលមានជាប្រក្រតីកើតឡើង ដោយជាបច្ច័យដល់ធម៌នោះ ហៅថា បដិច្ចសមុប្បាទន័យ ។

ចំណែកដែលសល់ហៅថា បដ្ឋានន័យ ព្រោះប្រារព្ធឋិតិ ( ការតាំងនៅដ៏វិសេស ) គឺ បច្ច័យពិសេសចេញទៅ ។ តែលោកអាចារ្យទាំងឡាយ អធិប្បាយន័យទាំងពីរឱ្យពិស្តារបញ្ចូលគ្នាទៅក្នុងន័យទាំង ២ យ៉ាងនេះថា ៖

សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ
វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ
នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ
អាយតនៈ ៦ កើតមាន ព្រោះនាមរូបជាបច្ច័យ
ផស្សៈកើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ
វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ
តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ
ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ
ភពកើតមាន ព្រោះឧបាទានជាបច្ច័យ

## បច្ច័យសង្គហៈ ២ ន័យ

ជាតិកើតមាន ព្រោះភពជាបច្ច័យ

ជរាមរណៈ សេចក្ដីសោកស្ដាយ សេចក្ដីខ្សឹកខ្សួល សេចក្ដីលំបាកកាយ លំបាកចិត្ត និងសេចក្ដីចង្អៀតចង្អល់ចិត្ត កើតមានព្រម ព្រោះជាតិជាបច្ច័យ

ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ដូច្នេះ ឈ្មោះថា បដិច្ចសមុប្បាទន័យ ។

ន័យរបស់បដិច្ចសមុប្បាទមាន ៧ យ៉ាង គឺ ៖

១- **តយោ អទ្ធា** កាល ៣

២- **ទ្វាទសង្គានិ** អង្គ ១២

៣- **វីសតិ អាការា** អាការ២០

៤- **តិសន្ធិ** សន្ធិ ៣

៥- **ចតុសង្ខេបា** សង្ខេប៤

៦- **តីណិ វដ្ដានិ** វដ្ដៈ ៣

៧- **ទ្វេ មូលានិ** មូល ២

# ១. បដិច្ចសមុប្បាទន័យ

* អទ្ធា ៣ គឺ ១-អវិជ្ជា និងសង្ខារ ( រួម ២ ) ជាអតីតអទ្ធា,

២-ជាតិ ជរា មរណៈ( រួម៣ ) ជាអនាគតអទ្ធា,

៣-អង្គទាំង៨ ចន្លោះកណ្តាល មានវិញ្ញាណជាដើម មានភពជាទីបំផុត ជាបច្ចុប្បន្នអទ្ធា ។

* អង្គ ១២ គឺ ១.អវិជ្ជា ២.សង្ខារ ៣.វិញ្ញាណ ៤.នាមរូប ៥.សឡាយតនៈ ៦.ផស្សៈ ៧.វេទនា ៨.តណ្ហា ៩.ឧបាទាន ១០.ភព ១១.ជាតិ ១២.ជរាមរណៈ ។

ក៏ពាក្យថា "សោក"ជាដើម ក្នុងបដិច្ចសមុប្បាទន័យនេះ ជាពាក្យសម្តែងដល់ផលដែលហូរចេញអំពីជាតិ ។

* អាការ ២០ គឺ ក្នុងបដិច្ចសមុប្បាទន័យនេះ តណ្ហាឧបាទាន ភព លោកកាន់យកថា អវិជ្ជា និងសង្ខារ ។

មួយទៀត អវិជ្ជា និងសង្ខារ លោកកាន់យកដោយស័ព្ទថា តណ្ហា ឧបាទាន និងភព ជាអង្គ ៥ គឺ អវិជ្ជា សង្ខារ តណ្ហា

ឧបាទាន ភព ជាអាការ ៥ ហៅថា ក្នុងអតីតកាល មានហេតុ ៥, និងផល ៥ គឺ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនា រួម ៥ អាការនេះ ហៅថា បច្ចុប្បន្នកាល មានផល ៥, អាការ ៥ ដែលជាហេតុនៅក្នុងបច្ចុប្បន្ន ក៏បានដល់ អវិជ្ជា សង្ខារ តណ្ហា ឧបាទាន និងភពនោះឯង សូម្បីអាការ ៥ ដែលជាផលក្នុងអនាគតកាល ក៏បានដល់ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនានោះឯង ។

មួយទៀត ផល ៥ មានវិញ្ញាណជាដើម ដែលកាន់យកដោយស័ព្ទថា ជាតិ ជរា និងមរណៈ ជាមួយគ្នា ព្រោះធ្វើការអធិប្បាយយ៉ាងនេះហើយ ទើបពោលសង្ខេបសេចក្តីទៅ ៖

## សង្គហគាថា

២ អតីតេ ហេតវោ បញ្ច  ឥទានិ ផលបញ្ចកំ
ឥទានិ ហេតវោ បញ្ច  អាយតី ផលបញ្ចកំ ។

ក្នុងអតីតកាល មានហេតុ ៥ យ៉ាង ក្នុងបច្ចុប្បន្នកាល

**មានផល ៥យ៉ាង ក្នុងបច្ចុប្បន្នកាលមានហេតុ ៥យ៉ាង ក្នុងអនាគតកាល មានផល ៥ យ៉ាង ដូច្នេះ ។**

* សន្ធិ ៣ គឺ ១-សង្ខារ តជាមួយនឹងវិញ្ញាណ ជាសន្ធិ
២- វេទនា តជាមួយនឹងតណ្ហា ជាសន្ធិ
៣- ភព តជាមួយនឹងជាតិ ជាសន្ធិ ។

* សង្ខេប ៤ គឺ អវិជ្ជា និង សង្ខារ រួម ២ អង្គ ជាសង្ខេប ១, វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា រួម ៥ អង្គ ជាសង្ខេប ១, តណ្ហា ឧបាទាន ភព រួមអង្គ ៣ នេះ ជាសង្ខេប ១, ជាតិនិងជរាមណៈ ជាវិបាកវដ្តៈ ជាសង្ខេប ១ ។

* វដ្តៈ ៣ គឺ អវិជ្ជា តណ្ហា ឧបាទាន ជាកិលេសវដ្តៈ, សង្ខារ និងភព (កម្មភព) ជាកម្មវដ្តៈ

អង្គដែលនៅសល់ ៧ គឺ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ភព (ឧប្បត្តិភព) គឺ ជាតិ និងជរាមរណៈ ជាវិបាកវដ្តៈ ។

* មូល ២ គឺ អវិជ្ជា និង តណ្ហា ។

## សង្គហគាថា

៣ តេសមេវ ច មូលានំ និរោធេន និរុជ្ឈតិ
ជរាមរណមុច្ឆាយ បីឡិតានមភិណ្ហសោ
អាសវានំ សមុប្បាទា អវិជ្ជាច បវត្តតិ ។

៤ វដ្ដមាពន្ធមិច្ចេវំ តេភូមិកមនាទិកំ
បដិច្ចសមុប្បាទោតិ បដ្ឋបេសិ មហាមុនិ ។

ក៏ព្រោះធម៌ទាំងឡាយ ដែលជាមូលទាំងនោះឯង នឹងរលត់ វដ្ដៈដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ ទើបរលត់ និងព្រោះអាសវៈកើត អវិជ្ជាក៏ចម្រើនឡើងក្រៃលែងដល់សត្វដែលមានការទ្រុឌទ្រោម គឺ ជរា និងមរណៈ បៀតបៀនរឿយ ៗ ។ ព្រះសម្មាសម្ពុទ្ធ ជាមហាមុនី ទ្រង់បញ្ញត្តិវដ្ដៈដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ ដែលវិលទៅមិនដាច់ ដែលមិនមានកំណត់ខាងដើមយ៉ាងនេះ ថា "បដិច្ចសមុប្បាទ" ដោយប្រការដូច្នេះ ។

**ចប់ បដិច្ចសមុប្បាទន័យ**

## ២. បដ្ឋានន័យ

ន័យយ៉ាងនេះថា ៖

| | |
|---|---|
| ១- ហេតុប្បច្ចយោ | ហេតុជាបច្ច័យ |
| ២- អារម្មណប្បច្ចយោ | អារម្មណ៍ជាបច្ច័យ |
| ៣- អធិបតិប្បច្ចយោ | អធិបតីជាបច្ច័យ |
| ៤- អនន្តរប្បច្ចយោ | អនន្តរៈជាបច្ច័យ |
| ៥- សមនន្តរប្បច្ចយោ | សមនន្តរៈជាបច្ច័យ |
| ៦- សហជាតប្បច្ចយោ | សហជាតៈជាបច្ច័យ |
| ៧- អញ្ញមញ្ញប្បច្ចយោ | អញ្ញមអញ្ញៈជាបច្ច័យ |
| ៨- និស្សយប្បច្ចយោ | និស្សយៈជាបច្ច័យ |
| ៩- ឧបនិស្សយប្បច្ចយោ | ឧបនិស្សយៈជាបច្ច័យ |
| ១០- បុរេជាតប្បច្ចយោ | ធម៌កើតមុនជាបច្ច័យ |
| ១១- បច្ឆាជាតប្បច្ចយោ | ធម៌កើតក្រោយជាបច្ច័យ |
| ១២- អាសេវនប្បច្ចយោ | អាសេវនៈជាបច្ច័យ |
| ១៣- កម្មប្បច្ចយោ | កម្មជាបច្ច័យ |

១៤- វិបាកប្បច្ចយោ វិបាកជាបច្ច័យ

១៥- អាហារប្បច្ចយោ អាហារជាបច្ច័យ

១៦- ឥន្ទ្រិយប្បច្ចយោ ឥន្ទ្រិយជាបច្ច័យ

១៧- ឈានប្បច្ចយោ ឈានជាបច្ច័យ

១៨- មគ្គប្បច្ចយោ មគ្គជាបច្ច័យ

១៩- សម្បយុត្តប្បច្ចយោ សម្បយុត្តធម៌ជាបច្ច័យ

២០- វិប្បយុត្តប្បច្ចយោ វិប្បយុត្តធម៌ជាបច្ច័យ

២១- អត្ថិប្បច្ចយោ អត្ថិធម៌ជាបច្ច័យ

២២- នត្ថិប្បច្ចយោ នត្ថិធម៌ជាបច្ច័យ

២៣- វិគតប្បច្ចយោ វិគតធម៌ជាបច្ច័យ

២៤- អវិគតប្បច្ចយោ អវិគតធម៌ជាបច្ច័យ

ឈ្មោះថា បដ្ឋានន័យ ក្នុងអធិការនៃបច្ចយសង្គហៈនេះ ។

## សង្គហគាថា

៥ ឆធា នាមន្តុ នាមស្ស បញ្ចធា នាមរូបិនំ
ឯកធា បុន រូបស្ស រូបំ នាមស្ស ចេកធា ។

៦ បញ្ញត្តិនាមរូបានិ នាមស្ស ឆុធា ទ្វយំ
ទ្វយស្ស នវធា ចេតិ ឆព្វិធា បច្ចយា កថំ ។

បច្ច័យធម៌ មាន ៦ ក្រុម គឺ

១-នាម ជាបច្ច័យដល់នាម ដោយអាការ ៦ យ៉ាង

២-នាម ជាបច្ច័យដល់នាមរូប ៥ យ៉ាង

៣-នាម ជាបច្ច័យដល់រូប ១ យ៉ាង

៤-រូប ជាបច្ច័យដល់នាម ១ យ៉ាង

៥-បញ្ញត្តិ. នាមរូប ជាបច្ច័យដល់នាម ២ យ៉ាង

៦-នាមរូបទាំងពីរ ជាបច្ច័យដល់នាមរូបទាំងពីរ បាន ៩ យ៉ាង តើអ្វីខ្លះ ?

**១-នាមជាបច្ច័យដល់នាម ៦ យ៉ាង គឺ**

ធម៌ គឺ ចិត្តនិងចេតសិកដែលរលត់ទៅហើយ មិនមានរវាងចន្លោះជាបច្ច័យ(គឺ ឧបការៈ)ដល់ធម៌ គឺ ចិត្តនិងចេតសិកដែលជាបច្ចុប្បន្ន ដោយអំណាចនៃអនន្តរប្បច្ច័យ ១, សមនន្តរ-ប្បច្ច័យ ១ នត្ថិប្បច្ច័យ ១, វិគតប្បច្ច័យ ១, ជវនដែលកើត

មុន ៗ ជាបច្ច័យដល់ជវនៃក្រោយ ៗ ដោយអំណាចអាសេវនៃប្បច្ច័យ ១ ជាបច្ច័យដល់គ្នានិងគ្នា, និងធម៌ គឺ ចិត្ត និងចេតសិកដែលកើតព្រមគ្នា ដោយអំណាចនៃសម្បយុត្តប្បច្ច័យ ១ ។

## ២-នាមជាបច្ច័យដល់នាមរូប ៥ យ៉ាង គឺ

ហេតុ ៦ អង្គឈាន ៥ អង្គមគ្គ ៨ ជាបច្ច័យដល់នាមរូបដែលកើតព្រមគ្នា ដោយអំណាចនៃហេតុប្បច្ច័យ ១, ឈានប្បច្ច័យ ១, មគ្គប្បច្ច័យ ១, សហជាតចេតនា (ចេតនាដែលកើតព្រមគ្នា) ជាបច្ច័យដល់នាមរូបដែលកើតព្រមគ្នា និងនានក្ខណិកចេតនា (ចេតនាដែលកើតផ្សេងខណៈគ្នា) ជាបច្ច័យដល់នាមរូប ដែលកើតព្រោះកម្មដោយអំណាចនៃកម្មប្បច្ច័យ ១, វិបាកនាមក្ខន្ធ ៤ ជាបច្ច័យដល់គ្នានិងគ្នា និងដល់រូបដែលកើតព្រមគ្នា ដោយអំណាចនៃវិបាកប្បច្ច័យ ១ ។

## ៣-នាមជាបច្ច័យដល់រូប ១ យ៉ាង គឺ

នាមធម៌ជាចិត្តនិងចេតសិក ដែលកើតខាងក្រោយជាបច្ច័យដល់កាយនេះ ដែលកើតមុនដោយអំណាចនៃបច្ឆាជាតប្បច្ច័យ ។

**៤_រូបជាបច្ច័យដល់រូប ១ យ៉ាង គឺ**

វត្ថុរូប ៦ ជាបច្ច័យដល់វិញ្ញាណធាតុ ៧ ក្នុងបវត្តិកាល អារម្មណ៍ ៥ មានរូបារម្មណ៍ជាដើមជាបច្ច័យដល់វិញ្ញាណវិថី ដោយអំណាចនៃបុរេជាតប្បច្ច័យ ។

**៥_បញ្ញត្តិនាម និងរូបជាបច្ច័យដល់នាមប៉ុណ្ណោះ ២យ៉ាងគឺ**

ដោយអំណាចនៃអារម្មណប្បច្ច័យ និងដោយអំណាចឧបនិស្សយប្បច្ច័យ ។ ក្នុងបច្ច័យទាំង ២ នោះ អារម្មណ៍មាន ៦ យ៉ាង គឺ ដោយអំណាចនៃរូបារម្មណ៍ជាដើម ។

ចំណែកឧបនិស្សយប្បច្ច័យមាន ៣ យ៉ាង គឺ អារម្មណូបនិស្សយប្បច្ច័យ ១, អនន្តរូបនិស្សយប្បច្ច័យ ១, បកតូបនិស្សយប្បច្ច័យ ១ ។

បណ្តាឧបនិស្ស័យ ៣ យ៉ាងនោះ អារម្មណ៍នោះឯង ដែលចិត្ត និងចេតសិកធ្វើឱ្យធ្ងន់ខ្លាំង ឈ្មោះថា អារម្មណូបនិស្សយ ។ ធម៌ គឺ ចិត្ត និងចេតសិក ដែលរលត់ទៅមិនដាច់រយៈ ឈ្មោះថា

អនន្តរូបនិស្សយ ។

ចំណែកបកតូបនិស្ស័យ មានច្រើនយ៉ាង គឺ ធម៌ទាំងឡាយ( ទាំងខាងក្នុងនិងទាំងខាងក្រៅ ) មានរាគៈនិងសទ្ធាជាដើម ១, សុខកាយនិងទុក្ខកាយ១, បុគ្គល១, ភោជនៈ១, ឧតុ១, សេនាសនៈ ១, រមែងជាបច្ច័យដល់ធម៌ មានកុសលជាដើម ដែលជាផលនៃកម្មទាំងខាងក្នុងនិងខាងក្រៅ តាមសមគួរ ។

## ៦-នាមរូបជាបច្ច័យដល់នាមរូប ៩យ៉ាងតាមសមគួរគឺ

១- ដោយអំណាចនៃអធិបតិបច្ច័យ ១
២- ដោយអំណាចនៃសហជាតប្បច្ច័យ ១
៣- ដោយអំណាចនៃអញ្ញមញ្ញប្បច្ច័យ ១
៤- ដោយអំណាចនៃនិស្សយប្បច្ច័យ ១
៥- ដោយអំណាចនៃអាហារប្បច្ច័យ ១
៦- ដោយអំណាចនៃឥន្ទ្រិយប្បច្ច័យ ១
៧- ដោយអំណាចនៃវិប្បយុត្តប្បច្ច័យ ១
៨- ដោយអំណាចនៃអត្ថិប្បច្ច័យ ១

៩- ដោយអំណាចនៃអវិគតប្បច្ច័យ ១ ។

បណ្ដាបច្ច័យទាំងនោះ អធិបតិប្បច្ច័យមាន ២ យ៉ាង គឺ អារម្មណ៍ដែលចិត្តនិងចេតសិកធ្វើឱ្យធ្ងន់ខ្លាំង (គឺ យកចិត្តទុកដាក់មាំ) ជាបច្ច័យដល់នាមទាំងឡាយ ដោយអំណាចនៃអារម្មណាធិបតិប្បច្ច័យ ១, សូម្បីសហជាតាធិបតិទាំង ៤ មានឆន្ទៈជាដើម ជាបច្ច័យដល់នាមរូបទាំងឡាយ ដែលកើតព្រមគ្នាដោយអំណាចសហជាតាធិបតិប្បច្ច័យ ១ ។

## សហជាតប្បច្ច័យ មាន ៣ យ៉ាង គឺ

+ ធម៌ គឺ ចិត្តនិងចេតសិកដែលកើតព្រមគ្នាជាបច្ច័យដល់គ្នានិងគ្នា និងដល់រូបទាំងឡាយ ដែលកើតរួមគ្នា ១
+ មហាភូតរូប ៤ ជាបច្ច័យដល់គ្នានិងគ្នា និងដល់ឧបាទាយរូបទាំងឡាយ ១
+ ក្នុងខណៈបដិសន្ធិវត្ថុរូបនិងវិបាកនាមខន្ធ ៤ ជាបច្ច័យដល់គ្នានិងគ្នា ១ ។

## អញ្ញមញ្ញប្បច្ច័យ មាន ៣ យ៉ាង គឺ

+ ធម៌ គឺ ចិត្តនិងចេតសិកជាបច្ច័យដល់គ្នានិងគ្នា ១
+ មហាភូតរូប ៤ ជាបច្ច័យដល់គ្នានិងគ្នា ១
+ ក្នុងខណបដិសន្ធិ វត្ថុរូបនិងវិបាកនាមក្ខន្ធ ៤ ជាបច្ច័យដល់គ្នានិងគ្នា ១ ។

## និស្សយប្បច្ច័យ មាន ៣ គឺ

+ ធម៌ គឺ ចិត្តនិងចេតសិកជាបច្ច័យដល់គ្នានិងគ្នា និងដល់រូបដែលកើតព្រមគ្នា ១
+ មហាភូតរូបជាបច្ច័យ ដល់គ្នានិងគ្នា និងដល់ឧបាទាយរូបទាំងឡាយ ១
+ វត្ថុ ៦ ជាបច្ច័យ ដល់វិញ្ញាណធាតុ ៧ ទៀត ១ ។

## អាហារប្បច្ច័យ មាន ២ យ៉ាង គឺ

+ កវឡិង្ការាហារជាបច្ច័យដល់រូបកាយនេះ ១
+ អរូបអាហារ ៣ មានផស្សាហារជាដើមជាបច្ច័យដល់នាមរូប

ដែលកើតព្រមគ្នា ១ ។

## ឥន្ទ្រិយប្បច្ច័យ មាន ៣ គឺ

+ ប្រសាទរូប ៥ ជាបច្ច័យដល់ បញ្ចវិញ្ញាណ ១
+ រូបជីវិតិន្ទ្រិយជាបច្ច័យដល់ឧបាទិន្នករូប( កម្មជរូប )១
+ នាមឥន្ទ្រិយ ( មាន ៨ អរូបជីវិតិន្ទ្រិយ មនិន្ទ្រិយ វេទនិន្ទ្រិយ និងឥន្ទ្រិយ ៥ មានសទ្ធិន្ទ្រិយជាដើម ) ជាបច្ច័យដល់នាមរូប ដែលកើតព្រមគ្នា ១ ។

## វិប្បយុត្តប្បច្ច័យ មាន ៣ គឺ

+ ក្នុងខណៈបដិសន្ធិ ហទយវត្ថុជាបច្ច័យដល់វិបាកនាមខន្ធ ៤ ដោយអំណាចសហជាតប្បច្ច័យ និងធម៌ទាំងឡាយ គឺ ចិត្ត និងចេតសិក ជាបច្ច័យដល់រូបកាយដែលកើតព្រមគ្នាដោយអំណាចសហជាតប្បច្ច័យ ១
+ ធម៌ទាំងឡាយ គឺ ចិត្ត និងចេតសិកដែលកើតខាងក្រោយ ជាបច្ច័យដល់រូបកាយនេះ ដែលកើតមុនដោយអំណាច

បច្ឆាជាតប្បច្ច័យ ១ ។

+ វត្ថុរូប ៦ ជាបច្ច័យ ដល់វិញ្ញាណធាតុ ៧ ក្នុងបវត្តិកាលដោយអំណាចបុរេជាតប្បច្ច័យ ១ ។

(ក្នុងវិប្បយុត្តប្បច្ច័យនេះ មានឈ្មោះហៅ ៣ យ៉ាង គឺ សហជាតវិប្បយុត្ត បច្ឆាជាតវិប្បយុត្ត និងបុរេជាតវិប្បយុត្ត តែបុរេជាតវិប្បយុត្ត មាន ២ គឺ វត្ថុបុរេជាតវិប្បយុត្ត និងវត្ថារម្មណបុរេជាតវិប្បយុត្ត) ។

## អត្ថិបច្ច័យមាន ៥ យ៉ាង គឺ

## សង្គហគាថា

៧ សហជាតំ បុរេជាតំ បច្ឆាជាតញ្ច សព្វថា
កពឡីការោ អាហារោ រូបជីវិតមិច្ចយំ ។

សហជាត:១ បុរេជាត:១ បច្ឆាជាត:១ កពឡីង្ការាហារ១ រូបជីវិតិន្ទ្រិយ១ មានដោយប្រការទាំងពួងដូច្នេះ ។

## អធិប្បាយ

*សហជាតត្ថិ* បានដល់ រូបនាមដែលកើតព្រមគ្នានៅមាន ទើបជាបច្ច័យបាន ។

*បុរេជាតត្ថិ* បានដល់ រូបដែលកើតមុននៅមាន ទើបជាបច្ច័យបាន ។

*បច្ឆាជាតត្ថិ* បានដល់ នាមដែលកើតខាងក្រោយនៅមាន ទើបជាបច្ច័យបាន ។

*កវឡិង្ការាហារត្ថិ* បានដល់ រូបអាហារ នៅមាន (វៀរនាមអាហារ ៣) ទើបជាបច្ច័យបាន ។

*រូបឥន្ទ្រិយត្ថិ* បានដល់ ឥន្ទ្រិយរូបតែម៉្យាង (វៀរឥន្ទ្រិយនាម) ដែលនៅមាន ទើបជាបច្ច័យបាន ។

*អវិគតប្បច្ច័យ* ក៏មាន ៥ ដូចគ្នា ។

## សរុបបច្ច័យ ២៤

ក៏បច្ច័យទាំង ២៤ រមែងដល់ការប្រជុំចុះក្នុងបច្ច័យ ៤ គឺ ក្នុងអារម្មណប្បច្ច័យ ១, ក្នុងឧបនិស្សយប្បច្ច័យ ១, ក្នុងកម្មប្បច្ច័យ ១ និងក្នុងអត្ថិប្បច្ច័យ ១ ។

ក៏ក្នុងបដ្ឋានន័យនេះ ពាក្យថា "សហជាតរូប" មាន ២ យ៉ាង សូម្បីដោយប្រការទាំងពួង គឺ ដោយអំណាចនៃរូបដែលមានចិត្ត ជាសមុដ្ឋានក្នុងបវត្តិកាល១ និងកដត្តារូបក្នុងបដិសន្ធិកាល១ ។

## សង្គហគាថា

៨ ឥតិ តេកាលិកា ធម្មា　　កាលមុត្តា ច សម្ភវា
អជ្ឈត្តញ្ច ពហិទ្ធា ច　　សង្ខតាសង្ខតា តថា ។
៩ បញ្ញត្តិនាមរូបានំ　　វសេន តិវិធា ឋិតា
បច្ចយា នាម បដ្ឋានេ　　ចតុវីសតិ សព្វថា ។

ធម៌ទាំងឡាយ ប្រកបដោយកាល ៣ និងផុតចាកកាល ទាំងខាងក្នុង ទាំងខាងក្រៅ ជាសង្ខតៈ និង អសង្ខតៈ តាមដែលកើតឡើង តាំងនៅហើយដោយអាការ ៣ យ៉ាង ដោយអំណាចនៃបញ្ញត្តិ នាមនិងរូប ឈ្មោះថា បច្ច័យ ២៤ ក្នុងបដ្ឋាន ដោយប្រការទាំងពួង ដូច្នេះ ។

បណ្តាបញ្ញត្តិ នាម និងរូបទាំងនោះ រូបធម៌ ហៅថា

រូបក្ខន្ធ, ធម៌ ៥ គឺ អរូបក្ខន្ធ ៤ (គឺ ចិត្ត ចេតសិក) និងនិព្វាន ១ ហៅថា អរូប និង នាមដែលក្រៅពីនោះ ហៅថា បញ្ញត្តិ ។

## បញ្ញត្តិនោះ មាន ២ យ៉ាង

១- បញ្ញាបីយត្តាបញ្ញត្តិ ការតែងតាំង ព្រោះត្រូវការដឹងសេចក្តីសំដៅ ។

២- បញ្ញាបនតោបញ្ញត្តិ ការតែងតាំង ដោយឱ្យដឹងអត្ថតាមសំឡេង ។

## បញ្ញាបីយត្តាបញ្ញត្តិ ៦

១- សន្តានប្បញ្ញត្តិ បញ្ញត្តិអាស្រ័យការបន្ត

២- សមូហប្បញ្ញត្តិ បញ្ញត្តិអាស្រ័យការប្រជុំ

៣- សម្មុតិប្បញ្ញត្តិ បញ្ញត្តិថា ជាសត្វបុគ្គល

៤- ទិសាកាលាទិប្បញ្ញត្តិ បញ្ញត្តិទិសនិងកាលជាដើម

៥- អាកាសប្បញ្ញត្តិ បញ្ញត្តិប្រហោងទទេ មានរណ្តៅ ល្អាងរូងភ្នំជាដើម

៦- **និមិត្តប្បញ្ញត្តិ** បញ្ញត្តិនិមិត្តកសិណ ។

តើយ៉ាងណា ?

គឺ បញ្ញត្តិថា "ផែនដី និងភ្នំជាដើម" ដែលតែងតាំងគ្នា ដោយប្រការនោះ. ដោយអាស្រ័យអាការ គឺ សេចក្តីប្រែប្រួល របស់ភូតរូបនោះ ឈ្មោះថា សន្តានបញ្ញត្តិ ។

បញ្ញត្តិថា "រថ និងរទេះជាដើម" ដោយអាស្រ័យ អាការ គឺ សេចក្តីប្រជុំនៃសម្ភារៈ ឈ្មោះថា សមូហបញ្ញត្តិ ។

បញ្ញត្តិថា "បុរស និងបុគ្គលជាដើម" ដោយអាស្រ័យ ខន្ធបញ្ចកៈ ឈ្មោះថា សម្មុតិបញ្ញត្តិ ។ បញ្ញត្តិថា "ទិស និងកាល ជាដើម" ដោយអាស្រ័យការវិលជុំវិញព្រះចន្ទមានទិសខាងកើតជា ដើម ឈ្មោះថា ទិសាកាលាទិបញ្ញត្តិ ។

បញ្ញត្តិថា "រណ្តៅ ល្អាងជាដើម" ដោយអាស្រ័យ ការ ដែលភូតរូបមិនទល់ដល់គ្នា ឈ្មោះថា កូបគុហាទិបញ្ញត្តិ ។ បញ្ញត្តិថា "កសិណនិមិត្ត"ជាដើម ដោយអាស្រ័យភូតនិមិត្តនោះ ហើយភាវនាពិសេស ឈ្មោះថា និមិត្តបញ្ញត្តិ ។

ក៏បញ្ញត្តិដែលផ្សេងគ្នា ដូចពោលមកហើយយ៉ាងនេះ រមែង មិនមានដោយបរមត្ថ តែក៏ជាអារម្មណ៍នៃចិត្តប្បាទបាន ដោយ អាការ គឺ ស្រមោលរបស់អត្ថដែលគេកំណត់សំដៅយកអាការ នោះ ៗ ព្រោះចូលទៅអាស្រ័យ គឺ ការប្រៀបធៀបដោយអាការ នោះ ៗ ឱ្យជាហេតុ ពោលឱ្យយល់ចូលចិត្តគ្នានាំគ្នាហៅឱ្យដឹងន័យ សេចក្តីដល់គ្នា ព្រោះហេតុនោះ ទើបលោកហៅថា បញ្ញត្តិ ។ បញ្ញត្តិនេះ ឈ្មោះថា បញ្ញា បីយត្តាបញ្ញត្តិ ។ (ម្យ៉ាងទៀតហៅថា អត្ថបញ្ញត្តិ) ។

ចំណែកបញ្ញាបនតោបញ្ញត្តិ លោកសម្តែងដោយនាមបញ្ញត្តិ មានឈ្មោះ និងការតាំងឈ្មោះជាដើម ។

## នាមបញ្ញត្តិនេះ មាន ៦ យ៉ាង គឺ ÷

**១-វិជ្ជមានបញ្ញត្តិ** បញ្ញត្តិរបស់ដែលមានដោយបរមត្ថ

**២-អវិជ្ជមានបញ្ញត្តិ** បញ្ញត្តិរបស់ដែលមិនមាន

**៣-វិជ្ជមានេន អវិជ្ជមានបញ្ញត្តិ** បញ្ញត្តិរបស់ដែលមិនមាន ជា

មួយនិងរបស់ដែលមាន

**៤-អវិជ្ជមានេន វិជ្ជមានបញ្ញត្តិ** បញ្ញត្តិរបស់ដែលមាន ជាមួយរបស់ដែលមិនមាន

**៥-វិជ្ជមានេន វិជ្ជមានបញ្ញត្តិ** បញ្ញត្តិរបស់ដែលមាន ជាមួយរបស់ដែលមាន

**៦-អវិជ្ជមានេន អវិជ្ជមានបញ្ញត្តិ** បញ្ញត្តិរបស់ដែលមិនមាន ជាមួយរបស់ដែលមិនមាន ។

ក្នុងបញ្ញត្តិ ៦ នោះ កាលណាបណ្ឌិតតែងតាំងនូវរូប និងវេទនាជាដើម ដែលតាំងនៅដោយបរមត្ថ ដោយបញ្ញត្តិនេះ កាលនោះ បញ្ញត្តិនោះ លោកហៅថា វិជ្ជមានបញ្ញត្តិ ។ តែបើកាលណាបណ្ឌិតតែងតាំងផែនដី និងភ្នំជាដើម ដែលមិនមានដោយបរមត្ថ ដោយបញ្ញត្តិនេះ ក្នុងកាលនោះ បញ្ញត្តិនេះ លោកហៅថា អវិជ្ជមានបញ្ញត្តិ ។

ចំណែកបញ្ញត្តិដែលនៅសល់ បណ្ឌិតគប្បីជ្រាបដោយអំណាចការផ្សំគ្នារបស់បញ្ញត្តិទាំងពីរនេះថា អ្នកមានអភិញ្ញា ៦

*សំឡេងរបស់ស្ត្រី ចក្ខុវិញ្ញាណ និងពាក្យថា ឱរសរបស់ព្រះរាជា ដែលប្រព្រឹត្តទៅតាមលំដាប់ ។*

**សង្គហគាថា**

១០. វចីឃោសានុសារេន សោតវិញ្ញាណវីថិយា
បវត្តានន្តរុប្បន្ន មនោទ្វារស្ស គោចរា ។
១១. អត្ថា យស្សានុសារេន វិញ្ញាយន្តិ តតោ បរំ
សាយំ បញ្ញត្តិ វិញ្ញេយ្យា លោកសង្កេតនិម្មិតា ។

*អត្ថទាំងឡាយ ដែលជាអារម្មណ៍នៃមនោទ្វារ ដែលកើតឡើងក្នុងលំដាប់នៃការប្រព្រឹត្តិរបស់សោតវិញ្ញាណវិថី ដោយក្រសែសំឡេងនៃវាចា. តពីនោះ បុគ្គលទាំងឡាយ រមែងដឹងបានដោយក្រសែនៃនាមបញ្ញត្តិណា នាមបញ្ញត្តិនោះ ក៏គប្បីជ្រាបថា ជាបញ្ញត្តិដែលសត្វលោកកំពុងធ្វើការកំណត់ទុក ដូច្នោះឯង ។*

# អធិប្បាយ សេចក្ដីជ្រាលជ្រៅនៃបច្ច័យ ២ ន័យ

*ន័យនៃបច្ច័យទាំង ២ ក្នុងបច្ចយសង្គហវិភាគនេះ មាន សេចក្ដីវិចិត្រពិស្ដារ ជ្រាលជ្រៅ ល្អិតសុខុម ទើបនាំពាក្យព្រះពុទ្ធឃោសាចារ្យ ដែលលោកប្រារព្ធសម្ដែងបច្ចយាការជាយ៉ាងច្រើន មកផ្សេផ្សំបន្តិចបន្តួច តាមដែលលោកពោលទុកហើយថា ៖*

*ព្រះពុទ្ធវចនៈដែលជាតន្តិភាសា ដែលព្រះមានព្រះភាគទ្រង់តាំងទុកដោយន័យថា* **អវិជ្ជាបច្ចយា សង្ខារា** *ជាដើមនេះ កុលបុត្រដែលនឹងធ្វើការពណ៌នា សេចក្ដីនៃព្រះបាលីនោះ គួរចូលកាន់ទីប្រជុំពុទ្ធសាវកដែលជាវិភជ្ជវាទី គប្បីជាអ្នកមិនពោលបង្អាច់អាចារ្យរបស់ខ្លួន មិនប្រកាន់ជឿលទ្ធិរបស់ខ្លួន មិនកន្ត្រល់ខ្វល់ខ្វាយក្នុងលទ្ធិដទៃ មិនបដិសេធព្រះសូត្រ ស្របតាមព្រះវិន័យ គួរពិនិត្យមើលមហាប្រទេស សម្ដែងធម៌ឬបរួមអត្ថៈ មិនផ្លាស់ប្ដូរ(ថែមថយ)សេចក្ដី និងមិនសម្ដែងដោយបរិយាយយ៉ាងដទៃ ទើបសមគួរធ្វើការពណ៌នាតាមព្រះបាលី ។*

*មួយទៀត ការពណ៌នាសេចក្ដីនៃបដិច្ចសមុប្បាទ សុម្បីដោយ*

បរមត្ថ ជារឿងធ្វើបានដោយលំបាក ដូចគាថាព័ន្ធដែលបូរាណាចារ្យទាំងឡាយពោលទុកថា ៖

**ធម៌ ៤ យ៉ាង គឺ សច្ចៈ ១ សត្វបញ្ញត្តិ ១ បដិសន្ធិ ១ បច្ចយាការ ១ ជាធម៌ឃើញបានដោយលំបាក និងសម្ដែងបាន ក៏សែនលំបាក ដូច្នេះ ។**

ព្រោះដូច្នោះ ការពណ៌នាបដិច្ចសមុប្បាទ ទើបធ្វើមិនបានដោយងាយ វៀរតែលោកអ្នកបានសម្រេចបរិយត្តិ និងលោកអ្នកសម្រេចមគ្គផល ដូចជាព្រះអានន្ទជាដើម ព្រះពុទ្ធឃោសាចារ្យពោលទុកដូច្នេះ ។

ចំណែកបច្ច័យ ទ្រង់សម្ដែងទុកក្នុងបដ្ឋាននោះ មានន័យវិចិត្រពិស្ដារក្រៃលែងជាង ព្រោះន័យដែលមិនមានទីបំផុត ដែលហៅថា មហាបដ្ឋានអនន្តន័យ និងហៅថា សមន្តប្បដ្ឋាន មានធម្មានុលោមជាដើម ទូលំទូលាយពិស្ដារ មិនដូចបច្ច័យដែលទ្រង់កំណត់ទុកក្នុងបដិច្ចសមុប្បាទនោះ ។

ក្នុងអភិធម្មវិភាវិនីដីកា វិនិច្ឆ័យពាក្យថា បច្ច័យក្នុងន័យនៃ

បដិច្ចសមុប្បាទ និងក្នុងបដ្ឋានទុកផ្សេងគ្នាដូចវចនត្ថៈដែលលោកពោលទុកដូចតទៅនេះ

ន័យទី ១ មានវចនត្ថៈថា **បច្ចយសាមគ្គឹ បដិច្ច សមំ គន្ត្វា ផលានមុប្បាទោ ឯតស្មាតិ = បដិច្ចសមុប្បាទោ បច្ចយោ** ប្រែថា បច្ច័យដែលឈ្មោះថា បដិច្ចសមុប្បាទ ព្រោះអត្ថថា ជាដែនដែលផលទាំងឡាយ តែងអាស្រ័យ គឺ គប្បីពឹងផ្អែកគ្នាជានិច្ចដោយការព្រមគ្នានៃបច្ច័យកើតឡើង ។

ន័យទី ២ មានវចនត្ថៈថា **នានប្បការានិ ឋានានិ បច្ចយា ឯត្ថាតិ អាទិនា = បដ្ឋានំ អនន្តនយសមន្តបដ្ឋានំ** : បករណ៍ដែលឈ្មោះថា **បដ្ឋាន** ដោយន័យជាដើមថា ឋានៈ គឺ បច្ច័យមានប្រការផ្សេង ៗ មាននៅក្នុងបករណ៍នេះ បានដល់ មហាបករណ៍ ដែលឈ្មោះថា អនន្តន័យ និងសមន្តប្បដ្ឋាន ។ ន័យដែលព្រះពុទ្ធទ្រង់សម្ដែងទុកក្នុងមហាបករណ៍នេះ ឈ្មោះថា បដ្ឋាន ។

ក្នុងន័យទាំង ២ នោះ ភាវៈនៃធម៌ដែលមានប្រក្រតីកើតឡើង ព្រោះមានបច្ច័យធម៌នោះ ៗ ឈ្មោះថា តព្ភាវៈ ភាវិភាវៈ

(បច្ច័យធម៌មានអវិជ្ជាជាដើម ឈ្មោះថា តព្ភាវៈ, ភាវៈនៃធម៌ដែលមានប្រក្រតីកើតឡើងព្រោះអវិជ្ជា មានសង្ខារជាដើម ឈ្មោះថា ភាវិភាវៈ) ។ តព្ភាវៈ ភាវិភាវៈនោះឯង ជាន័យដែលលោកកំណត់យកត្រឹមតែអាការ គឺ ភាវៈនៃបច្ច័យ និងភាវៈនៃធម៌ដែលកើតអំពីបច្ច័យនោះ ៗ ដោយពាក្យនេះឯង សូម្បីភាវៈនៃន័យដែលលោកកំណត់យកដោយត្រឹមតែអាការ គឺ ធម៌ដែលមានប្រក្រតីមិនកើតឡើង ដោយមិនជាបច្ច័យដល់ធម៌នោះ រមែងជាការដែលលោកសម្តែងហើយដោយអត្ថ ។

ពិតណាស់ លក្ខណៈនៃបច្ច័យ គួរសម្តែងដោយអំណាចនៃការអនុលោមទៅតាម (វដ្តន័យ មានពាក្យថា "**អវិជ្ជាបច្ចយា សង្ខារា** : សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ជាដើម)[1] និងសេចក្តីផ្ទុយគ្នា (វិវដ្តន័យ មានពាក្យថា **អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ** : ការរលត់នៃសង្ខារ

---

១. សំយុ. និទា. ពុទ្ធវគ្គ. ៣១. ២/២ ។

ព្រោះការវិនាសនិងរលត់ឥតសេសសល់នៃអវិជ្ជាជាដើម )[១] ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **“ឥមស្មឹ សតិ ឥទំ ហោតិ, ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ ។ ឥមស្មឹ អសតិ ឥទំ ន ហោតិ, ឥមស្ស និរោធា ឥទំ និរុជ្ឈតិ** : កាលបើធម្មជាតិនេះមាន ធម្មជាតិនេះក៏មានដែរ, ព្រោះការកើតឡើងនៃធម្មជាតិនេះ ទើបធម្មជាតិនេះកើតឡើងដែរ, កាលបើធម្មជាតិនេះមិនមាន ធម្មជាតិនេះក៏មិនមានដែរ, ព្រោះការរលត់ទៅនៃធម្មជាតិនេះ ទើបធម្មជាតិនេះរលត់ទៅដែរ”[២] ដូច្នេះ ។

**បច្ច័យ** មានវចនត្ថៈថា **បដិច្ច ផលំ ឯតស្មា ឯតីតិ = បច្ចយោ** : ធម៌ដែលឈ្មោះថា បច្ច័យ ព្រោះអត្ថថា ជាដែនអាស្រ័យប្រព្រឹត្តនៃផល ។ **តិដ្ឋតិ ផលំ ឯត្ថ តទាយត្តវុត្តិតាយាតិ = ឋិតិ** : បច្ច័យដែលឈ្មោះថា ឋិតិ ព្រោះអត្ថថា ជាទីតាំងនៅនៃ

---

១. សំយុ. និទា. ពុទ្ធវគ្គ. ៣១. ៣/៣ ។

២. សំយុ. និទា. ទសពលវគ្គ. ៣១. ៦៤/៥៩ ។

ផល ដោយមានការប្រព្រឹត្តិទៅជាប់ដោយហេតុនោះ ឋិតិ ពោលគឺ បច្ច័យដែលប៉ះខ្ទប់(កើត)ហើយ ប្រព្រឹត្តទៅដែលពិសេសចេញទៅ ឈ្មោះថា អាហច្ចប្បច្ចយឋិតិ ។

ពិតមែន បដិច្ចសមុប្បាទន័យ មិនសម្លឹងដល់សេចក្តីពិសេសដែលកំណត់បច្ច័យ មានហេតុប្បច្ច័យជាដើម រមែងប្រព្រឹត្តទៅដោយមិនវិសេស ព្រោះការប្រព្រឹត្តិទៅ ប្រាថ្នាសំដៅត្រឹមតែអាការ គឺ ភាវៈនៃធម៌មានប្រក្រតីកើតឡើងដោយមានបច្ច័យធម៌នោះ ចំណែកបដ្ឋានន័យនេះ ឈ្មោះថា ប្រព្រឹត្តវិសេសហើយ ព្រោះសំដៅយកសេចក្តីវិសេសនៃអាការដែលអាចក្នុងភាពជាបច្ច័យនោះ ៗ នៃបច្ច័យនោះ ៗ មានហេតុបច្ច័យជាដើម ដែលជាបច្ច័យដូច្នោះ ដល់ធម៌ដទៃនោះ ៗ ព្រោះដូច្នោះ ទើបលោកហៅថា បដ្ឋានន័យ ព្រោះប្រារព្ធអាហច្ចប្បច្ចយធិតិ ។ តែអាចារ្យពួកខ្លះពោលថា ឋិតិ គឺ បច្ច័យដែលនិយាយចេញមកប៉ះ គឺ ប៉ះខ្ទប់ទីឋានករណ៍(ជាហេតុធ្វើសំឡេង)ទាំងឡាយ មានកនិងពិជានជាដើម ឈ្មោះថា អាហច្ចប្បច្ច័យ ។ ក៏ពាក្យដែល

ពោលនោះ រមែងប្រកាសសេចក្ដីដែលអាចារ្យទាំងនោះ ជាអ្នកមានពាក្យសំដីគួរសើច ដោយត្រឹមតែបានឮប៉ុណ្ណោះ ។ ពិតមែនបដិច្ចសមុប្បាទន័យក្ដី ន័យអ្វីដទៃក្ដី ព្រះមានព្រះភាគទ្រង់អាចដើម្បីនឹងសម្ដែង មិនឱ្យប៉ះខ្ទប់កន្លែងសុរង និងពិតានជាដើមបាន ក៏ទេដូច្នោះឯង ។

មួយទៀត អាចារ្យទាំងឡាយ មានសង្គាហកាចារ្យជាដើមផ្សំគឺ រួមបញ្ចូលនូវបដ្ឋានន័យក្នុងបដិច្ចសមុប្បាទនុ៎ះឯង ហើយអធិប្បាយ គឺ ពង្រីកឱ្យលាយគ្នា ដោយភាវៈនៃធម៌ ដែលមានប្រក្រតីកើតឡើង ព្រោះមានបច្ច័យធម៌នោះ និងដោយអំណាចនៃបច្ច័យ មានហេតុប្បច្ច័យជាដើម ។ ចំណែកពួកខ្ញុំមានសេចក្ដីប្រាថ្នាចែកសម្ដែងជាផ្នែក ៗតែម្ដង ។

# អធិប្បាយ បដិច្ចសមុប្បាទន័យ

## ១- អវិជ្ជា

***អវិជ្ជា*** *មានវចនត្ថៈថា* ***ន វិជ្ជានាតីតិ = អវិជ្ជា*** *ធម្មជាតិដែលឈ្មោះថា អវិជ្ជា ព្រោះអត្ថថា មិនដឹង ។*

*មួយទៀត ធម្មជាតិដែលឈ្មោះថា អវិជ្ជា ព្រោះអត្ថថា ប្រសព្វ គឺ ប្រសព្វរបស់ដែលមិនគួរប្រសព្វ មានកាយទុច្ចរិតជាដើម ឬថា មិនធ្វើរបស់ដែលគួរដឹង មានអរិយសច្ចៈ ៤ ជាដើមឱ្យប្រាកដ រមែងញុំាងសត្វឱ្យត្រាច់ទៅក្នុងអារម្មណ៍ ដែលមិនមាន( ដោយបរមត្ថ ) ឬមិនឱ្យត្រាច់ទៅក្នុងអារម្មណ៍ដែលមាន ។*

*ពាក្យថា "អវិជ្ជា" នេះ ជាឈ្មោះនៃសេចក្តីមិនដឹងក្នុងអរិយសច្ចៈ ៤ និងក្នុងឋានៈ ៤ មានសេចក្តីមិនដឹងក្នុងខន្ធ ដែលជាចំណែកខាងដើម ។ បច្ច័យ គឺ អវិជ្ជា ព្រោះហេតុនោះ ទើបឈ្មោះថា អវិជ្ជាបច្ច័យ ។ ព្រោះអវិជ្ជាបច្ច័យនោះ ទើបមានសង្ខារទាំងឡាយ ។*

## ២_ សង្ខារ

*សង្ខារ* មានវចនត្ថៈថា **សង្ខតមភិសង្ខរោន្តីតិ = សង្ខារា កុសលាកុសលកម្មានិ** សភាវៈ ដែលឈ្មោះថា សង្ខារ ព្រោះអត្ថថា ប្រជុំតាក់តែងសង្ខតធម៌ បានដល់ កុសលកម្មនិងអកុសលកម្ម ។

សង្ខារនោះ មាន ៣ យ៉ាង គឺ បុញ្ញាភិសង្ខារ ១ អបុញ្ញាភិសង្ខារ ១ អនេញ្ជាភិសង្ខារ ១ ។

បណ្តាសង្ខារទាំងនោះ កុសលចេតនាជាកាមាវចរ ៨ និងរូបាវចរ ៥ ឈ្មោះថា បុញ្ញាភិសង្ខារ ។

អកុសលចេតនា ១២ ឈ្មោះថា អបុញ្ញាភិសង្ខារ
អរូបាវចរកុសលចេតនា ៤ ឈ្មោះថា អនេញ្ជាភិសង្ខារ
រួមចេតនា ២៩ នេះហើយ ឈ្មោះថា សង្ខារ ។

## ៣_ វិញ្ញាណ

**វិញ្ញាណ** មានវចនត្ថៈថា **វិជានាតីតិ = វិញ្ញាណំ :** ឈ្មោះថា វិញ្ញាណ ព្រោះអត្ថថា ដឹង ។

វិបាកចិត្ត ១៩ ដោយអំណាចនៃបដិសន្ធិកាលនិងវិបាកចិត្ត

៣២ ដោយអំណាចនៃបវត្តិកាល ឈ្មោះថា វិញ្ញាណ ។

## ៤_ នាមរូប

**នាមរូប** មានវិចនត្ថៈថា **នាមញ្ច រូបញ្ច** = **នាមរូបំ** : នាមផង រូបផង ឈ្មោះថា នាមរូប ។

បណ្តានាមនិងរូបនោះ នាម បានដល់ នាមក្ខន្ធ ៣ មានវេទនាជាដើម, ចំណែករូប បានដល់ រូបដែលមានកម្មជាសមុដ្ឋាន មាន ២ យ៉ាង ដោយចែកជាភូតរូបនិងឧបាទាយរូប, សូម្បីរូបទាំង ២ នោះ បណ្ឌិតគប្បីជ្រាបថា កើតព្រមគ្នា បដិសន្ធិវិញ្ញាណ ក្នុងពាក្យថា "នាមរូបប្បច្ចយា"នេះ គប្បីជ្រាបសរូបេកសេសន័យថា **នាមញ្ច រូបញ្ច នាមរូបញ្ច** = **នាមរូបំ** ប្រែថា នាមផង រូបផង នាមរូបផង ឈ្មោះថា នាមរូប ។

( លោកធ្វើសរូបេកសេសន័យទុកដូច្នេះ ព្រោះពេលខ្លះវិញ្ញាណជាបច្ច័យឱ្យនាម ពេលខ្លះជាបច្ច័យឱ្យរូប ពេលខ្លះជាបច្ច័យឱ្យនាមរូប ) ។

អាយតនៈខាងក្នុង ៦ មានចក្ខុជាដើម ឈ្មោះថា អាយតនៈម្យ៉ាងទៀត តាមមតិអាចារ្យពួកខ្លះ អាយតនៈខាងក្រៅ ៦ មានរូបជាដើម ក៏ឈ្មោះថា អាយតនៈ ។

## ៥_ សឡាយតនៈ

**សឡាយតន** មានវចនត្ថៈថា **ឆ អាយតនានិ ច ឆដ្ឋាយតនញ្ច = សឡាយតនំ** : អាយតនៈ ៦ និងអាយតនៈទី ៦ ឈ្មោះថា សឡាយតនៈ ។

## ៦_ ផស្ស

**ផស្ស** មានវចនត្ថៈថា **ផុសតីតិ = ផស្សោ** : ឈ្មោះថា ផស្សៈ ព្រោះអត្ថថា ពាល់ត្រូវ ។

ផស្សៈ ដែលប្រព្រឹត្តទៅនៅក្នុងទ្វារ ៦ ដោយអំណាចចក្ខុសម្ផស្សជាដើម ឈ្មោះថា ផស្សៈ ។

## ៧_ វេទនា

***វេទនា*** *មានវចនត្ថៈថា* ***វេទយតីតិ*** *=* ***វេទនា*** *: ឈ្មោះថា វេទនា ព្រោះអត្ថថា ដឹងខ្លួន គឺ សោយអារម្មណ៍ ។*

*វេទនាមាន ៣ យ៉ាង ដោយអំណាចនៃសុខ ទុក្ខ និងឧបេក្ខា ។*

## ៨_ តណ្ហា

***តណ្ហា*** *មានវចនត្ថៈថា* ***បរិតោសេតីតិ*** *=* ***តណ្ហា*** *: ឈ្មោះថា តណ្ហា ព្រោះអត្ថថា ប្រាថ្នា ឬចង់ ឬញៀន ( ឱ្យត្រេកអរ ) ។*

*តណ្ហាមាន ៣ យ៉ាង គឺ ១_កាមតណ្ហា ២_ភវតណ្ហា ៣_និងវិភវតណ្ហា ។*

*តែដោយអំណាចនៃអារម្មណ៍ ៦ ជាដើម ទើបមាន ១០៨ ប្រភេទ ។*

## ៩_ ឧបាទាន

***ឧបាទាន*** *មានវចនត្ថៈថា* ***ឧបាទិយតីតិ*** *=* ***ឧបាទានំ*** *ប្រែថា ឈ្មោះថា ឧបាទាន ព្រោះអត្ថថា ប្រកាន់មាំ ។*

ឧបាទានមាន ៤ គឺ ១.កាមុបាទាន ២.ទិដ្ឋុបាទាន ៣.សីលព្វតុបាទាន ៤.អត្តវាទុបាទាន ។

ក៏បណ្ដាតណ្ហា និងឧបាទាននោះ មានសេចក្ដីផ្សេងគ្នាដូច្នេះ គឺ តណ្ហាដែលមានកម្លាំងខ្សោយ ឈ្មោះថា តណ្ហា, ចំណែកតណ្ហាដែលមានកម្លាំងខ្លាំង ឈ្មោះថា ឧបាទាន ។

ម្យ៉ាងទៀត សេចក្ដីប្រាថ្នាក្នុងអារម្មណ៍ នៅមិនមកដល់ជាតណ្ហា ប្រៀបដូចជាចោរលូកដៃចេញទៅក្នុងទីងងឹត, សេចក្ដីប្រកាន់មាំក្នុងអារម្មណ៍ដែលដល់ហើយ ជាឧបាទាន ដូចចោរចាប់របស់បានហើយ ។

តណ្ហាជាបដិបក្ខនឹងសេចក្ដីប្រាថ្នាតិច, ឧបាទាន ជាបដិបក្ខនឹងសេចក្ដីសន្ដោស ។

តណ្ហា ជាមូលហេតុនៃទុក្ខក្នុងការស្វែងរក ចំណែកឧបាទាន ជាមូលហេតុនៃទុក្ខក្នុងការរក្សា ។

សេចក្ដីផ្សេងគ្នាយ៉ាងនេះ ។

## ១០- ភព

ភពមាន ២ យ៉ាង គឺ កម្មភព និងឧប្បត្តិភព ។

ភពទី ១ **កម្មភព** មានវចនត្ថៈថា **ភវតិ ឯតស្មា ផលន្តិ = ភវោ** : ឈ្មោះថា ភព ព្រោះអត្ថថា ជាទីកើតនៃផល ភពទី ១ នេះ មានចេតនា ២៩ យ៉ាងដោយអំណាចកាមាវចរកុសល និងអកុសលជាដើម ។

ភពទី ២-**ឧប្បត្តិភព** មានវចនត្ថៈថា **ភវតីតិ = ភវោ** : ឈ្មោះថា ភព ព្រោះអត្ថថា កើត ។

ភព គឺ ឧប្បត្តិភពនោះ មាន ៩ យ៉ាង ដោយអំណាចនៃកាមភពជាដើម ។

## ឧប្បត្តិភព ៩ គឺ ÷

១- **កាមភព** ដោយបរមត្ថ បានដល់ កាមវិបាកចិត្ត ២៣ ចេតសិក ៣៣ កម្មជរូប ២០,

២- **រូបភព** ដោយបរមត្ថ បានដល់ រូបវិបាកចិត្ត ៥ ចក្ខុវិញ្ញាណ

២ សោត វិញ្ញាណ ២ សម្បដិច្ឆន្នចិត្ត ២ សន្តីរណចិត្ត ៣ ចេតសិក ៣៥ កម្មជរូប ១៥,

៣- **អរូបភព** ដោយបរមត្ថ បានដល់ អរូបវិបាកចិត្ត ៤ ចេតសិក ៣០,

៤- **សញ្ញីភព** ដោយបរមត្ថ បានដល់ លោកិយវិបាកចិត្ត ៣១ ( វៀរនេវសញ្ញានាសញ្ញាវិបាកចិត្ត ១ ),

៥- **អសញ្ញីភព** ដោយបរមត្ថ បានដល់ ជីវិតនវកកលាប,

៦- **នេវសញ្ញីនាសញ្ញីភព** ដោយបរមត្ថ បានដល់ នេវសញ្ញានាសញ្ញាយតនវិបាកចិត្ត ១ ចេតសិក ៣០,

៧- **ឯកវោការភព** ដោយបរមត្ថ បានដល់ ជីវិតនវកកលាប,

៨- **ចតុវោការភព** ដោយបរមត្ថ បានដល់ អរូបវិបាកចិត្ត ៤ ចេតសិក ៣០,

៩- **បញ្ចវោការភព** ដោយបរមត្ថ បានដល់ កាមវិបាកចិត្ត ៣២ រូបវិបាក ចិត្ត ៥ ចេតសិក ៣៥ កម្មជរូប ២០,

ន័យមួយទៀត បានដល់ សត្តាវាស ៩

ភពទាំងនេះ កាលសម្ដែងដោយបុគ្គលាធិដ្ឋាន បានដល់សត្វដែលកើតនៅក្នុងភពនោះ ។

ឧប្បត្តិភព ៩ នេះ បើសម្ដែងដោយសង្ខេបទើងមានតែ៣ គឺ កាមភព ១, រូបភព ១, និងអរូភព ១,

ក៏ក្នុងបទថា "ឧបាទានបច្ចយាភវោ" នេះ សូម្បីឧប្បត្តិភព លោកក៏ប្រាថ្នាយក ។

ក្នុងពាក្យថា "ភវប្បច្ចយា ជាតិ" នេះ លោកប្រាថ្នាយកកម្មភពប៉ុណ្ណោះ ។ ពិតមែន កម្មភពនោះ រមែងជាបច្ច័យដល់ជាតិ, ភពក្រៅពីនេះ មិនជាបច្ច័យទេ ព្រោះឧប្បត្តិភពនោះ ជាសភាវៈនៃខន្ធដែលកើតមុនដំបូង ក៏គឺ ជាតិនោះឯង ក៏ឧប្បត្តិភពជាហេតុដល់ឧប្បត្តិភពនោះ មិនគួរទេ ។

## ១១. ជាតិ ១២. ជរាមរណៈ

ការបានចំពោះអត្តភាពរបស់សត្វនោះ. ក្នុងទីកន្លែងទាំងឡាយ មានគតិជាដើមនោះ. ឈ្មោះថា **ជាតិ,**

ភាវៈនៃអត្តភាព ដែលកើតមកហើយយ៉ាងនោះ ចាស់ទ្រុឌទ្រោមទៅ ឈ្មោះថា **ជរា**,

សេចក្តីផុតរលត់ អស់នៃអត្តភាពនោះហើយ ដែលកំណត់នៅក្នុងភពមួយ ឈ្មោះថា **មរណៈ**,

សេចក្តីសៅហ្មងចិត្តរបស់មនុស្ស ដែលត្រូវទុក្ខធ្វើទារុណកម្ម ( បៀតបៀន ) មានសេចក្តីវិនាសញាតិជាដើម ពាល់ត្រូវហើយ ឈ្មោះថា **សោកៈ**,

សេចក្តីត្អូញត្អែររៀបរាប់ ដោយវាចារបស់មនុស្សនោះឯង ឈ្មោះថា **បរិទេវៈ**,

ទុក្ខវេទនា ប្រព្រឹត្តទៅតាមផ្លូវកាយ ឈ្មោះថា **ទុក្ខ**,

ទុក្ខវេទនា ប្រព្រឹត្តទៅតាមផ្លូវចិត្ត ឈ្មោះថា **ទោមនស្ស**,

សេចក្តីចង្អៀតចង្អល់ចិត្ត ហួសពីការអត់ទ្រាំត្រូវទុក្ខផ្លូវចិត្តមានប្រមាណក្រៃលែងបន្ថែមឱ្យជាទ្វេឡើងរបស់ខ្លួន ដែលទុក្ខធ្វើទារុណកម្ម ( បៀតបៀន ) មានជាសេចក្តីវិនាសញាតិជាដើម ឈ្មោះថា **ឧបាយាសៈ** ។

## អធិប្បាយ បច្ច័យក្នុងបដិច្ចសមុប្បាទ

ក៏ក្នុងបដិច្ចសមុប្បាទន័យនេះ គប្បីឃើញថា កាលបច្ច័យដទៃ ៗ មានវត្ថុ និង អារម្មណ៍ជាដើម ក៏សំដៅយកបច្ច័យមួយយ៉ាង ៗ មានអវិជ្ជាជាដើម ព្រោះភាវៈនៃបច្ច័យដែលជាប្រធាន និងព្រោះភាវៈនៃបច្ច័យដែលប្រាកដ ។

ក៏ក្នុងបច្ច័យ មានអវិជ្ជាជាដើមនេះ សង្ខារទាំងឡាយរមែងកើតចេញពីអវិជ្ជាបច្ច័យ ព្រោះសង្ខារទាំងឡាយ ប្រព្រឹត្តទៅក្នុងសន្តាន ដែលមានអវិជ្ជាដេកសម្ងំជាប់នៅហើយប៉ុណ្ណោះ ជាហេតុនៃវិបាកធម៌ ។

ចំណែកវិញ្ញាណ ជាធម្មជាតិដែលសង្ខារឱ្យកើត រមែងតាំងនៅក្នុងភពដទៃ ។ ពិតមែន កាលបច្ច័យកើតមិនមាន វិញ្ញាណនោះក៏កើតមិនបាន ព្រោះដូច្នោះ វិញ្ញាណ ទើបកើតពីសង្ខារ ។

ក៏នាមរូបដែលនាមរូបដល់មុន ហើយជាទីអាស្រ័យ ជួយឧបត្ថម្ភហើយ រមែងតាំងនៅក្នុងបដិសន្ធិកាល និងក្នុងបវត្តិកាល ព្រោះដូច្នោះ នាមរូប ទើបឈ្មោះថា កើតពីវិញ្ញាណប្បច្ច័យ ។

ក៏សឡាយតនៈ មាននាមរូបចូលទៅអាស្រ័យ រមែង ប្រព្រឹត្តទៅដោយទ្វារនៃផស្សៈ ៦ តាមសមគួរ, មិនមែន ដោយ ប្រការដទៃទេ ព្រោះដូច្នោះ សឡាយតន ទើបឈ្មោះថា កើតអំពី នាមរូប ។ ក៏ផស្សៈ កាលមានសឡាយតនៈ កើតឡើងប៉ុណ្ណោះ រមែងប៉ះខ្ទប់អារម្មណ៍ តែកាលមិនមានទ្វារ ផស្សៈនោះ ក៏កើតមិន បាន ព្រោះដូច្នោះ ផស្សៈ ទើបឈ្មោះថា កើតអំពីសឡាយតនៈ ។

ក៏សត្វទាំងឡាយ អ្នកត្រូវប៉ះខ្ទប់អារម្មណ៍ដែលគួរប្រាថ្នា ឬ មិនគួរប្រាថ្នា និងជាកណ្តាលនោះឯង ទើបវេទនាសោយ មិន មែនដោយប្រការដទៃទេ ព្រោះដូច្នោះ វេទនា ទើបឈ្មោះថា កើត អំពីផស្សៈ ។

តណ្ហា មានវេទនាជាហេតុ រមែងកើតឡើងដល់សត្វ មាន ប្រក្រតីត្រេកអរក្នុងធម៌ទាំងឡាយ ដែលអាស្រ័យវេទនា ព្រោះ ដូច្នោះ តណ្ហា ទើបកើតអំពីវេទនា ។

ក៏ពួកសត្វទាំងឡាយ អ្នកក្រហល់ក្រហាយ( ស្រេកឃ្លាន យ៉ាងខ្លាំង ) ព្រោះជរស្អិត គឺ តណ្ហាប៉ុណ្ណោះ រមែងប្រព្រឹត្តទៅ

ដើម្បីសេចក្ដីប្រកាន់ ក៏ដើម្បីសេចក្ដីប្រកាន់មាំក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃឧបាទាន ។ ពិតមែន សត្វទាំងឡាយ ត្រេកអរក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ព្រោះតណ្ហា រមែងដល់ភាពជាអ្នកជ្រមុជជ្រមុល ជាប់ចិត្តក្នុងកាមទាំងឡាយ ព្រោះដូច្នោះ តណ្ហា ទើបជាបច្ច័យដល់កាមុបាទាន ។

មួយទៀត សត្វដែលជាប់ចិត្តក្នុងអារម្មណ៍ មានរូបជាដើម ជាអ្នកប្រាថ្នាដើម្បីនឹងរួចចាកផុតពីសង្សារ រមែងប្រកាន់សេចក្ដីឃើញខុស ដោយន័យជាដើមថា "ផលនៃទានដែលធ្វើហើយ មិនមានផល"ជាដើម និងការប្រកាន់ក្នុងផ្លូវដែលមិនបរិសុទ្ធថា បរិសុទ្ធ, និងការឃើញទាំង ២ ថា អត្តវាទៈ ការប្រកាន់ថា ខ្លួននិងរបស់ខ្លួនក្នុងខន្ធទាំងឡាយ ព្រោះដូច្នោះ តណ្ហា ទើបជាបច្ច័យដល់ទិដ្ឋុបាទានជាដើម ព្រោះដូច្នោះឧបាទាន ទើបឈ្មោះថា កើតអំពីបច្ច័យ គឺ តណ្ហា ។

សត្វទាំងឡាយ អ្នកតាំងនៅក្នុងឧបាទាន រមែងប្រព្រឹត្តទៅដើម្បីការប្រកបកម្ម ដោយអំណាចនៃកុសលសម្បយោគ និង

អនុស័យតាមសមគួរ ព្រោះដូច្នោះឧបាទាន ទើបជាបច្ច័យដល់ភព (ឧប្បត្តិភព) ។

ក៏ជាតិ ពោលគឺ ឧប្បត្តិភពដែលមានកម្មភពជាហេតុនុ៎ះឯង រមែងកើតបានក្នុងភពនោះ ប្រៀបដូចជាពន្លកនៃពូជវក្ខជាតិ កើតចេញពីពូជដូច្នោះ ព្រោះហេតុនោះ ភព (កម្មភព) ទើបជាបច្ច័យដល់ជាតិ ។ ក៏កាលជាតិនោះឯងមាន ទើបកើតជរានិងមរណៈ ។ ពិតមែន ជរា ឬមរណៈ រមែងមិនមានដល់សត្វដែលមិនកើត ព្រោះហេតុនោះ ជាតិ ទើបឈ្មោះថា ជាបច្ច័យដល់ជរានិងមរណៈ ដោយប្រការដូច្នេះ ។ បណ្ឌិតគប្បីឃើញភាវៈនៃបច្ច័យទាំងឡាយមានអវិជ្ជាជាដើម ជាធម៌មានប្រក្រតីកើតឡើង ដោយមានបច្ច័យនោះ ៗ ដូច្នោះឯង ។

## សរុបអត្ថនៃបដិច្ចសមុប្បាទន័យ

ការកើតឡើងនៃកងទុក្ខទាំងអស់ ពោលគឺ វដ្តៈសុទ្ធ ៗ មិនលាយឡំដោយសុខជាដើម រមែងមានវិធី គឺ ការបន្តនៃបច្ច័យ តាមដែលពោលហើយ មិនបានមានដោយការនិម្មិតរបស់ព្រះជាម្ចាស់

មានព្រះឥស្សរជាដើម ហើយទាំងមិនមែនជាការកើតឡើងនៃសភាវៈ មានសេចក្តីសុខនិងសេចក្តីល្អស្អាត ក្នុងអធិការនៃបច្ច័យសង្គហៈ នេះឯង ។

## អធិប្បាយពាក្យថា អទ្ធាជាដើម

***អទ្ធា*** មានវចនត្ថៈថា ***អតតិ សតតំ គច្ឆតិ បវត្តតីតិ*** = ***អទ្ធា*** : កាលណា រមែងធ្វើដំណើរទៅ បានដល់ រមែងប្រព្រឹត្ត ទៅបានជាប់តគ្នារឿយ ៗ ជានិច្ច ព្រោះហេតុនោះ កាលនោះ ឈ្មោះថា អទ្ធា ។

អវិជ្ជា និងសង្ខារ ជាអតីតអទ្ធា ព្រោះសេចក្តីដែលអវិជ្ជា និងសង្ខារទាំងនោះជាហេតុ រាប់បញ្ចូលហើយនៅក្នុងអតីតភពទុំះ ឯង លោកប្រាថ្នាយកក្នុងទីនេះ ។ ក៏ដោយ ***អទ្ធា*** ស័ព្ទ សំដៅ យកធម៌ មានអវិជ្ជាជាដើម ព្រោះធម៌អ្វី ៗ ផុតចាកកាលនោះ មិន មានទេ ។ ពិតមែន ធម៌ទាំងឡាយ ដែលរលត់ទៅហើយ និងមិន កើតឡើង បណ្ឌិតពោលដោយអំណាចនៃអតីតកាល និងអនាគត

កាល ចំណែកធម៌ដែលមានការរាប់បញ្ចូលក្នុងខណៈទាំង ៣ មានឧប្បាទានខណៈជាដើម លោកពោលដោយអំណាចនៃបច្ចុប្បន្នកាល ។

ជាតិ ជរា និងមរណៈ ឈ្មោះថា អនាគតអទ្ធា ព្រោះនឹងកើតក្នុងអនាគតកាល ចាកហេតុប្បច្ច័យ ។ អង្គ ៨ ចន្លោះកណ្ដាលបច្ចុប្បន្នអទ្ធា បានដល់ អង្គ ៨ មានវិញ្ញាណជាដើម ចន្លោះកណ្ដាល ឈ្មោះថា បច្ចុប្បន្នអទ្ធា ព្រោះអង្គទាំងនោះ ជាផលដែលកើតនៅក្នុងភពនេះ បន្ទាប់ពីអតីតហេតុ និង ព្រោះមានសភាវៈជាហេតុក្នុងភពនេះដល់អនាគតផល ។

លោកអាចារ្យធ្វើទុកក្នុងចិត្ត ដល់ការជំទាស់ថា "សូម្បីសោកៈ និងបរិទេវៈជាដើម ក៏គួរពោលថា ជាអង្គ មិនមែនឬ" ដូច្នេះ ទើបពោលថា សោកៈ អធិប្បាយថា ពាក្យថា សោកៈជាដើម ជាការសម្ដែងផលដែលហូរចេញនៃជាតិ គឺ ត្រឹមតែអមុខផល តែមិនជាការសម្ដែងញែកអង្គផ្សេងមិនអាចធ្វើបានឡើយ ។

## អធិប្បាយ អាការ ២០

ពាក្យថា "សូម្បីតណ្ហាឧបាទាន និងភពជាធម៌ដែលសង្គ្រោះយកហើយ" អធិប្បាយថា តណ្ហា និងឧបាទាន លោកកាន់យកដោយអវិជ្ជាសព្ទ ព្រោះជាធម៌ស្មើគ្នាដោយភាពជាកិលេស, កម្មភព លោកកាន់យកដោយសង្ខារសព្ទ ព្រោះដូចគ្នានឹងកម្មភព ។ គប្បីជ្រាបការជាប់ទាក់ទងគ្នាថា "ក៏អវិជ្ជានិងសង្ខារលោកកាន់យកដោយសព្ទថា តណ្ហាឧបាទាន និងភពដូចគ្នា" សូម្បីក្នុងពាក្យដែលពោលហើយនេះ បណ្ឌិតគប្បីជ្រាបការសង្គ្រោះអវិជ្ជា និងសង្ខារទាំងនោះ ដោយការកាន់យកតណ្ហាឧបាទាន និងភពនោះ ដោយន័យដែលពោលហើយ ។

ក៏លោកអាចារ្យធ្វើទុកក្នុងចិត្តថា "ការកើត ការចាស់ និងការរលត់វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនាទុំះឯងព្រះមានព្រះភាគត្រាស់ថា ជាតិ ជរា និងមរណៈ" ដូច្នេះ ទើបពោលពាក្យជាដើម ដោយសព្ទថា ជាតិ ជរា និងមរណៈ ដូច្នេះ ។

## អធិប្បាយ សង្គហគាថាទី ២

ហេតុ ៥ យ៉ាង ដែលកើតហើយ ក្នុងភពអតីតជាបច្ច័យដល់ផលដែលជាបច្ចុប្បន្ន ដោយអំណាចនៃអវិជ្ជា និងសង្ខារទាំង ២ ដែលលោកពោលទុកដោយសង្ខេបថា "អតីតេ ហេតវោ បញ្ច" និងដោយអំណាចនៃតណ្ហា ឧបាទាន និង ភពទាំង ៣ ដែលលោកកាន់យកដោយអំណាចសង្គ្រោះនៃអវិជ្ជា និងសង្ខារ ។

ពាក្យថា **ឥទានិ ផលបញ្ចកំ** បានដល់ ផល ៥ យ៉ាង មានវិញ្ញាណជាដើម ដែលកើតក្នុងបច្ចុប្បន្ននេះ មានបច្ច័យ គឺអតីតហេតុ ៥ ។ ហេតុក្នុងបច្ចុប្បន្ន ៥ យ៉ាង ជាបច្ច័យដល់ផលក្នុងអនាគត ដោយអំណាចនៃហេតុទាំង ៣ មានតណ្ហាជាដើម ដែលលោកពោលទុកដោយសង្ខេបថា **ឥទានិ ហេតវោ បញ្ច** និងដោយអំណាចនៃអវិជ្ជានិងសង្ខារទាំង ២ ដែលលោកសង្គ្រោះចូលជាមួយគ្នា ។ ពាក្យថា **អាយតឹ ផលបញ្ចកំ** បានដល់ ផល ៥ យ៉ាង មានវិញ្ញាណជាដើម ដែលលោកពោលទុកដោយស័ព្ទថា ជាតិ ជរា និងមរណៈ ដែលនឹងកើតក្នុងអនាគត បន្ទាប់ពីបច្ច័យ

គឺ បច្ចុប្បន្នហេតុ ៥ ។

អាការមាន ២០ យ៉ាង ដោយប្រការដូច្នេះ ។

ពាក្យថា **អាការ** មានវចនត្ថៈថា **អតីតាទីសុ តត្ថ តត្ថ អាកិរិយន្តីតិ អាការា** : ហេតុជាដើម ឈ្មោះថា អាការ ព្រោះអត្ថថា ត្រូវខ្ចាត់ខ្ចាយទៅក្នុងទីនោះ ក្នុងកាលមានអតីតកាលជាដើម ។

## អធិប្បាយ សន្ធិ ៣ យ៉ាង

សន្ធិ ៣ យ៉ាង គឺ ក្នុងរវាងនៃអតីតហេតុទាំងឡាយ និងបច្ចុប្បន្នផល ៥ ជាសន្ធិ ១, ក្នុងរវាងនៃបច្ចុប្បន្នផល ៥ និងបច្ចុប្បន្នហេតុទាំងឡាយជាសន្ធិ ១, និងក្នុងរវាងបច្ចុប្បន្នហេតុទាំងឡាយ និងអនាគតផលជាសន្ធិ ១, ។ សមដូច ពាក្យលោកអាចារ្យពោលទុកថា "ក្នុងរវាងសង្ខារ និងវិញ្ញាណ ជាសន្ធិ ១, ក្នុងរវាងវេទនា និងតណ្ហា ជាសន្ធិ ១, ក្នុងរវាងភព និងជាតិ ជាសន្ធិ ១ " ។

ពិតមែន បណ្តាសន្ធិទាំងនោះ សន្ធិទី ១ ជាការសម្ពន្ធគ្នាជា

មួយផលនឹងហេតុ ព្រោះផលប្រព្រឹត្តទៅមិនផុតចាកពីហេតុ ។ សន្ធិទី ៣ ក៏ដូចគ្នា ។ សន្ធិទី ២ សម្ពន្ធជាមួយហេតុនិងផល ព្រោះហេតុប្រព្រឹត្តទៅមិនដាច់ខ្សែចាកពីផលដែរ ។ ពិតមែន ធម៌ជាផល ក៏ជាបច្ច័យដល់ធម៌ដទៃដែលមានសភាវៈជាហេតុ ។

## អធិប្បាយសង្ខេបជាដើម

**សង្ខេប** មានវចនត្ថៈថា **សង្ខិបីយន្តិ ឯត្ថ អវិជ្ជាទយោ វិញ្ញាណាទយោ ចាតិ សង្ខេបា** : ធម៌មានហេតុជាដើម ឈ្មោះថា សង្ខេប ព្រោះអត្ថថា ជាទីដែលព្រះមានព្រះភាគទ្រង់សង្ខេបអតីតហេតុ មានអវិជ្ជាជាដើម និងបច្ចុប្បន្នផល មានវិញ្ញាណជាដើមទុក ។

សង្ខេប ៤ គឺ អតីតហេតុ ១, បច្ចុប្បន្នផល ១, បច្ចុប្បន្នហេតុ ១, អនាគតផល ១, រួមជាសង្ខេប ៤ ដោយប្រការដូច្នេះ ។

ក្នុងពាក្យថា "មួយចំណែករបស់ភព ពោលគឺ កម្មភព"

នេះ ចេតនាជាបច្ច័យដល់បដិសន្ធិតទៅក្នុងអនាគត ឈ្មោះថា ភព ។ ចេតនាក្នុងកម្មភពមុនជាបច្ច័យដល់បដិសន្ធិក្នុងភពនេះ គប្បីជ្រាបថា ឈ្មោះថា សង្ខារ ។ ពាក្យថា "អង្គដែលនៅសល់" បានដល់ ធម៌ដែលលោកពោលទុកដោយអំណាចនៃបច្ចុប្បន្នផល ៧ ដោយអំណាចនៃពួក ៥ មានវិញ្ញាណជាដើម មានជាតិ ជរា មរណៈ ជាទីបំផុត ។ ក៏ធម៌មានវិញ្ញាណជាដើម ដែលរាប់បញ្ចូលក្នុងអនាគត បណ្ឌិតគប្បីជ្រាបថា ភព ក្នុងពាក្យថា "មួយចំណែកនៃភព" ពោលគឺ ឧប្បត្តិភព ។ សព្ទថា ចំណែកមួយនៃភព លោកពោលហើយ ព្រោះសូម្បីកម្មភព លោកក៏ពោលដោយភាវៈសព្ទ ។

លោកអាចារ្យធ្វើក្នុងចិត្តថា "អវិជ្ជាជាមូលហេតុដល់ធម៌ដែលជាទីបំផុតខាងដើម តណ្ហាជាមូលហេតុដល់ធម៌ដែលជាចំណែកខាងចុង ទើបពោលមូលហេតុទុក ២ យ៉ាង ដោយអំណាចនៃអវិជ្ជា និងតណ្ហា" ដូច្នេះ ។

## អធិប្បាយ សង្គហគាថាទី ៣_៤

វដ្ដ: រមែងរលត់ទៅ ដោយការរលត់មូលហេតុនៃវដ្ដ: ពោលគឺ អវិជ្ជានិងតណ្ហាទាំងនោះនុ៎ះឯង គឺ ដល់ការមិនកើតទៀតជាធម្មតា បានដល់ ការមិនប្រព្រឹត្តទៅនៃមូលហេតុដែលសម្រេចហើយ ដោយការចាក់ធ្លុះនូវសច្ច: ។

ក៏អវិជ្ជារមែងត្រឡប់ចម្រើនឡើងទៀត ព្រោះការកើតឡើងនៃអាសវ: មានកាមាសវ:ជាដើម ដល់សត្វអ្នកពោរពេញដោយសោក:ជាដើម អ្នកដែលមានសេចក្ដីទុក្ខទ្រោម ពោលគឺ ការចាស់ និងសេចក្ដីស្លាប់បៀតបៀនរឿយ ៗ ។ សមពិត ដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា ***“អាសវសមុទយា អវិជ្ជាសមុទយោ*** : ការកើតឡើងនៃអវិជ្ជា ព្រោះការកើតឡើងនៃអាសវ:”[១] ដូច្នេះ ។ ដោយពាក្យថា “អាសវ:”ជាដើមនេះ សូម្បីអាសវ:ធម៌ដែលជាបច្ច័យដល់អវិជ្ជា រមែងជាការដែលព្រះមានព្រះ

---

១. មជ្ឈិ. មូល. សម្មាទិដ្ឋិសូត្រ. ២០. ១២៨/១៨០ ។

ភាគ ទ្រង់ត្រាស់សម្តែងហើយ ដោយប្រការដែលសម្តែងបច្ច័យនៃអវិជ្ជាយ៉ាងនេះ ចក្រ គឺ បដិច្ចសមុប្បាទនឹងគប្បីជាធម៌ មិនយោងសណ្តោងគ្នាឡើយ ។

ព្រះមហាមុនី គឺ ព្រះសម្មាសម្ពុទ្ធ ទ្រង់តែងតាំង គឺ ទ្រង់បញ្ញត្តិវដ្តៈ គឺ ធម្មជាតិដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយអំណាចនៃកិលេស កម្ម និងវិបាក ដែលប្រព្រឹត្តទៅជានិច្ចមិនដាច់ខ្សែ មិនមានខាងដើម គឺ ប្រាសចាកខាងដើម ឈ្មោះថា តេភូមិកៈ ព្រោះមានការរាប់ចូលក្នុងភូមិថា "បដិច្ចសមុប្បាទ" ដោយន័យដែលពោលហើយ ដោយប្រការដូច្នេះ ។

## លក្ខណាទិចតុក្កៈរបស់អវិជ្ជា

១. **អញ្ញាណលក្ខណា** មានការមិនដឹង ជាលក្ខណៈ

២. **សម្មោហនរសា** មានសេចក្តីវង្វេងព្រម ជាកិច្ច

៣. **ឆាទនបច្ចុប្បដ្ឋានា** មានការបិទបាំងសភាវៈ ជាផល

៤. **អាសវបទដ្ឋានា** មានអាសវៈ ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់សង្ខារ

១. អភិសង្ខរណលក្ខណា មានការប្រជុំតាក់តែង ជាលក្ខណៈ

២. អាយូហនរសា មានសេចក្ដីខ្វល់ខ្វាយ ជាកិច្ច

៣. ចេតនាបច្ចុប្បដ្ឋានា មានចេតនា ជាផល

៤. អវិជ្ជាបទដ្ឋានា មានអវិជ្ជា ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់វិញ្ញាណ

១. វិជាននលក្ខណំ មានការដឹងច្បាស់ ជាលក្ខណៈ

២. បុព្វង្គមរសំ មានភាពជាប្រធាន ជាកិច្ច

៣. បដិសន្ធិបច្ចុប្បដ្ឋានំ មានការកើតបន្ត ជាផល

៤. សង្ខារបទដ្ឋានំ វា មានសង្ខារ ជាបទដ្ឋាន ឬ
 វត្ថារម្មណបទដ្ឋានំ មានវត្ថុនិងអារម្មណ៍ ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់នាម

១. នមនលក្ខណំ មានការបង្អោនទៅ ជាលក្ខណៈ

២. សម្បយោគរសំ មានការប្រកបព្រមគ្នា ជាកិច្ច

៣. អវិនិព្ភោគបច្ចុប្បដ្ឋានំ មានការមិនបែកចេញពីចិត្ត ជាផល
៤. វិញ្ញាណបទដ្ឋានំ មានវិញ្ញាណ ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់រូប

១. រុប្បនលក្ខណំ មានការប្រែប្រួល ជាលក្ខណៈ
២. វិករណរសំ មានការខ្ចាត់ខ្ចាយ ជាកិច្ច
៣. អព្យាកតបច្ចុប្បដ្ឋានំ មានភាពជាអព្យាកត ជាផល
៤. វិញ្ញាណបទដ្ឋានំ មានវិញ្ញាណ ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់សឡាយតនៈ

១. អាយតនលក្ខណំ មានការធ្វើឱ្យវដ្តៈវែងឆ្ងាយ ជាលក្ខណៈ
២. ទស្សនាទិរសំ មានការឃើញជាដើម ជាកិច្ច
៣. វត្ថុទ្វារភាវបច្ចុប្បដ្ឋានំ មានវត្ថុនិងទ្វារ ជាផល
៤. នាមរូបបទដ្ឋានំ មាននាមរូប ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់ផស្សៈ

១. ផុស្សនលក្ខណោ មានការប៉ះខ្ទប់ ជាលក្ខណៈ

២. សំឃដ្ដនរសោ មានអារម្មណ៍តភ្ជាប់ជាមួយចិត្ត ជាកិច្ច

៣. សង្គតិបច្ចុប្បដ្ឋានោ មានការប្រជុំ (វត្ថុ អារម្មណ៍ ចិត្ត) ជាផល

៤. សឡាយតនបទដ្ឋានោ មានសឡាយតនៈ ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់វេទនា

១. អនុភាវនលក្ខណា មានការដឹងខ្លួនឬសោយអារម្មណ៍ ជាលក្ខណៈ

២. វិសយរសសម្ភោគរសា មានការសោយអារម្មណ៍ ជាកិច្ច

៣. សុខទុក្ខបទដ្ឋានា មានសុខនិងទុក្ខ ជាផល

៤. ផស្សបទដ្ឋានា មានផស្សៈ ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់តណ្ហា

១. ហេតុលក្ខណា មានភាពជាហេតុ ជាលក្ខណៈ

២. អភិនន្ទនរសា មានសេចក្តីត្រេកអរ ជាកិច្ច

៣. អតិត្តភាវបច្ចុប្បដ្ឋានា មានសេចក្តីមិនចេះឆ្អែត មិនល្មមក្នុងអារម្មណ៍ ៦ ជាផល

៤. វេទនាបទដ្ឋានា មានវេទនា ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់ឧបាទាន

១. គហណលក្ខណំ មានការប្រកាន់មាំ ជាលក្ខណៈ

២. អមុញ្ចនរសំ មានការមិនលែងចោល ជាកិច្ច

៣. តណ្ហាទឡ្ហត្តទិដ្ឋិបច្ចុប្បដ្ឋានំ មានតណ្ហាមាំទាំ( ខ្ជាំង ) និងទិដ្ឋិជាផល

៤. តណ្ហាបទដ្ឋានំ មានតណ្ហា ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់កម្មភវៈ

១. **កម្មលក្ខណោ** មានកម្ម ជាលក្ខណៈ

២. **ភាវនរសោ**មានការឱ្យកើត ជាកិច្ច

៣. **កុសលាកុសលបច្ចុប្បដ្ឋានោ** មានកុសលនិងអកុសល ជាផល

៤. **ឧបាទានាបទដ្ឋានោ** មានឧបាទាន ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់ឧបត្តិភវៈ

១. **កម្មផលលក្ខណោ** មានភាពជាផលរបស់កម្ម ជាលក្ខណៈ

២. **ភាវនរសោ** មានការកើតឡើង ជាសម្បត្តិរស

៣. **អព្យាកតបច្ចុប្បដ្ឋានោ** មានអព្យាកតៈ ជាផល

៤. **ឧបាទានបទដ្ឋានោ** មានឧបាទាន ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់ជាតិ

១. **តត្ថ តត្ថ ភវេ បឋមាភិនិព្វត្តិលក្ខណា** មានការកើតនៅក្នុងភពនោះ ៗ ជាលក្ខណៈ

២. **និយ្យាតនរសា** មានការប្រគល់ឱ្យ ( នូវខន្ធ ) ជាកិច្ច
៣. **អតីតភវតោ ឥធ ឧម្មុជ្ជនបច្ចុប្បដ្ឋានា** មានការ ( ឃ្លាត ) ចាកពីអតីតភពមកផុសឡើងក្នុងភពថ្មីនេះ ជាផល
**ផលវិសេន ទុក្ខវិចិត្តតាប្បច្ចុបដ្ឋានា វា** ឬមានការសន្សំទុក្ខដោយអំណាចផល ជាអាការប្រាកដ
៤. **ឧបចិតនាមរូបបទដ្ឋានា** មាននាមរូបដែលសន្សំហើយ ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់ជរា

១. **ខន្ធបរិបាកលក្ខណា** មានការចាស់គ្រាំគ្រានៃខន្ធ ជាលក្ខណៈ
២. **មរណូបនយនរសា** មានការបង្អោនទៅជិតសេចក្ដីស្លាប់ ជាកិច្ច
៣. **យោព្វនវិនាសបច្ចុប្បដ្ឋានា** មានការវិនាសនូវវ័យក្មេងកំពុងកម្លោះក្រមុំ ជាអាការប្រាកដ
៤. **បរិបច្ចនាមរូបបទដ្ឋានា** មានរូបកំពុងចាស់គ្រាំគ្រា ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់មរណៈ

១. **ចុតិលក្ខណំ** មានការឃ្លាតចាកទៅ ជាលក្ខណៈ ។
២. **វិយោគរសំ** មានការព្រាត់ប្រាស ជាសម្បត្តិរស
៣. **គតិវិប្បវាសបច្ចុប្បដ្ឋានំ** មានការប្រាសចាកគតិ ជាផល
៤. **បរិភិជ្ជមាននាមរូបបទដ្ឋានំ** មាននាមរូបកំពុងបែកធ្លាយ ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់សោកៈ

១. **អន្តោនិជ្ឈាយនលក្ខណោ** មានការដុតបំផ្លាញភាពខាងក្នុងខ្លួន ជាលក្ខណៈ
២. **ចេតសោ បរិនិជ្ឈាយនរសោ** មានការដុតរោលចិត្ត ជាកិច្ច
៣. **អនុសោចនបច្ចុប្បដ្ឋានោ** មានការសោកសៅរឿយ ៗ ជាអាការប្រាកដ ។
៤. **ទោសចិត្តុប្បាទបទដ្ឋានោ** មានទោសចិត្តកើតឡើង ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់បរិទេវៈ

១. **លាលប្បនលក្ខណោ** មានការត្អូញត្អែ ជាលក្ខណៈ

២. **គុណទោសបរិកិត្តនរសោ** មានការរៀបរាប់ពណ៌នា ដល់គុណនិងទោស ជាកិច្ច

៣. **សម្ភមបច្ចុប្បដ្ឋានោ** មានការក្រវល់ក្រវាយចិត្ត ជាផល

៤. **ទោសចិត្តមហាភូតបទដ្ឋានោ** មានមហាភូតរូបកើតចេញពីទោសចិត្ត ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់ទុក្ខ

១. **កាយបីឡនលក្ខណំ** មានការបៀតបៀនកាយ ជាលក្ខណៈ

២. **ទុប្បញ្ញានំ ទោមនស្សករណរសំ** មានការធ្វើទោមនស្សដល់អ្នកមានបញ្ញាតិច ជាកិច្ច

៣. **កាយិកាពាធបច្ចុប្បដ្ឋានំ** មានអាពាធផ្លូវកាយ ជាផល

៤. **កាយបសាទបទដ្ឋានំ** មានកាយប្រសាទ ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់ទោមនស្ស

១. ចិត្តបីឡនលក្ខណំ មានការបៀតបៀនចិត្ត ជាលក្ខណៈ

២. មនោវិឃាតនរសំ មានការរុកគួនចិត្ត ជាកិច្ច

៣. មានសព្យាធិបច្ចុប្បដ្ឋានំ មានការឈឺចិត្ត ជាផល

៤. ហទយវត្ថុបទដ្ឋានំ មានហទយវត្ថុ ជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈរបស់ឧបាយាសៈ

១. ព្យាសត្តលក្ខណោ មានចិត្តជាប់ក្នុងអារម្មណ៍ផ្សេង ៗ ជាលក្ខណៈ

ចិត្តបរិទហនលក្ខណោ វា ឬមានការដុតចិត្តយ៉ាងខ្លាំង ជាលក្ខណៈ

២. និត្ថុននរសោ មានការដកថយចិត្ត ជាកិច្ច

៣. វិសាទបច្ចុប្បដ្ឋានោ មានការសៅហ្មងចិត្ត ជាផល

៤. ហទយវត្ថុបទដ្ឋានោ មានហទយវត្ថុ ជាបទដ្ឋាន ។

**ចប់ បដិច្ចសមុប្បាទន័យ**

# អធិប្បាយបច្ច័យ ២៤ ក្នុងបដ្ឋានន័យ

ន័យនៃបដ្ឋាន បានដល់ បច្ច័យ ២៤ មានហេតុបច្ច័យជាដើម ទាំងនោះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា "ហេតុប្បច្ច័យ"ជាដើម ។

## ១_ ហេតុ

**ហេតុ** មានវចនត្ថៈថា **ហិនោតិ បតិដ្ឋាតិ ឯតេនាតិ** = **ហេតុ*** : បច្ចយុប្បន្នធម៌[១] រមែងតាំងនៅ គឺ រមែងតាំងមាំដោយបច្ច័យនេះ ព្រោះហេតុនោះ បច្ច័យនោះ ទើបឈ្មោះថា **ហេតុ** ។

ម្យ៉ាងទៀត **ហិនោតិ វា ឯតេន កម្មនិទានភូតេន ឧទ្ធំ ឱជំ អភិហរន្តេន មូលេន វិយ បាទបោ តប្បច្ចយំ ផលំ គច្ឆតិ បវត្តតិ វុឌ្ឍឹ វិរុឡ្ហឹ អាបជ្ជតីតិ** = **ហេតុ** : ផលមានលោភៈជាដើម

---

១. បច្ចយុប្បន្ន មានវចនត្ថៈថា **បច្ចយតោ ឧប្បន្នំ** = **បច្ចយុប្បន្នំ** ផលធម៌ដែលកើតឡើងអំពី បច្ច័យ ឈ្មោះថា បច្ចយុប្បន្នធម៌ ។

នោះ ជាបច្ច័យ រមែងប្រព្រឹត្តទៅ ដំណើរទៅ បានដល់ ការចម្រើនលូតលាស់ល្អដោយបច្ច័យ មានលោភៈជាដើមនេះ ដែលជាហេតុនៃកម្ម ដូចដើមឈើ រមែងតាំងមាំដល់សេចក្ដីចម្រើនលូតលាស់ល្អ ដោយឫសដែលស្រូប ឱជៈ( អាហារ ) ឡើងទៅខាងលើ ព្រោះហេតុនោះ បច្ច័យមានលោភៈជាដើមនោះ ទើបឈ្មោះថា ហេតុ ។ ហេតុនោះផង ជាបច្ច័យផង ព្រោះដូច្នោះ ទើបឈ្មោះថា ហេតុប្បច្ច័យ ។ មានពាក្យអធិប្បាយលោកពោលទុកថា ហេតុជាបច្ច័យ គឺ ជាបច្ច័យដោយសេចក្ដីជាហេតុ ដូច្នេះ ។ ធម៌គ្រឿងជួយឧបត្ថម្ភ គាំទ្រ ដោយអត្ថថា ជាមូលហេតុ ឈ្មោះថា ហេតុប្បច្ច័យ ដោយសង្ខេបថា ឈ្មោះថា ហេតុ ព្រោះអត្ថថា ជាមូល, ឈ្មោះថា បច្ច័យ ព្រោះអត្ថថា ឧបការៈ ដូច្នេះ ។

គប្បីជ្រាបសន្និដ្ឋានថា "ក៏ហេតុបច្ច័យនោះ ជាធម៌ ៦ យ៉ាង ដែលជាគ្រឿងឧបត្ថម្ភដល់រូបទាំងឡាយ មានចិត្តជាសមុដ្ឋានក្នុងបវត្តិកាល និងមានកម្មជាសមុដ្ឋានក្នុងបដិសន្ធិកាល

ទាំងដល់នាមធម៌ដែលសម្បយុត្តគ្នាក្នុងបវត្តិកាល និងបដិសន្ធិកាល ទាំង ២ ដោយអត្ថថា ជាមូល ពោលគឺ ការញុំាងធម៌ ឱ្យតាំងនៅដោយល្អ ឱ្យសម្រេចដោយល្អ ដូចឫសទាំងឡាយនៃដើមឈើ ជាគ្រឿងតាំងនៅនៃដើមឈើ ដូច្នោះ ។

## ២_ អារម្មណប្បច្ច័យ

*អាលម្ពណៈ* មានវចនត្ថៈថា ***អាលម្ពិយតិ ទុព្វលេន វិយ ទណ្ឌាទិកំ ចិត្តចេត សិកេហិ គណ្ហិយតីតិ = អាលម្ពនំ*** : ធម្មជាតិ ដែលឈ្មោះថា អាលម្ពណៈ ព្រោះអត្ថថា ដែលចិត្តនិងចេតសិក តោងទុក គឺ ប្រកាន់ទុក ដូចមនុស្សទុព្វលតោងវត្ថុមានឈើច្រត់ជាដើម ដូច្នោះ ។ ពិតមែន ចិត្ត និងចេតសិកប្រារព្ធនូវធម៌ណា ៗ រមែងប្រព្រឹត្តធម៌នោះ ឈ្មោះថា អារម្មណប្បច្ច័យ ដល់ធម៌ទាំងឡាយនោះ ព្រោះធម៌ណា មិនគប្បីដល់សេចក្ដីជាអារម្មណប្បច្ច័យ ធម៌នោះ មិនមានទេ ។

## ៣_អធិបតិប្បច្ច័យ

**អធិបតិ** មានវចនត្ថៈថា **អត្តាធីនប្បវត្តីនំ បតិភូតោ បច្ចយោ = អធិបតិប្បច្ចយោ :** បច្ច័យដែលជាធំនៃធម៌ទាំងឡាយដែលមានការប្រព្រឹត្តិទៅជាប់តាមខ្លួន ឈ្មោះថា អធិបតិប្បច្ច័យ ។

ន័យទៀតថា អធិបតីនោះផង ជាបច្ច័យផង ព្រោះហេតុនោះ ឈ្មោះថា អធិបតិប្បច្ច័យ ។

## ៤_អនន្តរប្បច្ច័យ ៥_សមនន្តរប្បច្ច័យ

**អនន្តរៈ** មានវចនត្ថៈថា **ន វិជ្ជតិ បច្ចយុប្បន្នេន សហ អន្តរំ ឯតស្ស បច្ចយស្សាតិ = អនន្តរប្បច្ចយោ :** ឈ្មោះថា **អនន្តរប្បច្ច័យ** ព្រោះអត្ថថា មិនមានរវាងចន្លោះនៃបច្ច័យនេះ ជាមួយនឹងបច្ចយុប្បន្នធម៌ ។

**សណ្ឋានាភាវេន សំ សុដ្ឋុ អនន្តរប្បច្ចយោ = សមនន្តរប្បច្ចយោ :** បច្ច័យមិនមានរវាងចន្លោះដោយល្អ ព្រោះមិនមានសណ្ឋាន ឈ្មោះថា **សមនន្តរប្បច្ច័យ** ។

ធម៌ដែលកើតមុន ៗ រលត់ទៅហើយ អាចញ៉ាំងចិត្តុប្បាទដែលសមគួរឱ្យកើតឡើងក្នុងលំដាប់នៃខ្លួន ព្រះមានព្រះភាគត្រាស់ថា អនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យ ។ ពិតមែន សេចក្ដីប្លែកគ្នានៃបច្ច័យទាំងពីរនោះ ដោយត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ តែដោយអត្ថសូម្បីពាក្យទាំង ២ ជាឈ្មោះនៃបច្ច័យដែលរលត់ទៅហើយដោយមិនមានធម៌ដទៃខ័ណ្ឌជាចន្លោះ ដូចគ្នាតែម្យ៉ាង ព្រោះសេចក្ដីផ្សេងគ្នាដោយអត្ថនៃបច្ច័យប៉ុណ្ណោះ មិនមាន ។

ចំណែកពាក្យដែលលោកអាចារ្យពួកខ្លះ ពោលថា "ឈ្មោះថា អនន្តរប្បច្ច័យ ព្រោះមិនមានរវាងចន្លោះដោយអត្ថ, ឈ្មោះថា សមនន្តរប្បច្ច័យ ព្រោះមិនមាន រវាងចន្លោះដោយកាល" ដូច្នេះ ពាក្យនោះ រមែងខុសចាកព្រះបាលីថា "**និរោធា វុដ្ឋហន្តស្ស នេវសញ្ញានាសញ្ញាយតនំ ផលសមាបត្តិយា សមនន្តរប្បច្ចយេន បច្ចយោ** : នេវសញ្ញានាសញ្ញាយតនៈនៃព្រះអរិយៈ អ្នកចេញចាកនិរោធជាបច្ច័យដល់ផលសមាបត្តិ ដោយអំណាចសមនន្តរប្បច្ច័យ" ជាដើម ។

ក៏នេវសញ្ញានាសញ្ញាយតនចិត្ត ដែលរលត់អស់ហើយ ៧ ថ្ងៃជាដើម (សត្តាហាទិកាលនិរុទ្ធំ)(១) នៅតែជាសមនន្តរប្បច្ច័យ ដល់ផលសមាបត្តិបាន ព្រោះដូច្នោះ មិនគប្បីធ្វើសេចក្តីប្រកាន់ គប្បីជឿសេចក្តីផ្សេងគ្នាក្នុងបច្ច័យទាំង ២ នេះ ដោយត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ មិនមែនផ្សេងគ្នាដោយអត្ថ ។ ពិតមែន សេចក្តីផ្សេងគ្នាត្រឹមតែព្យញ្ជនៈតែម្យ៉ាងយ៉ាងនេះថា "សេចក្តីរលត់ដោយជាធម៌ អាចក្នុងការញុំាងធម៌ដទៃឱ្យកើតឡើង ដោយមិនមានរវាងចន្លោះនៃការរលត់របស់ធម៌ដែលកើតមុន និងការកើតរបស់ធម៌ដែលកើតខាងក្រោយ ឈ្មោះថា ភាពជាអនន្តរប្បច្ច័យ, ការរលត់នៃធម៌ដែលជាធម៌អាចដើម្បីញុំាងធម៌ដទៃឱ្យកើតឡើង ដោយមិនមានរវាងចន្លោះដោយល្អ ដូចបង្អោនចូលទៅកាន់សេចក្តីតែម្យ៉ាងជា

---

១. ពាក្យថា ជាដើម អាចារ្យពួកខ្លះពោលថា ចិត្តសូម្បីរលត់ទៅក្នុងអសញ្ញីភព ៥០០ កប្ប ក៏ដោយ កាលកើតឡើង ក៏លោកហៅថា អនន្តរ-សមនន្តរប្បច្ច័យ ។

មួយទីផ្ទួន ដោយមិនមានការបែកថា ធម្មជាតិនេះនៅខាងលើ, ធម៌នេះនៅខាងក្រោម, ធម៌នេះនៅដោយជុំវិញ ដូច្នេះ ឈ្មោះថា សមនន្តរប្បច្ច័យ” ដូច្នេះ ។

ពិតមែន សេចក្តីដែលនេវសញ្ញានាសញ្ញាយតនៈជាបច្ច័យសូម្បីដល់និរោធ, និងចុតិចិត្ត ដែលមានក្នុងកាលមុនពីការកើតនៅក្នុងអសញ្ញីភព ជាធម៌អាចក្នុងការញ៉ាំងបដិសន្ធិដែលជាផល ដែលនឹងកើតសូម្បីក្នុងកាលដទៃ ក៏ឱ្យកើតដោយមិនមានរវាងចន្លោះ និងក្នុងការឱ្យកើត ដូចបង្អោនចូលទៅកាន់ភាពដូចគ្នា ព្រោះអរូបធម៌ដែលមានជាតិស្មើគ្នា មិនមានមកជ្រៀតជ្រែកត្រង់ចន្លោះ និងព្រោះរូបធម៌ដែលមានជាតិផ្សេងគ្នា មិនអាចធ្វើការជ្រៀតជ្រែក ព្រោះហេតុនោះ ភាពជាអនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យ សូម្បីនៃនេវសញ្ញានាសញ្ញាយតនៈ និងចុតិចិត្តនោះ ទើបមានបាន ។ ព្រោះដូច្នោះ សូម្បីកាលមិនមានសេចក្តីប្លែកគ្នាដោយធម៌ ក៏គប្បីជឿសេចក្តីផ្សេងគ្នា ដោយត្រឹមតែសេចក្តីប្លែកគ្នា ដោយអត្ថនៃឧបសគ្គៈ ដោយអំណាចនៃវេនេយ្យសត្វទាំងឡាយ អ្នកនឹងត្រាស់

ដឹង ដោយប្រការនោះ ៗ យ៉ាងនេះឯង ។

## ៦_សហជាតៈ ៧_អញ្ញមញ្ញប្បច្ច័យ

*សហជាតប្បច្ច័យ* មានវចនត្ថៈថា ៖

*អត្តនោ អនុប្បត្តិយា សហុប្បន្នាទម្បិ អនុប្បត្តិតោ បកាសស្ស បទីបោ វិយ សហុប្បន្នាន់ំ សហុប្បាទភាវេន បច្ចយោ* = ***សហជាតប្បច្ចយោ*** : ធម៌ដែលជាបច្ច័យដល់ធម៌ទាំងឡាយ ដែលកើតព្រមនឹងខ្លួន ដោយភាពជាធម៌ មានការកើតរួមគ្នា ដូចប្រទីបជាបច្ច័យដល់ពន្លឺ ឈ្មោះថា សហជាត-ប្បច្ច័យ ព្រោះកាលខ្លួនមិនទាន់កើត សូម្បីធម៌ទាំងឡាយ ដែលនឹងកើតរួមជាមួយនឹងខ្លួន ក៏មិនកើត ។ សហជាតធម៌នោះ បានដល់ អរូបក្ខន្ធ ៤ មហាភូតរូប ៤ និងធម៌ដែលជាវត្ថុ និងវិបាកក្នុងបដិសន្ធិខណៈ ។

*អញ្ញមញ្ញៈ* មានវចនត្ថៈថា ៖

*អញ្ញមញ្ញំ ឧបត្ថម្ភិយមានំ តិទណ្ឌំ វិយ អត្តនោ ឧបការកធម្មានំ ឧបត្ថម្ភកភាវេន បច្ចយោ* = ***អញ្ញមញ្ញប្បច្ចយោ*** : ធម៌

ដែលជាបច្ច័យដល់ធម៌ដែលឧបការៈដល់ខ្លួន ដោយភាពជាធម៌ឧបត្ថម្ភ ដូចឈើ ៣ កំណាត់ ដែលទល់ជ្រែងគ្នាទុក ឈ្មោះថា **អញ្ញមញ្ញប្បច្ច័យ ។**

បច្ច័យទាំង ២ គឺ សហជាតៈ និងអញ្ញមញ្ញៈ មានការប្លែកគ្នាយ៉ាងនេះ គឺ ភាពជាធម៌ឧបការៈដោយអំណាចនៃភាពអញ្ញមញ្ញៈប៉ុណ្ណោះ ឈ្មោះថា **ភាពជាអញ្ញមញ្ញប្បច្ច័យ** មិនមែនដោយត្រឹមតែជាធម៌ដែលកើតរួមគ្នាទេ ប្រាកដយ៉ាងនេះហើយ ធម៌ខ្លះមានប្រក្រតីជាសហជាតប្បច្ច័យតែម្យ៉ាង ទើបមិនហៅថាអញ្ញមញ្ញប្បច្ច័យ ព្រោះនាមដែលមានប្រក្រតីជាសហជាតប្បច្ច័យដល់ចិត្តជរូប និងមហាភូតរូប ដែលមានប្រក្រតីជាសហជាតប្បច្ច័យដល់ឧបាទាយរូប លោកមិនបានលើកឡើងជាអញ្ញមញ្ញប្បច្ច័យ, ពិតមែន បើសិនថា ភាពជាធម៌ឧបការៈដល់ធម៌ទាំងឡាយ ដែលឧបការៈដល់ខ្លួន ដោយសហជាតតែម្យ៉ាង នឹងគប្បីជាអញ្ញមញ្ញប្បច្ច័យបានមែននោះ ក្នុងកាលនោះ សហជាតប្បច្ច័យ និងអញ្ញមញ្ញប្បច្ច័យ ក៏នឹងគប្បីជាបច្ច័យដូចគ្នា ដូច្នេះឯង ។

## ៨_និស្សយៈ ៩_ឧបនិស្សយប្បច្ច័យ

និស្សយ មានវចនត្ថៈថា ៖

**ចិត្តកម្មស្ស បដោ វិយ សហជាតនាមរូបានំ និស្សយភូតា ចតុក្ខន្ធា តរុបព្វតាទីនំ បឋវី វិយ អាធារា ការតោយេវ សហជាតរូបសត្តវិញ្ញាណធាតូនំ យថាក្កមំ និស្សយា ភូតរូបំ វត្ថុ ចាតិ = ឥមេ និស្សយប្បច្ចយោ នាម :** ធម៌ទាំងនេះ គឺ នាមក្ខន្ធ៤[១] ជាទីអាស្រ័យដល់នាមរូបដែលកើតរួមគ្នា ដូចផ្ទាំងសំពត់ជាទីទទួលរងភាពចិត្រកម្ម, ភូតរូប និងវត្ថុជាទីអាស្រ័យរបស់រូបដែលកើតរួមគ្នា, និងវិញ្ញាណធាតុ ៧ តាមលំដាប់ដោយអាការ គឺ ភាពជាទីទទួលរងនោះឯង ដូចផែនដីជាទីអាស្រ័យទទួលរងដើមឈើ និងភ្នំជាដើម ឈ្មោះថា និស្សយប្បច្ច័យ ព្រោះធ្វើអធិប្បាយថា

---

១. នាមរូប រមែងកើតព្រោះនាមជាបច្ច័យ ភូតរូបជាទីអាស្រ័យនៃវត្ថុ ៦, វត្ថុ ៦ ជាទីអាស្រ័យនៃ វិញ្ញាណធាតុ ៧, ក្នុងចតុវោការភូមិ មិនមានរូប, ក្នុងឯកវោការភូមិ មិនមាននាម ។

អ្នកត្រូវអាស្រ័យពឹងផ្អែកនូវធម៌ទាំងឡាយ ។

ក្នុងអភិធម្មត្ថវិភាវិនី ពោលថា **និស្សយតីតិ = និស្សយោ** : បច្ច័យណា ត្រូវធម៌ទាំងឡាយ គប្បីពឹងផ្អែក ព្រោះហេតុនោះ បច្ច័យនោះ ឈ្មោះថា **និស្សយៈ** ។

**ឧបនិស្សយ** មានវចនត្ថៈថា **ពលវភាវេន និស្សយោ បច្ចយោ = ឧបនិស្សយប្បច្ចយោ** : បច្ច័យជាទីអាស្រ័យដោយភាពជាបច្ច័យ មានកម្លាំងខ្លាំង ឈ្មោះថា ឧបនិស្សយប្បច្ច័យ ( ឧប ស័ព្ទ បំភ្លឺដល់សេចក្តីឱ្យរឹងរឹតតែល្អ នឹងពោលខាងមុខ ) ។

## ១០_បុរេជាតៈ ១១_បច្ឆាជាតប្បច្ច័យ

**បុរេជាត** មានវចនត្ថៈថា **ឆ វត្ថូនិ ឆាលម្ពនានិ ចាតិ ឥមេ បច្ចុប្បន្នភោ បឋមំ ឧបជ្ជិត្វា បវត្តមានភាវេន ឧបការកា = បុរេជាតប្បច្ចយោ** : ធម៌ទាំងនេះ គឺ វត្ថុ៦ និងអារម្មណ៍ ៦ ជាធម៌ ឧបការៈដោយភាពជាធម៌កើតឡើង ហើយប្រព្រឹត្តទៅមុន

បច្ចយុប្បន្នធម៌ ឈ្មោះថា **បុរេជាតប្បច្ច័យ ។**

**បច្ឆាជាត** មានវចនត្ថៈថា **បច្ឆាជាតបច្ចយេ អសតិ សន្តាន ដ្ឋិតិ ហេតុភាវំ អគច្ឆន្តស្ស កាយស្ស ឧបត្ថម្ភនភាវេន ឧបការកា បច្ឆាជាតាចិត្តចេតសិកា ធម្មា = បច្ឆាជាតប្បច្ចយោ :** កាលមិន មានបច្ឆាជាតប្បច្ច័យ ធម៌ទាំងឡាយ គឺ ចិត្ត និងចេតសិក ដែល កើតខាងក្រោយ ជាធម៌ឧបការៈ ដោយជាការឧបត្ថម្ភដល់កាយ ដែលមិនទាន់ដល់ភាពជាហេតុនៃការតាំងនៅរបស់ការបន្ត ឈ្មោះថា បច្ឆាជាតប្បច្ច័យ ។

ម្យ៉ាងទៀតថា **បច្ឆាជាតោ បច្ចយោ = បច្ឆាជាតប្បច្ចយោ** បច្ច័យធម៌ដែលកើតខាងក្រោយ ឈ្មោះថា បច្ឆាជាតប្បច្ច័យ ។

បច្ឆាជាតប្បច្ច័យនោះ បណ្ឌិតគប្បីឃើញដូចចេតនា មាន ការប្រាថ្នាហែង ក្នុងអាហារជាបច្ច័យ ដល់សរីរៈរបស់កូនសត្វត្មាត ទាំងឡាយ ដូច្នោះ ។

## ១២_អាសេវនប្បច្ច័យ

**អាសេវន** មានវចនត្ថៈថា **បុរិមបរិចិតគន្ថោ វិយ ឧត្តរុត្តរស្ស គន្ថស្ស កុសលាទិភាវេន អត្តសទិសស្ស បគុណពលភាវវិសិដ្ឋ អត្តសជាតិយតាគហណំ = អាសេវនំ** : ការប្រកាន់ធម៌ (ជាអារម្មណ៍) ដូចគ្នានឹងខ្លួន ដោយភាពជាកុសលជាដើម ដោយភាពជាធម៌ មានជាតិស្មើគ្នានឹងខ្លួន ដល់ការសម្រេចពិសេសហើយ ដោយជាធម៌ជុំទាញនិងមានកម្លាំង ដូចគម្ពីរដែលខ្លួនបងចាំទុកក្នុងកាលមុន ជាបច្ច័យដល់ការស្វាធ្យាយ ក្នុងកាលខាងក្រោយតៗមក ដូច្នោះ ឈ្មោះថា **អាសេវនប្បច្ច័យ** ។ ធម៌ទាំងឡាយ ដែលមានជាតិស្មើគ្នានោះឯង ជាបច្ច័យដល់ធម៌ទាំងឡាយ ដែលមានជាតិស្មើគ្នា ដោយការសេពគប់នោះ ឈ្មោះថា អាសេវនប្បច្ច័យ ។

ពិតមែន ធម៌ដែលមានជាតិផ្សេងគ្នា រមែងមិនអាចញ៉ាំងធម៌ដែលមានជាតិផ្សេងគ្នា ឱ្យកាន់យកគតិ ពោលគឺ ភាពជាកុសលជាដើម ដែលសម្រេចពិសេសហើយ ដោយភាពជាធម៌មាន

កម្លាំងស្ទាត់ជំនាញរបស់ខ្លួន ដោយគុណ គឺ ការសេពគប់ទាំងខ្លួនឯង ក៏មិនកាន់យកគតិចាកពីធម៌មាន ជាតិផ្សេងគ្នានោះ ។

បណ្ឌិតគប្បីជ្រាបថា "ក៏អាសេវនប្បច្ច័យធម៌នោះ ជាកុសលនិងអកុសលដែលជាលោកិយ និងជាកិរិយាជវន តែមិនមានទោសកំហុស ដែលកន្លងទៅមិនមានចន្លោះ" ដូច្នេះ ។

## ១៣_កម្មប្បច្ច័យ ១៤_វិបាកប្បច្ច័យ

កម្ម មានវចនត្ថៈថា **ចិត្តប្បយោគសង្ខាតក្រិយាភាវេន សហជាតានំ នានក្ខណិកានញ្ច ឧបការិកា ចេតនា = កម្មប្បច្ចយោ** ចេតនាដែលឧបការៈដល់បច្ចយុប្បន្នធម៌ដែលកើតរួមគ្នា និងឧបការៈដល់បច្ចយុប្បន្នធម៌ដែលកើតខណៈផ្សេងគ្នា ដោយភាពជាការធ្វើ ពោលគឺ សេចក្តីខ្វល់ខ្វាយនៃចិត្ត ឈ្មោះថា **កម្មប្បច្ច័យ** ។

កម្មប្បច្ច័យមាន ២ យ៉ាង គឺ សហជាតកម្មប្បច្ច័យ និង

នានាខណិកកម្មប្បច្ច័យ, បណ្តា ២ យ៉ាងនោះ កម្មជាបច្ច័យកើតព្រមនឹងធម៌ដែលជាបច្ចយុប្បន្ន ហៅថា សហជាតកម្មប្បច្ច័យ ចំណែកកម្មដែលជាកុសល និងអកុសលដែលរលត់ទៅជាបច្ច័យឱ្យកើតវិបាកនាមក្ខន្ធ ៤ និងកដត្តារូបដែលមានខណៈផ្សេងគ្នា ហៅថា នានក្ខណិកកម្មប្បច្ច័យ ។

**វិបាក** មានវចនត្ថៈថា **អត្តនោ និរុស្សាហសន្តភាវេន សហជាតនាមរូបានំ និរុស្សាហសន្តភាវាយ ឧបការកា វិបាកចិត្តចេតសិកា = វិបាកប្បច្ចយោ :** ចិត្ត និងចេតសិកដែលជាវិបាកជាធម៌ឧបការៈដល់នាមរូបដែលកើតរួមគ្នា ដោយភាពដែលខ្លួន ជាធម៌ស្ងប់ចំពោះភាពជាធម៌ស្ងប់គ្មានឧស្សាហ៍ (ជាមួយគ្នា) ទើបឈ្មោះថា វិបាកប្បច្ច័យ ។ (បច្ច័យក៏ស្ងប់ បច្ចយុប្បន្នក៏ស្ងប់) ។

ពិតមែន វិបាកមានភវង្គចិត្តជាដើម ជាវត្ថុដែលដឹងបានដោយលំបាក ព្រោះជាសេចក្តីស្ងប់នៃសន្តានដែលគ្មានបច្ច័យនោះឯង ព្រោះត្រឹមតែជាសេចក្តីសម្រេចបាកពីកម្មដែលសត្វធ្វើទុក

ព្រោះភាពជាវិបាកទាំងនោះ ដែលសត្វទាំងឡាយ មិនគប្បីឱ្យសម្រេចដោយការព្យាយាម ។

ក៏វិបាកចិត្តទាំងឡាយ ត្រឹមតែការធ្លាក់ទៅក្នុងអារម្មណ៍ មានរូបារម្មណ៍ជាដើម, សម្បដិច្ឆន្នៈ (ការទទួល) សន្តីរណៈ (ការពិចារណា) ជារបស់ដឹងបានដោយលំបាកតែម្តង ។ សេចក្តីដែលបញ្ចវិញ្ញាណ សម្បដិច្ឆន្នចិត្ត សន្តីរណចិត្តទាំងនេះ ទទួលអារម្មណ៍ មានរូបជាដើម បណ្ឌិតរមែងដឹងបានដោយការប្រព្រឹត្តិទៅនៃជវនៃប៉ុណ្ណោះ ដូច្នេះឯង ។

## ១៥-អាហារប្បច្ច័យ

**អាហារ** មានវចនត្ថៈថា **រូបារូបានំ ឧប្បត្ថម្ភកត្តេន ឧបការកា ចត្តារោ អាហារា = អាហារប្បច្ចយោ :** អាហារ ៤ ឧបការៈដល់រូបនិងអរូប ដោយភាពជាគ្រឿងឧបត្ថម្ភ ឈ្មោះថាអាហារប្បច្ច័យ ។

ពិតមែន សូម្បីកាលមានកម្មតាក់តែងឱ្យកើតអាហារជាគ្រឿងជួយឧបត្ថម្ភនោះឯង ដែលជាកិច្ចសំខាន់របស់អាហារ ។ សូម្បីអាហារកាលឱ្យកើតឡើង ក៏ជួយឧបត្ថម្ភ ដោយអំណាចនៃការបន្ត មិនដាច់ខ្សែឱ្យកើតឡើង ព្រោះដូច្នោះ គ្រឿងជួយឧបត្ថម្ភនោះ ឈ្មោះថា **អាហារ ។**

## ១៦-ឥន្ទ្រិយប្បច្ច័យ

*ឥន្ទ្រិយ* មានវចនត្ថៈថា ***តេសុ តេសុ កិច្ចេសុ បច្ចយុប្បន្នធម្មេហិ អត្តានំ អនុវត្តាបនសង្ខាតអធិបច្ចត្ថេន បច្ចយោ = ឥន្ទ្រិយប្បច្ចយោ*** : ធម៌ឈ្មោះថា បច្ច័យ ព្រោះអត្ថ គឺ ភាពជាធំពោលគឺ ការញ៉ាំងបច្ចយុប្បន្នធម៌ទាំងឡាយ ឱ្យស្របតាមខ្លួន ក្នុងកិច្ចនោះ ឈ្មោះថា ឥន្ទ្រិយប្បច្ច័យ ។

## ១៧_ឈានប្បច្ច័យ

*ឈាន* មានវចនត្ថៈថា ***អាលម្ពនូបនិជ្ឈានលក្ខណូប និសជ្ឈានវសេន ឧបគន្ត្វា អាលម្ពនំ និជ្ឈានកា វិតក្កាទយោ = ឈានបច្ចយោ*** : *ធម៌ទាំងឡាយមានវិតក្កៈជាដើម ដែលចូលទៅ សម្លឹងអារម្មណ៍ ដោយអំណាចអារម្មណូបនិជ្ឈាន និងលក្ខណូប និជ្ឈាន ឈ្មោះថា ឈានប្បច្ច័យ ។*

## ១៨_មគ្គប្បច្ច័យ

*មគ្គ* មានវចនត្ថៈថា ***សុគតិតោ ទុគ្គតិតោ បុញ្ញតោ បាបតោ វា និយ្យានត្ថេន ឧបការកា សម្មាទិដ្ឋាទយោ = មគ្គប្បច្ចយោ*** : *ធម៌មាន សម្មាទិដ្ឋិជាដើម ឈ្មោះថា ឧបការៈ ព្រោះអត្ថថា ជាហេតុនាំចេញចាកសុគតិ ឬទុគ្គតិ ចាកបុណ្យ ឬ បាប ឈ្មោះថា* ***មគ្គប្បច្ច័យ*** *។*

## ១៩-សម្បយុត្ត ២០-វិប្បយុត្តប្បច្ច័យ

**សម្បយុត្ត** មានវចនត្ថៈថា **បរមត្ថតោ ភិន្នាបិ ឯកីភាវំ គតា វិយ ឯកុប្បាទាទិសង្ខាត សម្បយោគលក្ខណេន ឧបការកា នាម ធម្មា = សម្បយុត្តប្បច្ចយោ** : នាមធម៌ទាំងឡាយនោះឯង សូម្បីផ្សេងគ្នាដោយបរមត្ថ ក៏ដូចជាដល់សភាពដូចគ្នាតែម៉្យាង ជាធម៌ឧបការៈដោយលក្ខណៈនៃសម្បយោគៈ ពោលគឺ មានការកើតឡើងជាមួយគ្នាជាដើម ឈ្មោះថា សម្បយុត្តប្បច្ច័យ ។

### សម្បយោគលក្ខណៈមាន ៤ គឺ

១- **ឯកុប្បាទ** កើតព្រមគ្នា

៣- **ឯកាលម្ពន** មានអារម្មណ៍ជាមួយគ្នា

២- **ឯកនិរោធ** រលត់ព្រមគ្នា

៤- **ឯកវត្ថុក** មានវត្ថុជាមួយគ្នា

**វិប្បយុត្ត** មានវចនត្ថៈថា **អញ្ញមញ្ញសម្ពន្ធតាយ យុត្តាបិ សមានា វិប្បយុត្តភាវេន វិសំសដ្ឋតាយ នានត្តុបគមនេន ឧបការកា វត្ថុចិត្តចេតសិកា = វិប្បយុត្តប្បច្ចយោ** : វត្ថុរូប ចិត្ត និង

ចេតសិក ទោះបីជាធម៌ប្រកបជាមួយគ្នា ដោយសភាព ជាធម៌ទាក់ទងនូវគ្នានិងគ្នា ក៏ជាធម៌ឧបការៈដោយការចូលដល់ផ្សេងគ្នា ដោយសភាពជាធម៌មិនប្រឡំគ្នា ព្រោះភាពជាវិប្បយុត្តគ្នា ឈ្មោះថា វិប្បយុត្តប្បច្ច័យ ។ វិប្បយុត្តប្បច្ច័យ បានដល់ នាមនិងរូប មិនប្រកបដោយលក្ខណៈទាំង ៤ តាមដែលពោលទុកនៅក្នុងសម្បយុត្តប្បច្ច័យ ។ ក្នុងបដិសន្ធិ រូប និងនាម កើតព្រមគ្នា ក្នុងបវត្តិកាល ចិត្តជរូបកើតព្រមគ្នា និងចិត្តតែមិនបានគ្រប់លក្ខណៈទាំង ៤ តាមដែលពោលហើយ ។

## វិប្បយុត្តៈ មាន ២ គឺ

១- ***អភាវវិប្បយុត្តំ*** គឺ វិប្បយុត្ត ព្រោះការមិនមាន ដូចជា “***ទិដ្ឋិគតវិប្បយុត្តំ***” ប្រែថា ចិត្តមិនប្រកបដោយការឃើញខុស “***ញាណវិប្បយុត្តំ***” ចិត្តមិនប្រកបដោយញាណ ។

២- ***វិសំសដ្ឋវិប្បយុត្តំ*** គឺ វិប្បយុត្ត ព្រោះជាធម៌មិនប្រឡូកប្រឡំគ្នា ដូចក្នុងវិប្បយុត្តប្បច្ច័យនេះ ។

## ២១- អត្ថិប្បច្ច័យ ២២- នត្ថិប្បច្ច័យ

*អត្ថិ មានវចនត្ថៈថា* ***បច្ចុប្បន្នសភាវេន អត្ថិភាវេន តាទិសស្សេវ ធម្មស្សុបត្ថម្ភកត្តេន ឧបការកា សហជាតំ បុរេជាតន្តិ អាទិនា វុត្តមានធម្មា អត្ថិប្បច្ចយោ*** *: ធម៌ដែលលោកអាចារ្យពោលទុក ដោយពាក្យថា* ***សហជាតំ*** *( កើតព្រមគ្នា )* ***បុរេជាតំ*** *( កើតមុន )ជាដើម ឈ្មោះថា ជាធម៌ឧបការៈ ព្រោះជាការឧបត្ថម្ភដល់ធម៌ដូច្នោះឯង ដោយសភាពជាធម៌មាន ដែលមានសភាពជាបច្ចុប្បន្ន ឈ្មោះថា អត្ថិប្បច្ច័យ ។*

*សូម្បីពេលកម្មឱ្យអ្នកកើតមាន សេចក្តីខ្វល់ខ្វាយនៃអត្ថិប្បច្ច័យ ក្នុងឋិតិខណៈប៉ុណ្ណោះ ជាសេចក្តីល្អក្រៃលែង ព្រោះដូច្នោះ ភាពដែលជាអត្ថិប្បច្ច័យទាំងនោះ ជាធម៌ជួយគាំទ្រទុក ទើបលោកកាន់យកដោយពាក្យថា* ***សហជាតំ*** *( កើតព្រមគ្នា )ជាដើម ។ ពាក្យថា* ***សហជាតំ*** *សំដៅដល់ នាមរូបដែលកើតព្រមគ្នាក្នុងបដិសន្ធិកាល ចំណែកពាក្យថា* ***បុរេជាតំ*** *សំដៅយករូបដែលកើតមុន ក្នុងបវត្តិកាល ព្រោះរូបកើតនៅមាន ទើប*

ជាបច្ច័យ ។

នត្ថិ មានវចនត្ថៈថា **ឯកស្មឹ ផស្សាទិសមុទាយេ បវត្តមានេ ទុតិយស្ស អភាវតោ អត្ថនោ បតិយា ឱកាសមលភន្តានំ អនន្តរំ ឧប្បជ្ជមានកចិត្តចេតសិកានំ ឱកាសទានវសេន ឧបការកា អនន្តរនិរុទ្ធា ចិត្តចេតសិកា = នត្ថិប្បច្ចយោ :** ចិត្ត និងចេតសិកដែលរលត់ទៅ មិនមានរវាងចន្លោះ ជាធម៌ឧបការៈដោយអំណាចនៃការឱ្យឱកាសដល់ចិត្ត និងចេតសិកដែលនឹងកើតឡើង ក្នុងលំដាប់ជាប់គ្នា ដែលមិនមានឱកាសដើម្បីការតាំងនៅរបស់ខ្លួន ព្រោះកាលពួកធម៌មានផស្សៈជាដើម ពួកមួយមិនទាន់ប្រព្រឹត្តទៅ ពួកធម៌ទី ២ មានផស្សៈជាដើម ក៏មិនមាន ឈ្មោះថា នត្ថិប្បច្ច័យ ។

## ២៣_វិគត ២៤_អវិគតប្បច្ច័យ

*វិគត* មានវចនត្ថៈថា **អត្តនោ សភាវវិគមេន អប្បវត្ត-មានធំ វិគតភាវេន ឧបការកាយេវ ធម្មា = វិគតប្បច្ចយោ :** ធម៌ទាំងឡាយ ដែលឧបការៈដល់ធម៌ទាំងឡាយនុ៎ះឯង ដែលប្រព្រឹត្តទៅមិនទាន់បាន ដោយសភាពរបស់ខ្លួន នៅមិនទាន់អស់ទៅដោយជាភាវៈដែលប្រាសទៅហើយ ឈ្មោះថា វិគតប្បច្ច័យ ។

**អវិគត** មានវចនត្ថៈថា **និរោធានុបគមនវសេន ឧបការកាអត្ថិបច្ចយាវ = អវិគតប្បច្ចយោ :** អត្ថិប្បច្ច័យនោះឯង ជាឧបការៈ ដោយអំណាចនៃការនៅមិនទាន់ចូលដល់ការរលត់ ឈ្មោះថា **អវិគតប្បច្ច័យ ។**

សូម្បីកាលមិនមានការប្លែកគ្នានៃអត្ថិប្បច្ច័យ ជាមួយនឹងអវិគតប្បច្ច័យទាំងពីរនោះ បណ្ឌិតគប្បីជ្រាបសេចក្តីជាបច្ច័យដែលផ្សេងគ្នា យ៉ាងនេះគឺ "ភាពជាធម៌ដែលមានឧបការៈដោយត្រឹមតែការនៅមានប្រាកដ ឈ្មោះថា អត្ថិប្បច្ច័យ ភាពជាធម៌ដែលឧបការៈដោយអំណាចនៃការនៅមិនចូលដល់ការរលត់ ឈ្មោះថា

អវិគតប្បច្ច័យ" ។

ពិតមែន បណ្ឌិតជឿក្នុងព្រះមានព្រះភាគថា "ព្រះមានព្រះភាគ ទ្រង់ជ្រាបអំណាចពិសេសនៃធម៌ទាំងឡាយ គ្រប់យ៉ាង ទើបទ្រង់សម្តែងបច្ច័យ ២៤ ទុកៈ" ដូច្នេះ ។

គួរធ្វើសុតមយញ្ញាណឱ្យកើតឡើងថា "ធម៌ទាំងនេះ មានសេចក្តីពិសេសយ៉ាងនេះ" ហើយគួរធ្វើសេចក្តីព្យាយាម ដើម្បីការត្រាស់ដឹងវិសេសនៃបច្ច័យទាំងនោះ ដោយចិន្តាមយញ្ញាណ និងភាវនាមយញ្ញាណ ។ ក្នុងសេចក្តីនេះ បណ្ឌិតគប្បីសន្និដ្ឋានថា សូម្បីសេចក្តីនៃធម៌អាចមិនប្លែកគ្នា ក៏ពិតមែន តែបច្ច័យដែលត្រាស់ទុកក្នុងកាលមុន ព្រះអង្គក៏ត្រាស់ដដែលទៀតដោយប្រការដទៃ ដោយអំណាចនៃបុគ្គលដែលគួរទូន្មានបាន ដោយប្រការនោះ. ដូចដែលទ្រង់ត្រាស់អហេតុកទុកៈទុកហើយ ក៏ទ្រង់ត្រាស់ហេតុវិប្បយុត្តទុកៈទៀត ដូច្នោះ ។

## អធិប្បាយ សង្គហគាថាទី ៥_៦

បច្ច័យទាំងឡាយ តាំងនៅដោយអាការ ៦ យ៉ាង គឺ ៖

១_ នាម បានដល់ នាមក្ខន្ធ ៤ ជាបច្ច័យដល់នាម ដូច្នោះទុំះឯង ដោយចំណែក ៦ គឺ ដោយអាការ ៦ យ៉ាង ។

២_ នាមទុំះឯង ជាបច្ច័យដល់នាមធម៌ និងរូបធម៌ ដែលកើតប្រព្រឹត្តទៅរួមគ្នា ដោយចំណែក ៥ ។

៣_ នាមទុំះឯង ជាបច្ច័យដល់រូបដែលផ្សេងដោយភូតរូប និងឧបាទាយរូបទៀត ដោយចំណែកតែមួយ ។

៤_ ចំណែករូបជាបច្ច័យដល់នាមត្រឹមតែម្យ៉ាង ។

៥_ បញ្ញត្តិ និងនាមរូបជាបច្ច័យដល់នាម ដោយចំណែក ២ គឺ ២ ប្រការ ។

៦_ មួយទៀត ទាំង ២ យ៉ាង គឺ នាមរូបទាំង ២ ដែលប្រព្រឹត្តទៅរួមគ្នា ជាបច្ច័យដល់នាមរូបទាំង ២ ដូច្នោះទុំះឯង ដោយអាការ ៩ យ៉ាង ។

បច្ច័យទាំងឡាយ តាំងនៅដោយអាការ ៦ យ៉ាង ដោយ

ប្រការ ដូច្នេះ ។

## វិនិច្ឆ័យជវ័នដល់ភាពជាអាសេវនបច្ច័យ

អព្យាកតវិបាក ដល់ភាពជាវិបាក ដោយអំណាចនៃកម្ម ត្រូវកម្លាំងនៃកម្មបន្សាត់ទៅ ប្រព្រឹត្តទៅប្រៀបដូចធ្លាក់ចុះទៅហើយ តោងសភាវៈរបស់ខ្លួនទុកឱ្យបម្រើន មិនឱ្យវិបាកដទៃប្រព្រឹត្តទៅ និងមិនតោងអានុភាពនៃវិបាកដើមកើតឡើង, ក៏នៅក្នុងអហេតុកកិរិយាចិត្តទាំងឡាយ អាវជ្ជនចិត្តទាំង ២ រមែងមិនជាអាសេវនប្បច្ច័យ ព្រោះលើកហសិតុប្បាទចិត្តតែម្យ៉ាងឡើងជាអាសេវនប្បច្ច័យ បានដោយព្រះបាលីថា "ក្នុងអាសេវនៈ ព្រោះភាវៈនៃធម៌ មិនមែនមគ្គប្បច្ច័យ ទើបមានបញ្ហាព្យាករណ៍មួយ" ដូច្នេះ ព្រោះដូច្នោះ ជវ័នទាំងឡាយ ទើបដល់ភាពជាអាសេវនប្បច្ច័យ លោកអាចារ្យសន្និដ្ឋានទុកដូច្នេះ ទើបពោលពាក្យថា **"បុរិមានិជវនានិ"**ជាដើម ។ ក៏កាលមានពាក្យមិនប្លែកនេះ បណ្ឌិតគប្បីឃើញ កុសលជវ័ន អកុសលជវ័ន និងអព្យាកតជវ័នចំពោះ

លោកិយៈប៉ុណ្ណោះ ព្រោះលោកមិនលើកយកលោកុត្តរជវនៈនេះ ជាអាសេវនប្បច្ច័យ មកធ្វើអត្ថាធិប្បាយទុកយ៉ាងនេះ ក្នុងអដ្ឋកថាបដ្ឋាន ទើបពោលថា "លោកុត្តរជវន ឈ្មោះថា អាសេវនប្បច្ច័យមិនមាន" ដូច្នេះ ។

ពិតហើយ បណ្ដាលោកុត្តរកុសលនោះ លោកុត្តរកុសលមិនអាចញុំាង ផលចិត្តនោះឱ្យកាន់យកគុណ គឺ អាសេវនៈ ព្រោះខ្លួនជាជវនទៅក្នុងខាងមុខនៃផលចិត្ត ដែលមានជាតិផ្សេងគ្នា ក៏ផលចិត្ត សូម្បីកើតឡើងដោយអំណាចនៃជវន ក៏មិនកាន់យកអាសេវនៈ ដោយន័យដែលពោលហើយ ក្នុងអព្យាកតវិបាក និងមិនញុំាងវិបាកដទៃឱ្យកាន់យកអាសេវនៈ ។

សូម្បីពាក្យដែលលោកអាចារ្យធម្មបាលត្ថេរ ពោលទុកថា "ជវនដែលនឹងផុតទៅចាកពីអាសេវនៈ មិនមាន" ដូច្នេះ សូម្បីពាក្យនោះ ក៏ត្រូវយល់ថា លោកពោលទុកដោយអំណាចវោហារជាចំណែកច្រើន ។ ដោយប្រការក្រៅពីនេះ ក៏គប្បីជាប់ទាក់ទងដល់សេចក្ដី ដែលលោកអាចារ្យពោលដោយមិនទាន់ពិចារណា

( ពិនិត្យមើល )សេចក្ដីឱ្យបានល្អ ។

តែពាក្យថា "មគ្គមិនកាន់យកអាសេវនៈអំពីគោត្រភូ" ដូច្នេះ មិនមាន ព្រោះមិនប្រាថ្នាយកសេចក្ដីដែលធម៌ មានជាតិផ្សេងគ្នា ដោយអំណាចនៃភូមិជាដើម ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងបករណបដ្ឋានថា "**គោត្រភុ មគ្គស្ស, វោទានំ មគ្គស្ស អាសេវនប្បច្ចយេន បច្ចយោ** : គោត្រភូ ( ជាបច្ច័យ )នៃមគ្គ, វោទានៈជាបច្ច័យនៃមគ្គ ដោយអាសេវនប្បច្ច័យ"[១] ដូច្នេះ ។

## អធិប្បាយ ភពជាបច្ច័យរបស់នាមរូប

សេចក្ដីដែលរូបធម៌ទាំងឡាយ សូម្បីកើតឡើងព្រមគ្នា ក៏មិនឈ្មោះថា សម្បយុត្តប្បច្ច័យ ព្រោះមិនមានលក្ខណៈនៃសម្បយោគៈ ៤ មានឯកុប្បាទៈជាដើម លោកអាចារ្យធ្វើទុកក្នុងចិត្ត ដូច្នេះ ទើបពោលពាក្យថា "ធម៌ទាំងឡាយ គឺ ចិត្តនិងចេតសិក

---

១. អភិ. បដ្ឋា. កុសលត្តិកៈ. ៩៤. ៥៦២/២៧៥ ។

ដែលកើតព្រមគ្នា ជាបច្ច័យដល់គ្នា ដោយអំណាចនៃសម្បយុត្តប្បច្ច័យ” ដូច្នេះ ។

បទថា **“ហេតុជ្ឈានង្គមគ្គង្គានិ សហជាតានំ នាមរូបានំ”** អធិប្បាយថា ហេតុ, អង្គឈាន, និងអង្គមគ្គ, ទាំង ៣ នេះ រមែងជាបច្ច័យដល់រូបដែលមានកម្មជាសមុដ្ឋានក្នុងបដិសន្ធិកាល និងមានចិត្តជាសមុដ្ឋានក្នុងបវត្តិកាល និងដល់នាមដែលកើតព្រមគ្នាក្នុងបដិសន្ធិកាល និងបវត្តិកាលទាំង ២ ដោយបច្ច័យ មានហេតុប្បច្ច័យជាដើម ។ ពិតមែន លោកអាចារ្យពោលថា ក្នុងពាក្យទាំងពួងដែលថា សហជាតរូប ដូច្នេះ បណ្ឌិតគប្បីជ្រាបថា រូបមានកម្មជាសមុដ្ឋាន ក្នុងបដិសន្ធិកាល និងមានចិត្តជាសមុដ្ឋានក្នុងបវត្តិកាល ។ ពាក្យថា **“សជាតា ចេតនា”** បានដល់ ចេតនាដែលកើតព្រមគ្នា ដោយហោចទៅសូម្បីចក្ខុវិញ្ញាណជាដើម ។ ក្នុងពាក្យថា **សហជាតានំ នាមរូបានំ** បានដល់ ចេតនាទាំងអស់រមែងជាបច្ច័យដល់នាម ចេតនាដែលសហគតដោយបដិសន្ធិរមែងជាបច្ច័យដល់រូបដែលមានកម្មជាសមុដ្ឋាន និងចេតនាដែល

សហគតដោយចិត្តដែលញ៉ាំងរូបឱ្យកើតក្នុងបវត្តិកាល ជាបច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋាន ។ ពាក្យថា **"នានក្ខណិកា ចេតនា"** បានដល់ កុសលចេតនា និងអកុសលចេតនា ដែលកើតឡើងក្នុងភពទាំងឡាយ មានអតីតភពជាដើម ក្នុងខណៈផ្សេងគ្នាពីខណៈវិបាក ។ ពាក្យថា **នាមរូបានំ** បានដល់ ចេតនាកើតខណៈផ្សេងគ្នា រមែងជាបច្ច័យដល់នាមរូប ក្នុងបដិសន្ធិកាល និងបវត្តិកាលទាំង ២ ។ ពាក្យថា "វិបាកក្ខន្ធា" បានដល់ អរូបក្ខន្ធដែលជាវិបាក មានបដិសន្ធិវិញ្ញាណជាដើម ។ ពិតមែន សូម្បីរូបមានកម្មជាសមុដ្ឋាន ក៏មិនមានវោហារថា វិបាក ព្រោះសព្ទថា វិបាក និយមប្រើចំពោះក្នុងអរូបធម៌ទាំងឡាយ ដូចគ្នានឹងកម្មនុ៎ះឯងដោយភាពជាអរូបធម៌ និងជាធម៌មានអារម្មណ៍ប៉ុណ្ណោះ ។

ពាក្យថា **"បុរេជាតស្ស ឥមស្ស កាយស្ស"** សេចក្តីថា នាមជាបច្ច័យដល់រូបកាយនេះ ដែលកើតឡើងមុនអំពីធម៌ដែលជាបច្ច័យ ។

សួរថា ក៏កាលបច្ចយុប្បន្នធម៌ មានការកើតឡើងមុន ធម៌

ដែលកើតខាងក្រោយជាបច្ច័យ តើនឹងមានដូចម្ដេច ?

ឆ្លើយថា ខ្ញុំបានពោលទុកហើយ មិនមែនឬថា កាលមិនមានបច្ឆាជាតធម៌ (គឺ ចិត្តនិងចេតសិក) ជាបច្ច័យជួយឧបត្ថម្ភដល់រូបកាយ ដែលមិនទាន់ដល់ភាពជាហេតុនៃសេចក្ដីតាំងនៅរបស់សន្ដាន (គឺ ឧបត្ថម្ភឱ្យរូបតាំងនៅរហូតដល់គ្រប់អាយុ) ព្រោះដូច្នោះ បច្ឆាជាតប្បច្ច័យនេះ ទើបធ្វើការជួយក្នុងការឧបត្ថម្ភ ដោយភាពជាហេតុនៃការប្រព្រឹត្តិទៅក្នុងសន្ដាន ព្រោះដូច្នោះ ទើបមិនមានសេចក្ដីខុសប្លែកអ្វីទេ ។

រូបជាបច្ច័យដល់នាម ដែលលោកអាចារ្យពោលថា "**ឆ វត្ថូនិ បវត្តិយំ**" ដូច្នេះទុក ក៏ព្រោះវត្ថុមានចក្ខុជាដើម មិនទាន់កើតក្នុងបដិសន្ធិកាល និងព្រោះកាលមានការកើត ក៏មិនទាន់ចូលដល់ភាពជាបច្ច័យដល់វិញ្ញាណនោះ. និងព្រោះហទយវត្ថុ ដែលកើតព្រមនឹងបដិសន្ធិវិញ្ញាណជាវត្ថុដែលកើតមុនមិនមាន ។ ក៏ពាក្យថា "អារម្មណ៍ ៥ ជាបច្ច័យដល់បញ្ចវិញ្ញាណវិថី" នេះ លោកអាចារ្យពោលសំដៅយកន័យដែលមានហើយ ក្នុងអារម្មណបុរេជាត

និទ្ទេស ។

## បញ្ញត្តិ នាមរូប ជាបច្ច័យដល់នាម ២ យ៉ាង

សុប្បីធម្មារម្មណ៍ដែលជាអារម្មណ៍កើតមុនជាបច្ច័យ ដែលបណ្ឌិតរមែងបានក្នុងមនោវិញ្ញាណវិថី ព្រោះសុប្បវត្ថុ មានចក្ខុដែលជាបច្ចុប្បន្នជាដើម លោកក៏កាន់យកក្នុងបញ្ហាវារៈដោយមិនប្លែកគ្នា ដោយន័យជាដើមថា "ព្រះសេក្ខៈឬបុថុជ្ជន រមែងឃើញច្បាស់នូវចក្ខុ ដោយការមិនទៀង ជាទុក្ខ ជាអនត្តា" ដូច្នេះ ។

ពិតមែន ពាក្យដែលពោលថា "អារម្មណ៍បច្ចុប្បន្នយ៉ាងណា ដែលមានមនោទ្វារវិថីកាន់យកប្រព្រឹត្តទៅ អារម្មណ៍នោះ ជាអារម្មណបុរេជាតប្បច្ច័យដល់មនោទ្វារវិថី" ដូច្នេះ នោះសម្រេចតាមប្រាថ្នា (នេះម្យ៉ាង) ។

ឧបនិស្ស័យដោយប្រក្រតីនោះឯង គឺ ដោយសភាវៈរបស់ខ្លួនប៉ុណ្ណោះ វៀរចាកបច្ច័យដទៃ ឈ្មោះថា បកតូបនិស្ស័យ ។ មានអធិប្បាយដែលលោកពោលទុកថា "ឧបនិស្ស័យមួយ

ចំណែកខ្លះ មិនលាយជាមួយអារម្មណ៍ដទៃ" ដូច្នេះ ។ ម្យ៉ាងទៀត ឧបនិស្ស័យដែលធ្វើទុកទៅ ឈ្មោះថា បកតូបនិស្ស័យ ។

ក៏ **ប** អក្សរក្នុងពាក្យថា "បកតោ"នេះ ជាឧបសគ្គ ។ **ប** អក្សរនោះ រមែងបំភ្លឺធម៌ដែលបុគ្គលគប្បីឱ្យសម្រេច ក្នុងសន្តាន និងភាពជាធម៌ដែលបុគ្គលគប្បីសេព ដោយភាពជាធម៌អាចក្នុងការញ៉ាំងផលរបស់ខ្លួនឱ្យកើត ។ ព្រោះដូច្នោះ អកុសលធម៌មានរាគៈជាដើម និងកុសលធម៌មានសទ្ធាជាដើម ដែលសម្រេចក្នុងសន្តានរបស់ខ្លួន ឬឧតុនិងភោជនៈជាដើម ដែលបុគ្គលគប្បីសេព ឈ្មោះថា បកតូបនិស្ស័យ ។ លោកអាចារ្យអធិប្បាយ បកតូបនិស្ស័យទុកដោយប្រការ ដូច្នេះ ។

ពាក្យថា "ធ្វើឱ្យចាស់ក្លា" បានដល់ អារម្មណ៍ដែលចិត្ត និងចេតសិកធ្វើឱ្យចាស់ក្លាហើយពិចារណា ។ យ៉ាងនោះពិតនិទ្ទេសនៃអារម្មណូបនិស្ស័យ ប្រព្រឹត្តទៅហើយ ដោយអំណាចនៃទាន, សីល, ឧបោសថកម្ម, កុសលកម្មដែលធ្វើទុកនៅក្នុងកាលមុននឹងសន្សំទុកល្អហើយ ឈាន, គោត្រភូ, វោទាន និងមគ្គជា

ដើមឱ្យចាស់ក្លាហើយ ពិចារណាដោយន័យជាដើមថា "បុគ្គលឱ្យទាន, សមាទានសីល, ធ្វើឧបោសថកម្ម ហើយធ្វើកុសលមានទានជាដើមនោះឱ្យចាស់ក្លា រមែងពិចារណា" ដូច្នេះ ។

លោកអាចារ្យពោលពាក្យជាដើមថា "ចិត្តនិងចេតសិករលត់ទៅហើយ មិនមានរវាងចន្លោះ"ដូច្នោះទុក ក៏ព្រោះអនន្តរូបនិស្ស័យ មិនប្លែកផ្សេងពីអនន្តរប្បច្ច័យមកហើយ ដោយន័យជាដើមថា "កុសលក្ខន្ធមុនជាបច្ច័យដល់កុសលក្ខន្ធក្រោយដោយអំណាចអនន្តរប្បច្ច័យ" ដូច្នេះ ។ សូម្បីយ៉ាងនោះក៏ដោយបច្ច័យទាំងពីរនេះ ក៏មានសេចក្តីផ្សេងគ្នាយ៉ាងនេះ គឺ ឈ្មោះថាអនន្តរប្បច្ច័យ ដោយអំណាចចិត្តុប្បាទៈដែលសមគួរក្នុងលំដាប់របស់ខ្លួន, ឈ្មោះថា អនន្តរូបនិស្សយប្បច្ច័យ ដោយអំណាចនៃការណៈដ៏មានកម្លាំង ។ អធិប្បាយសេចក្តីថា "ធម៌ទាំងឡាយមានរាគៈ និងសទ្ធាជាដើម សុខ, ទុក្ខ, បុគ្គល, ភោជនៈ ឧតុនិងសេនាសនៈ ទាំងខាងក្នុង ទាំងខាងក្រៅ ជាបច្ច័យដល់ធម៌ទាំងឡាយ មានកុសលជាដើម តាមសមគួរ ។ ពិតមែន ធម៌មាន

រាគៈជាដើម ដែលបុគ្គលឱ្យសម្រេចហើយខាងក្នុងខ្លួន និងបុគ្គលជាដើម ដែលបុគ្គលសេពហើយ ចំណែកខាងក្រៅ ។ សមពិតដូចពាក្យដែលលោកអាចារ្យពោលទុកថា ៖

**ធម៌ មានរាគៈ និងសទ្ធាជាដើម ដែលបុគ្គលអប់រំហើយខាងក្នុង និងធម៌ គឺ សត្វ និងសង្ខារទាំងឡាយ ដែលបុគ្គលសេពហើយខាងក្រៅ ជាឧបនិស្ស័យដល់កុសលធម៌ជាដើម ។**

ម្យ៉ាងទៀត ការប្រកបដោយអំណាចសេចក្ដីគាថា តាមដែលតាំងនៅនុ៎ះឯងថា "ធម៌ទាំងឡាយ មានរាគៈជាដើម និងធម៌ទាំងឡាយ មានសទ្ធាជាដើម សុខ ទុក្ខ បុគ្គល ភោជនៈ ឧតុ និងសេនាសនៈ រមែងជាឧបនិស្ស័យដល់ធម៌ មានកុសលជាដើមទាំងខាងក្នុង និងខាងក្រៅ" ដូច្នេះ គឺ ធម៌ មានរាគៈ និងសទ្ធាជាដើមរបស់ខ្លួន រមែងជាឧបនិស្ស័យដល់ធម៌ មានកុសលជាដើមរបស់ខ្លួន និងដល់កុសលជាដើមរបស់ពួកមនុស្សដទៃ ដែលអាស្រ័យសទ្ធាជាដើមរបស់កល្យាណមិត្ត ហើយធ្វើកុសល ។ បណ្ឌិតគប្បីឃើញពាក្យតាមសមគួរយ៉ាងនេះថា ទាន សីល

ឧបោសថ ឈាន អភិញ្ញា វិបស្សនា និងមគ្គភាវនាក្ដី ធម៌មានរាគៈក្នុងភពខាងលើឡើងទៅ ដែលជាហេតុនៃធម៌ មានរាគៈជាដើមក្ដី រមែងមានដើម្បីអាស្រ័យ ធម៌មានកាមរាគៈជាដើម ក្នុងធម៌មានរាគៈជាដើមនោះ ហើយកើតក្នុងភពទាំងឡាយ មានកាមភពជាដើម និងដើម្បីសេចក្ដីចូលទៅរម្ងាប់កិលេសមានរាគៈជាដើមដូច្នេះ ។

ពិតមែន ធម្មជាតិណា ៗ អាស្រ័យធម្មជាតិណា ៗ កើតឡើងប្រព្រឹត្តទៅ ធម្មជាតិនោះ ជាបកតូបនិស្ស័យ ដល់ធម្មជាតិនោះ ៗ ក៏លោកអាចារ្យពោលទុកថា **"បច្ចយមហា-បទេសោ ហេស យទិទំ ឧបនិស្សយប្បច្ចយោ** ពិតមែន បច្ច័យនេះ គឺឧបនិស្សយប្បច្ច័យជាបច្ច័យ មហាបទេស (គឺ ជាបច្ច័យដែលមានខអាងច្រើន ឬទូលំទូលាយច្រើន)" ។ ក៏ដោយសេចក្ដីជាមហាបទេសយ៉ាងនោះ ព្រះអនុរុទ្ធាចារ្យ ទើបពោលថា បកតូបនិស្ស័យ មានច្រើនយ៉ាង ។

ពាក្យថា **សទ្ធា**ជាដើម បានដល់ សីល សុតៈ ចាគៈ និង

បញ្ញា ។

ពាក្យនេះថា "ប្រាកដណាស់ ទានសីលជាដើមរបស់ខ្លួន អាស្រ័យសទ្ធាជាដើមរបស់ខ្លួន ទើបកើតបាន, និងទាន សីលជាដើមរបស់មនុស្សដទៃ ក៏អាស្រ័យសទ្ធានិងសីលជាដើមរបស់កល្យាណមិត្ត ទើបកើតបានដូចគ្នា" ដូច្នេះ ប្រាកដច្បាស់ហើយ ។

ពាក្យថា **សុខ និងទុក្ខ** បានដល់ សុខនិងទុក្ខផ្លូវកាយ ។ ពាក្យថា បុគ្គល បានដល់ បុគ្គលជាកល្យាណមិត្តជាដើម ។ ពាក្យថា **ភោជន** បានដល់ ភោជនដែលជាសប្បាយជាដើម ។ សូម្បីឧតុក៏ដូចគ្នា ។ ដើម្បីនឹងញុំាងអត្ថ ដែលពោលទុកដោយសង្ខេបថា "នាមរូបជាបច្ច័យដល់នាមរូប ដោយបច្ច័យ ៩ យ៉ាង តាមសមគួរ គឺ ដោយអំណាចអធិបតិប្បច្ច័យ ១, សហជាតប្បច្ច័យ ១, អញ្ញមញ្ញប្បច្ច័យ ១, និស្សយប្បច្ច័យ ១, អាហារប្បច្ច័យ ១, ឥន្ទ្រិយប្បច្ច័យ ១ វិប្បយុត្តប្បច្ច័យ ១, អត្ថិប្បច្ច័យ ១, និងអវិគតប្បច្ច័យ ១, ដូច្នេះ ឱ្យពិស្តារ ទើបព្រះអនុរុទ្ធាចារ្យពោលថា "បណ្តាបច្ច័យទាំង ៩ នោះ អារម្មណ៍ដែល

ធ្ងន់ខ្លាំង"ជាដើម អធិប្បាយថា អារម្មណ៍ដែលបុគ្គលធ្វើឱ្យធ្ងន់ខ្លាំង ដោយបច្ចវេក្ខណៈ និងអស្សាទៈជាដើម ។ ពិតមែន អារម្មណ៍នោះ ដែលផ្សេងដោយអារម្មណ៍មានឈាន មគ្គ ផល និព្វានជាដើម រមែងធ្វើធម៌មានបច្ចវេក្ខណៈ អស្សាទៈ មគ្គ ផលជាដើម ឱ្យជាប់ជាមួយនឹងខ្លួន ព្រោះដូច្នោះ ទើបឈ្មោះថា អារម្មណាធិបតិ ។ បច្ច័យទាំង ២ នោះ មានសេចក្តីប្លែកគ្នាយ៉ាងនោះ គឺ អារម្មណាធិបតិ រមែងមានដោយហេតុត្រឹមតែជាអារម្មណ៍ គួរធ្វើឱ្យធ្ងន់ខ្លាំង អារម្មណូបនិស្ស័យ រមែងមានដោយអត្ថថា ជាការណៈដែលមានកម្លាំងជាងអារម្មណ៍ដែលធ្វើឱ្យធ្ងន់ខ្លាំង ។

ពាក្យថា "សហជាតៈជាដើម ជាបច្ច័យដល់នាមរូប" អធិប្បាយថា សហជាតាធិបតីមាន ៤ ដោយអំណាចឆន្ទៈ វីរិយៈ ចិត្តៈ និងវីមំសា ជាបច្ច័យដល់នាមរូបដែលកើតព្រមគ្នាក្នុងបវត្តិកាលប៉ុណ្ណោះ ដោយអំណាចសហជាតាធិបតី តាមសមគួរ ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា "ការដែលរូបធម៌អាស្រ័យអរូបធម៌ ជាសហជាតបច្ច័យ ព្រះមានព្រះភាគ ត្រាស់

ទុកដោយអំណាចនៃវត្ថុក្នុងបដិសន្ធិកាលប៉ុណ្ណោះ" ទើបពោលពាក្យថា "វត្ថុវិបាកជាបច្ច័យ ដល់គ្នានិងគ្នា" ដូច្នេះ ។

## ចិត្ត និងចេតសិកជាបច្ច័យដល់គ្នានិងគ្នា

ក៏ព្រោះភាវៈនៃចិត្តនិងចេតសិក ជាអញ្ញមញ្ញប្បច្ច័យ ដោយអំណាចនៃការជួយឧបត្ថម្ភដល់គ្នានោះឯង មិនមែនត្រឹមតែកើតរួមគ្នា ដោយថា ក្នុងបវត្តិកាល រូបមិនជាអញ្ញមញ្ញប្បច្ច័យដល់នាម ដូច្នោះ ទើបលោកអាចារ្យពោលថា "ចិត្តនិងចេតសិកជាបច្ច័យដល់គ្នា" ដូច្នេះ ។ ម្យ៉ាងទៀត ឧបាទាយរូប ក៏មិនជាអញ្ញមញ្ញប្បច្ច័យដល់ភូតរូប ដូចរូបក្នុងបវត្តិកាល មិនជាអញ្ញមញ្ញប្បច្ច័យដល់នាម ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា "មហាភូតរូប ជាអញ្ញមញ្ញប្បច្ច័យដល់គ្នា" ដូច្នេះ ។

សួរថា ក៏លោកអាចារ្យបានពោលថា អរូបអាហារជាបច្ច័យដល់នាមរូបដែលកើតរួមគ្នា មិនមែនឬ ? ក៏កាលបើយ៉ាងនោះ ពាក្យថា "សត្វទាំងពួងតាំងនៅបានដោយអាហារ" ដូច្នេះ តើពួក

យើងនឹងដឹងដូចម្ដេច ? ព្រោះសហជាតាហារ មិនមានដល់ពួកអសញ្ញីសត្វ ។

ឆ្លើយថា កាលដែលសព្វសត្វមានសេចក្ដីតាំងនៅបានដោយអាហារ ព្រះមានព្រះភាគប្រាថ្នាយកបរិយាយ គឺ កម្មដែលប្រព្រឹត្តទៅដោយអំណាចនៃអាហារ គឺ មនោសញ្ចេតនា[១] ឬអាហារដែលនៅសល់ក្រៅពីនេះ សូម្បីដែលសហគតដោយមនោសញ្ចេតនាហារនោះ ជាបច្ច័យដោយកម្មប្បច្ច័យ និងឧបនិស្សយប្បច្ច័យ មិនមែនដោយអាហារប្បច្ច័យ ។

សួរថា ឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ លោកអាចារ្យមិនកាន់យកក្នុងឥន្ទ្រិយទាំងឡាយ មានប្រសាទរូបជាដើមឬ ?

ឆ្លើយថា ពិតមែនហើយ លោកមិនបានកាន់យកមែន ។

ភាពដែលឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ ទាំងពីរនោះ ជាធម្ម

---

**១. មនេន សម្បយុត្តា ចេតនា = មនោសញ្ចេតនា** ចេតនាដែលសម្បយុត្តដោយមនៈ ឈ្មោះថា មនោសញ្ចេតនា ។

ជាតិញ៉ាំងអាការ មានប្រភេទជាដើម(១)ឱ្យប្រព្រឹត្តទៅតាមខ្លួន នៅមានក៏ពិតមែន តែវាក៏មិនមានភាពជាបច្ច័យ ដូចយ៉ាងថា ជីវិតនិងអាហារជាបច្ច័យដល់ធម៌ពួកណា ក៏អនុបាលឧបត្ថម្ភធម៌ទាំងនោះ ជាអត្ថិប្បច្ច័យនិងអវិគតប្បច្ច័យ ដល់ធម៌ទាំងនោះយ៉ាងណា ភាពជាប្រុស និងស្ត្រី ជាធម៌ឧបការៈដល់ភេទជាដើម ដោយឧបការៈ ណា ៗ ដូចយ៉ាងនោះ ក៏ទេ ។ តែភាវៈនៃភេទជាដើម ដែលប្រព្រឹត្តទៅតាំងពីបច្ច័យ មានកម្មជាដើម តាមសមគួរដល់ខ្លួន តែម្យ៉ាង ជាបច្ច័យដល់សេចក្តីដឹងថា ជាស្រី ជាប្រុស ដោយអាការណា ព្រោះការមិនប្រព្រឹត្តទៅក្នុងសន្តាន ជាការប្រព្រឹត្តិទៅព្រមដោយភាពជាស្ត្រីជាប្រុសនោះ ដោយអាការដទៃ ក្រៅពីអាការនោះ ទើបលោកអាចារ្យពោលភាវៈជាស្ត្រី ជាប្រុសនោះ ញ៉ាំងភេទជាដើមឱ្យប្រព្រឹត្តទៅតាមខ្លួន និងជាឥន្ទ្រិយ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគមិនត្រាស់ភាវៈនៃភាពជាស្ត្រី ជាប្រុសនោះ ជា

១. ភេទ និមិត្ត កុត្ត: អាកប្ប:, មានក្នុងបរិច្ឆេទទី ៦ អំពីភាវរូប ។

ឥន្ទ្រិយប្បច្ច័យ ។

លោកអាចារ្យធ្វើក្នុងចិត្តថា "ការប្រព្រឹត្តិទៅនៃនាមពួកណា ដូចជាចេញពីខាងក្នុងនៃវត្ថុមានហទយវត្ថុជាដើម និងការប្រព្រឹត្តិទៅនៃរូបពួកណា ដែលកំពុងកើតដោយអាស្រ័យនាមនោះឯង ។ (ទាំង ២ នេះ) មិនលាយគ្នាក្នុងសម្បយោគ-នាមរូប ទើបជាវិប្បយុត្តប្បច្ច័យដល់នាមរូបពួកនោះ ចំណែករូបមិនលាយគ្នា ក្នុងសម្បយោគជាមួយរូប រមែងមិនមាន ។ រូបដែលត្រឹមតែជាអារម្មណ៍នៃនាម ដែលកើតព្រោះអាស្រ័យវត្ថុនោះឯង ឈ្មោះថាអាលម្ពនៈ ព្រោះដូច្នោះ នាមរូបទាំងនោះ ទើបមិនលាយគ្នា ក្នុងសម្បយោគជាមួយនឹងអារម្មណ៍នោះ ព្រោះហេតុនោះ ធម៌ពួកណាមិនលាយគ្នាក្នុងសម្បយោគ មានធម៌ទាំងនោះឯង សូម្បីជាវិប្បយុត្តប្បច្ច័យ ព្រះមានព្រះភាគ ក៏ត្រាស់ទុកហើយ" ដូច្នេះ ទើបពោលពាក្យថា "ក្នុងខណៈបដិសន្ធិ វត្ថុ និងវិបាក ជាបច្ច័យគ្នា" ។

## អធិប្បាយ សង្គហគាថាទី ៧

អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យមាន ៥ យ៉ាង គឺ បច្ច័យដែលជាជាតៈ មាន ៣ បានដល់ សហជាតបីយ៉ាង[១] ១, បុរេជាតៈពីរយ៉ាង ១, បច្ឆាជាតៈមួយយ៉ាង ១, ដែលលោកពោលទុកដោយអំណាចនាមរូប តាមសមគួរ ដោយប្រការទាំងពួង គឺ គ្រប់យ៉ាង ក្នុងអាហារទាំងឡាយ បានដល់ កពឡីង្ការាហារ ១ រូបជីវិតិន្ទ្រិយ ១ ។

## ព្រះនិព្វាននៅមានគ្រប់កាល

ដើម្បីនឹងសម្តែងបដិសេធន៍ថា ព្រះនិព្វាន មិនមែនអត្ថិប្បច្ច័យ ទើបលោកពោលថា ភាវៈនៃធម៌ដែលជួយទំនុកបម្រុងអត្ថិភាវៈ (គឺ ដែលមានអញ្ញមញ្ញប្បច្ច័យ) និងដល់ធម៌ដែលមិនជួយទំនុកបម្រុង ដោយមិនមានអត្ថិភាវៈ (គឺ ដែលមិន

---

១. សហជាត ៣ មើលទំព័រ ៨៦៦ ។

មានអញ្ញមញ្ញប្បច្ច័យ) ព្រោះធម៌ដូច្នោះនុ៎ះឯង ជាសភាពឧបត្ថម្ភដោយភាវៈដែលនៅមាន ដែលមានសភាពជាបច្ចុប្បន្ន ឈ្មោះថា អត្ថិប្បច្ច័យ ព្រោះដូច្នោះ ព្រះនិព្វានដែលមានបានគ្រប់កាល ទើបមិនជាអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។

មួយទៀត ភាវៈនៃធម៌ដែលប្រកបដោយខណៈ មានឧប្បាទក្ខណៈជាដើម ធ្វើការជួយឧបត្ថម្ភ ដែលខុសចាកភាវៈនៃធម៌ដែលធ្វើការជួយឧបត្ថម្ភ ដោយនត្ថិភាវៈ និងខុសចាកភាវៈដែលធ្វើការជួយឧបត្ថម្ភដោយវិគតភាវៈ ឈ្មោះថា អត្ថិប្បច្ច័យជាដើម ព្រោះដូច្នោះ ព្រះនិព្វាននោះ ទើបមិនដល់ភាពជាអត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។

ក៏បណ្តាអត្ថិបច្ច័យទាំង ៥ នេះ រូបជីវិតិន្ទ្រិយ ព្រះមានព្រះភាគ ទ្រង់មិនកាន់យកក្នុងពួកសហជាតប្បច្ច័យ ព្រោះជាធម្មជាតិឧបត្ថម្ភចំពោះតែក្នុងឋិតិខណៈ ដូចឱជា ព្រោះដូច្នោះ ទើបលោកអាចារ្យពោលរូបជីវិតិន្ទ្រិយទុកមួយផ្នែក ។

## សរុបបច្ច័យ ២៤ សល់តែ ៤ យ៉ាង

ឥឡូវនេះ ដើម្បីសម្តែងថា បច្ច័យទាំងអស់ដោយសង្ខេប មាន ៤ ប៉ុណ្ណោះ, ទើបលោកអាចារ្យពោលថា បច្ច័យទាំងអស់ រមែងដល់ការប្រជុំចុះ ក្នុងអារម្មណប្បច្ច័យ ឧបនិស្សយប្បច្ច័យ កម្មប្បច្ច័យ និងអត្ថិប្បច្ច័យ ដូច្នេះ ។

ពិតមែន បច្ច័យអ្វី ៗ ដែលទីងមិនគប្បីដល់ភាពជា អារម្មណ៍នៃចិត្ត និងចេតសិក រមែងមិនមាន និងមិនដល់ភាពជា ឧបនិស្សយប្បច្ច័យដល់ធម៌ដែលកើតពីបច្ច័យ បច្ចយុប្បន្នរបស់ ខ្លួន ៗ ក៏មិនមាន ។

ម្យ៉ាងទៀត សូម្បីបច្ច័យទាំងអស់ រមែងមិនហួសពីសភាព នៃកម្ម ដោយអំណាចនៃការប្រព្រឹត្តិទៅជិត ក្នុងហេតុនិងផល ព្រោះការប្រព្រឹត្តិរបស់លោក មានកម្មជាហេតុ ។ ក៏បច្ច័យទាំង ឡាយប៉ុណ្ណោះ មានដោយបរមត្ថ និងដោយអំណាចនៃលោក សម្មតិ ព្រោះដូច្នោះ បច្ច័យទាំង ២៤ ទើបដល់ការប្រជុំចុះ ក្នុង បច្ច័យ ៤ យ៉ាង ។

## អធិប្បាយសហជាតរូប ២ យ៉ាង

ឥឡូវនេះ ដើម្បីសម្តែងថា ពាក្យណា ដែលព្រះអនុរុទ្ធាចារ្យពោលទុកក្នុងកន្លែងនៃបច្ច័យនោះ ៗ ថា “សជាតរូប” ដូច្នេះ ។ ពាក្យទាំងអស់នោះ បណ្ឌិតគប្បីជ្រាបដោយការមិនប្លែកគ្នា ទើបលោកពោលពាក្យថា **សជាតរូបំ** ជាដើម ។

ពិតមែន ឈ្មោះថា សហជាតរូប មាន ២ យ៉ាង គឺ ដោយអំណាចនៃរូបដែលមានចិត្តជាសមុដ្ឋាន ក្នុងបវត្តិកាល មួយយ៉ាង, ដោយអំណាចនៃកម្មជរូប ពោលគឺ កដត្តារូបក្នុងបដិសន្ធិកាល មួយយ៉ាង, សូម្បីដោយប្រការទាំងពួង ព្រោះរូបមានចិត្តជាសមុដ្ឋាន មិនមានក្នុងបដិសន្ធិកាល និងព្រោះរូបដែលមានកម្មជាសមុដ្ឋានកើតរួមជាមួយចិត្ត និងចេតសិក មិនមានកំណត់ក្នុងបវត្តិកាល ។ រូបទាំងឡាយ ដែលកំពុងកើតព្រោះកម្មដែលសត្វបានធ្វើទុក ឈ្មោះថា កដត្តារូប ។

## បច្ច័យ២៤ ដោយសង្ខេបតាំងនៅដោយអាការ៣យ៉ាង

ក្នុងគាថាទី ៨-៩ សម្តែងបច្ច័យ ២៤ ប្រកបដោយកាលជាដើមនោះ ប្រកបសេចក្តីថា ធម៌ទាំងឡាយប្រកបដោយកាល ៣ គឺ មាន ៣ កាលដោយអំណាចនៃធម៌ ប្រកបដោយអតីតកាល មាន ៥ យ៉ាង គឺ ដោយអំណាចនៃអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។ ដោយអំណាចនៃកម្មប្បច្ច័យ មាន ២ កាល គឺ ដោយអតីតកាល និងបច្ចុប្បន្នកាល ដោយអំណាចនៃអារម្មណប្បច្ច័យ អធិបតិប្បច្ច័យ និងឧបនិស្សយប្បច្ច័យ មាន ៣ កាល និងដោយអំណាចបច្ច័យធម៌ដែលនៅសល់ ១៥ បច្ច័យ ប្រកបដោយបច្ចុប្បន្នកាល និងធម៌ដែលផុតចាកពីកាល ដោយអំណាចនៃនិព្វាន និងបញ្ញត្តិ ដែលជាខាងក្នុងដោយអំណាចនៃប្រសាទរូប មានចក្ខុជាដើម និងធម៌មានរាគៈ និងសទ្ធាជាដើម ដែលជាខាងក្រៅដោយអំណាចនៃបុគ្គល ឧតុ និងភោជនៈជាដើម ដែលជាសង្ខតៈ ដែលជាធម៌កើតអំពីបច្ច័យ និងជាអសង្ខតៈ ដោយជាបដិបក្ខនិងសង្ខតៈ

នោះ តាមដែលកើត គឺ តាមសមគួរដល់ការប្រព្រឹត្តិទៅ ដោយន័យដែលពោលហើយ យ៉ាងនេះ ឈ្មោះថា បច្ច័យ លោកពោលទុក ២៤ បច្ច័យក្នុងបដ្ឋានបករណ៍ គឺក្នុងបករណ៍ ឈ្មោះថា អនន្តន័យ សមន្តប្បដ្ឋាន ដោយប្រការទាំងពួង ជាធម៌តាំងនៅដោយសង្ខេប ៣ យ៉ាង ដោយអំណាចនៃបញ្ញត្តិ[១] នាមនិងរូបដូច្នោះ ។

## អធិប្បាយ បញ្ញត្តិ ២ យ៉ាង

បណ្តាបញ្ញត្តិ នាម និងរូបទាំងនោះ បញ្ញត្តិមាន ២ យ៉ាងគឺ

១- បញ្ញាបីយត្តា បញ្ញត្តិ ឬ អត្ថប្បញ្ញត្តិ

២- បញ្ញាបនតោ បញ្ញត្តិ ឬ សទ្ទប្បញ្ញត្តិ

បញ្ញត្តិ ២ យ៉ាងនេះ ផ្សេងគ្នា គឺ ដោយអត្ថៈ ដែលបណ្ឌិតគប្បីពោល (មួយយ៉ាង) និងជាសទ្ទ (សំឡេង) ពោលដល់សេចក្តីសំដៅ(មួយយ៉ាង) ព្រោះដូច្នោះ ទើបព្រះ

---

១. បញ្ញត្តិដោយសង្ខេប ២ គឺ វិជ្ជមានបញ្ញត្តិ និងអវិជ្ជមានបញ្ញត្តិ ។

អនុរុទ្ធាចារ្យពោលពាក្យថា **បញ្ញាបីយត្តា** និង **បញ្ញាបនតោ** ជាដើម ។ ពាក្យថា **បញ្ញាបីយត្តា** ប្រែថា ព្រោះជាអត្ថ ដែលបណ្ឌិតគប្បីជ្រាបដោយប្រការនោះ ៗ ដោយពាក្យដែលជាកម្មសាធារណៈនេះ ទើបលោកពោលថា ជាអត្ថប្បញ្ញត្តិ គឺ ឧបាទាបញ្ញត្តិ ជាសម្មតិសច្ចៈ ដែលផ្សេងដោយការប្រជុំនិងការបន្តជាដើម នៃធម៌ទាំងឡាយមានរូបជាដើម និងសេចក្តីកំណត់ដែលវិសេសជាដើម[១] ព្រោះអត្ថប្បញ្ញត្តិនោះ រមែងដឹងបាន ដោយនាមប្បញ្ញត្តិ ។

ពាក្យថា **បញ្ញាបនតោ** ប្រែថា ព្រោះអត្ថប្បញ្ញត្តិ ដោយប្រការទាំងឡាយ ពិតដោយពាក្យ កត្តុសាធនៈនេះ ពោលនាមប្បញ្ញត្តិ គឺ ឈ្មោះរបស់អត្ថទាំងឡាយ ដែលបាននាមថា បញ្ញត្តិ ព្រោះជាអត្ថៈឱ្យដឹងបាន ។

---

១. អត្ថយោជនា តតិយភាគ សេចក្តីកំណត់វិសេស បានដល់កសិណុគ្ឃាដនាជាដើម ។

## បញ្ញាបីយត្តា បញ្ញត្តិ ៦យ៉ាង

គប្បីជ្រាប បញ្ញាបីយត្តា បញ្ញត្តិ មាន ៦ យ៉ាង ដូចតទៅនេះ ៖

## ១-សន្តានប្បញ្ញត្តិ

ពាក្យថា បញ្ញត្តិ អាស្រ័យអាការ គឺ ការផ្លាស់ប្តូរប្រែប្រួលរបស់ភូតរូប បានដល់ ដោយអាការផ្សព្វផ្សាយ ពង្រីកចេញនិងរួមចូលជាដើមនៃមហាភូតរូប មានដីនិងភ្នំជាដើម ដែលប្រព្រឹត្តទៅដោយអំណាចការបន្ត គឺ ធ្វើឱ្យជានិស្សយៈ ។ ពាក្យថា ដោយប្រការនោះៗ បានដល់ ដោយអំណាចនៃផែនដី ភ្នំនិងដើមឈើជាដើម ហៅថា សន្តានប្បញ្ញត្តិ ។

## ២-សមូហប្បញ្ញត្តិ

ពាក្យថា អាការ គឺ ការប្រជុំនៃសម្ភារៈ បានដល់ ឧបករណ៍ មានឈើ ដីស្អិត និងខ្សែជាដើម គឺ មានអាការសណ្ឋានជាដើមនោះ. ដែលសម្រេចហើយដោយការធ្វើ ។ ពាក្យថា រថ និងរទេះជា

ដើម បានដល់ មានរថ រទេះ ផ្ទះ ឆ្នាំង និងផ្តុំងសំពត់ជាដើម ហៅថា សមូហប្បញ្ញត្តិ ។

## ៣_សម្មុតិបញ្ញត្តិ

សម្មុតិបញ្ញត្តិនេះ ខ្លះហៅថា សត្តប្បញ្ញត្តិ បើសិនជាដោយភាវៈ ហើយ ក៏ជាបញ្ញត្តិដែលអាស្រ័យខន្ធ ៥ តែងតាំងឡើង ដើម្បីឱ្យដឹងន័យសេចក្តីដូចគ្នាតែម្តង, មួយទៀត បញ្ញត្តិនេះ ជាសច្ចៈ ហៅថា សម្មុតិសច្ចៈ គូជាមួយនឹងបរមត្ថសច្ចៈ នេះសេចក្តីក្នុងសម្មុតិបញ្ញត្តិនេះ មានអត្ថច្បាស់លាស់ហើយ ។

## ៤_ទិសាកាលប្បញ្ញត្តិ

ពាក្យថា ការវិលជុំវិញព្រះចន្ទជាដើម បានដល់ អាការ គឺ ព្រះចន្ទ ព្រះអាទិត្យ និងផ្កាយនក្ខត្តឫក្សទាំងឡាយ វិលទៅ មានការរះឡើងជាដើម ដោយអំណាចនៃការវិលខាងស្តាំជុំវិញភ្នំសិនេរុ ។ ពាក្យថា ទិស និងកាលជាដើម បានដល់ បញ្ញត្តិទិសមានខាងកើតជាដើម ឈ្មោះថា **ទិសាបញ្ញត្តិ** ។ បញ្ញត្តិកាល មានវេលាព្រឹកជា

ដើម ឈ្មោះថា **កាលប្បញ្ញត្តិ** ។ បញ្ញត្តិ ខែ, រដូវ, ឈ្មោះខែមាន វិសាខ ជាដើម ដែលផ្សេងគ្នាដោយឈ្មោះនោះថា **មាសាបញ្ញត្តិ** ។

## ៥_អាកាសប្បញ្ញត្តិ

អាកាសប្បញ្ញត្តិនេះ ខ្លះហៅថា កូបគូហាទិបញ្ញត្តិ ។

ពាក្យថា អាកាសដែលមហាភូតរូបមិនទាន់ទល់ដល់គ្នា បានដល់ អាកាស មានប្រហោង រូងជាដើម ដែលរូបកលាបនោះ ៗ មិន ទល់ដល់គ្នានិងគ្នា ។

ពាក្យថា អណ្តូង និងល្អាង (រូងភ្នំ)ជាដើម បានដល់ បញ្ញត្តិ ប្រទ្បោះទទេ មានអណ្តូង និងប្រហោងរូងជាដើម ឈ្មោះថា អាកាសប្បញ្ញត្តិ ។

## ៦_និមិត្តប្បញ្ញត្តិ

ពាក្យថា ភូតនិមិត្តនោះ ៗ បានដល់ ភូតនិមិត្តនោះ មាន បឋវីកសិណជាដើម ។ ពាក្យថា ភាវនាវិសេស បានដល់ អាការ ពិសេសដែលបន្តជាប់គ្នារបស់ភាវនា ដែលផ្សេងគ្នាដោយនិមិត្ត

មានបរិកម្មជាដើម ។ ពាក្យថា កសិណនិមិត្តជាដើម បានដល់ បញ្ញត្តិ គឺ និមិត្តដែលផ្សេងគ្នា គឺ ឧគ្គហ[១] និងបដិភាគ[២] ដែលប្រាកដដល់ព្រះយោគី ដែលផ្សេងដោយកសិណនិមិត្ត និង អសុភនិមិត្តជាដើម និងបញ្ញត្តិដែលផ្សេងគ្នាដោយអាកាសដែលបើ កកសិណ និងនិរោធកសិណជាដើម ។ ពាក្យថា ដោយអាការ គឺ ស្រមោលរបស់អត្ថ អធិប្បាយថា ដោយអាការ គឺ ស្រមោល បានដល់ ដោយអាការ គឺ ជាចំណែកប្រៀបធៀបនៃបរមត្ថធម៌ ។

---

១. មានវចនត្ថថា **ឧគ្គហេតព្វំ មនសាតិ = ឧគ្គហំ :** និមិត្តណា ដែលបុគ្គល គប្បីកាន់យក ដោយចិត្ត ព្រោះហេតុនោះ និមិត្តនោះ ឈ្មោះថា ឧគ្គហៈ ។

២. មានវចនត្ថថា **ឧគ្គហនិមិត្តេន បដិ សទិសភាវំ ភជតិ គច្ឆតីតិ = បដិភាគំ :** និមិត្តណា រមែងសេពមាំ រមែងទៅកាន់ភាវៈ ដូចនឹង ឧគ្គហនិមិត្តនោះ ព្រោះហេតុនោះ និមិត្តនោះ ឈ្មោះថា បដិភាគៈ ។

## បញ្ញាបនតោ បញ្ញត្តិ

**បញ្ញាបនតោ បញ្ញត្តិ** លោកអាចារ្យសម្តែងទុកដោយឈ្មោះ មាននាមនិងនាមកម្មជាដើម ពាក្យថា ដោយឈ្មោះ មាននាមនិងនាមកម្មជាដើម បានដល់ ឈ្មោះ ៦ យ៉ាង គឺ ៖

**១-នាម** បង្អោនទៅក្នុងអត្ថ
**២-នាមកម្ម** ការធ្វើឈ្មោះ
**៣-នាមធេយ្យ** ការតាំងឈ្មោះ
**៤-និរុត្តិ** ការពោលអត្ថដោយអក្ខរៈ
**៥-ព្យញ្ជន** នាមដែលប្រកាសអត្ថ
**៦-អភិលាប** សំឡេងដែលគេនិយាយ

បណ្តានាមជាដើមទាំងនោះ សទ្ទរូបណា រមែងបង្អោនទៅក្នុងអត្ថទាំងឡាយ ព្រោះហេតុនោះ សទ្ទរូបនោះ ឈ្មោះថា នាម ។ នាមនោះមាន ២ យ៉ាង គឺ ដោយអំណាចនៃនាមដែលស្របតាមអត្ថ ១ និងម្យ៉ាងទៀត បានដល់ នាមដែលគេនិយមមាន ៤ គឺ ដោយអំណាចនៃសាមញ្ញនាម (ឈ្មោះទូទៅ) ១

គុណនាម (ឈ្មោះតាមសេចក្ដីល្អ) ១ កិរិយានាម (ឈ្មោះតាមដែលគេធ្វើ) ១ និងយទិច្ឆនាម (ឈ្មោះតាមចូលចិត្ត) ១ ។

ការតាំងឈ្មោះ ឈ្មោះថា នាមកម្ម ។ នាមធេយ្យៈ ក៏យ៉ាងនោះ ។ ការនិយាយ គឺ ការពោលអត្ថចេញជាអក្ខរៈ ឈ្មោះថា និរុត្តិ ។ នាមដែលឈ្មោះថា ព្យញ្ជនៈ ព្រោះអត្ថថា ប្រកាសអត្ថ ។ សំឡេងដែលឈ្មោះថា អភិលាបៈ ព្រោះអត្ថថា ដែលបុគ្គលនិយាយ បានដល់ លំដាប់នៃការប្រជុំរបស់អក្ខរៈទៅតាមសំឡេង ។

**នាមបញ្ញត្តិនោះ មាន ៦ យ៉ាង គឺ**

១- វិជ្ជមានបញ្ញត្តិ

២- អវិជ្ជមានបញ្ញត្តិ

៣- វិជ្ជមានេន អវិជ្ជមានបញ្ញត្តិ

៤- អវិជ្ជមានេន វិជ្ជមានបញ្ញត្តិ

៥- វិជ្ជមានេន វិជ្ជមានបញ្ញត្តិ

## ៦. អវិជ្ជមានេន អវិជ្ជមានបញ្ញត្តិ

ក៏ដើម្បីសម្តែងថា នាមបញ្ញត្តិ(ជាដើម)នោះ មាន ៦ យ៉ាង ដោយអំណាចនៃវិជ្ជមានបញ្ញត្តិ អវិជ្ជមានបញ្ញត្តិ និងការប្រកបគ្នានៃបញ្ញត្តិទាំង ២ នោះ ទើបលោកអាចារ្យពោលពាក្យថា វិជ្ជមានបញ្ញត្តិជាដើម. ពាក្យថា **រមែងបញ្ញត្តិដោយបញ្ញត្តិ** នេះ អធិប្បាយថា បណ្ឌិតរមែងប្រកាសរូប វេទនា សញ្ញា សង្ខារ វិញ្ញាណជាដើម ដោយវិជ្ជមានបញ្ញត្តិនេះ និងរមែងប្រកាសផែនដី ភ្នំជាដើម ដោយអវិជ្ជមានបញ្ញត្តិនេះ ។ ពាក្យថា **បញ្ញត្តិទាំង ២ ផ្សំគ្នា** បានដល់ វិជ្ជមានបញ្ញត្តិ និងអវិជ្ជមានបញ្ញត្តិ ទាំង ២ ។ ដូចមានវចនត្ថៈថា "អភិញ្ញា ៦ គឺ អភិញ្ញា ៥ និងអាសវក្ខយញ្ញាណមានដល់បុគ្គលនេះ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា ឆឡភិញ្ញោ (មានអភិញ្ញា ៦) ។

ក៏បញ្ញត្តិទាំង ៦ នោះ បញ្ញត្តិថា បុគ្គលបានអភិញ្ញា ៦ នោះ ឈ្មោះថា វិជ្ជមានេន អវិជ្ជមានបញ្ញត្តិ ព្រោះអភិញ្ញាមាន តែបុគ្គលអ្នកបានអភិញ្ញានោះ មិនមាន ។ មួយទៀត បញ្ញត្តិថា

សំឡេងរបស់ស្ត្រី ឈ្មោះថា អវិជ្ជមានេន វិជ្ជមានប្បញ្ញត្តិ ព្រោះ ស្ត្រីមិនមាន តែសំឡេងមាន ។

បញ្ញត្តិថា ចក្ខុវិញ្ញាណ ឈ្មោះថា វិជ្ជមានេន វិជ្ជមានប្បញ្ញត្តិ ព្រោះចក្ខុប្រសាទ និងចក្ខុវិញ្ញាណអាស្រ័យចក្ខុប្រសាទនោះមាន ។ បញ្ញត្តិថា ឱរសរបស់ព្រះរាជា ឈ្មោះថា អវិជ្ជមានេន អវិជ្ជមានប្បញ្ញត្តិ ព្រោះព្រះរាជានិងឱរស ជាសម្មតិធម៌ ដូច្នេះ ។

## អធិប្បាយគាថាទី ១០-១១

ពាក្យថា "**វចីឃោសានុសារេន**" អធិប្បាយថា អត្ថទាំង ឡាយ ដែលផ្សេងគ្នា ដោយសម្មតិ និងបរមត្ថដែលជាគោចរ គឺ ជាអារម្មណ៍នៃមនោទ្វារ គឺ ការបន្តរបស់វិញ្ញាណដែលប្រព្រឹត្តទៅ តាមមនោទ្វារវិថី ដែលប្រព្រឹត្តទៅដោយអាការ គឺ ដឹងនាមប្បញ្ញត្តិ មានការសង្កេតដែលបុគ្គលកាន់យកក្នុងកាលមុនថា "ពាក្យនេះ ជា ឈ្មោះនៃសេចក្តីយ៉ាងនេះ" ដូច្នេះ ជាឧបនិស្ស័យជាប្រក្រតីកើតឡើង ក្នុងលំដាប់ តាំងពីការប្រព្រឹត្តិទៅនៃសោតទ្វារវិថី ដែលប្រព្រឹត្តទៅ

តាមក្រសែ គឺ ទៅតាមសំឡេងដែលនិយាយ មានផែនដី ភ្នំ រូប វេទនាជាដើម គឺថា ដោយធ្វើឱ្យជាអារម្មណ៍ ដែលបណ្ឌិតរមែង ដឹងដោយក្រសែសេចក្តី គឺ ប្រព្រឹត្តទៅតាមនាមបញ្ញត្តិ យ៉ាងណា ដែលមានសម្មតិ និងបរមត្ថជាអារម្មណ៍ តអំពីការកាន់យក នាមបញ្ញត្តិនោះ ៗ នាមបញ្ញត្តិនោះ ជានាមបញ្ញត្តិ ដែល សម្តែងអត្ថៈ ដែលបណ្ឌិតគប្បីសម្តែងបញ្ញត្តិ មានផែនដី ភ្នំ រូប និងវេទនាជាដើម ដែលបណ្ឌិតសំដៅយកតាមសេចក្តីសង្កេតរបស់ លោក គឺ តាមវោហាររបស់លោក ជារបៀបនៃអក្សរ ដែលដឹង បានតាមផ្លូវមនោទ្វារ បណ្ឌិតដឹងច្បាស់ថា បញ្ញត្តិ គឺ ដឹងថា នាមបញ្ញត្តិ ពោលគឺ បញ្ញាបនតោ បញ្ញត្តិ ដូច្នោះឯង ៗ

ក៏ក្នុងសង្គហគាថានេះ លោកអាចារ្យបានរួមយកវិថីដែល ប្រព្រឹត្តទៅតាមមនោទ្វារ ដែលមាននៅក្នុងលំដាប់នៃសោតវិញ្ញាណ វិថី ដោយអារម្មណ៍នៃសោតទ្វារវិថី ទើបបានពោលពាក្យថា "របស់ សោតវិញ្ញាណវិថី" ដូច្នេះ ៗ ពិតមែន កាលបុគ្គលបានឮសំឡេង ថា ឃដៈ ដូច្នេះជាដើម ជវនវារៈ ប្រារព្ធយកសំឡេងអក្សរមួយ ៗ

២ ជន ដោយអំណាចអារម្មណ៍ដែលជាបច្ចុប្បន្ន និងអតីត ប្រារព្ធប្រៀបធៀបអក្សរដែលជានាមប្បញ្ញត្តិ ដែលកាន់យកដោយសេចក្ដីដឹងមួន ការដឹងនាមប្បញ្ញត្តិ ក្នុងលំដាប់នៃជវនវិថីដែលមានសំឡេងជាអតីតជាអារម្មណ៍ ដែលជាលំដាប់នៃសោតទ្វារវិថី មានយ៉ាងនេះ ដោយប្រការដូច្នេះ តពីនោះ ជាសេចក្ដីដឹងអត្ថ (អត្ថគហណវិថី) លោកអាចារ្យពោលទុកដូច្នេះឯង ។

ក្នុងបរមត្ថទីបនី សំដែងលំដាប់វិថីដូច្នេះ

១.សោតទ្វារវិថី ដឹងអារម្មណ៍បច្ចុប្បន្ន

២.អតីតគហណវិថី មនោទ្វារដឹងអតីតអារម្មណ៍ តពីសោតទ្វារវិថី

៣.សមូហគហណវិថី មនោទ្វារដឹងសំឡេងដែលប្រជុំគ្នា

៤.នាមគហណវិថី មនោទ្វារដឹងនាមបញ្ញត្តិ

៥.អត្ថគហណវិថី មនោទ្វារដឹងសេចក្ដីសំដៅ ។

## អង្គធម៌របស់បច្ច័យ ២៤

### ១_ហេតុបច្ច័យ

បច្ច័យធម៌ បានដល់ ហេតុ ៦

បច្ចយុប្បន្នធម៌ បានដល់ សហេតុកចិត្ត ៧១ ចេតសិក ៥២ ដែលប្រកបជាមួយ (វៀរមោហចេតសិក នៅក្នុងមោហមូលចិត្ត ២) សហេតុកចិត្តជរូប និង សហេតុកបដិសន្ធិកម្មជរូប ។

បច្ចនិកធម៌ បានដល់ អហេតុកចិត្ត ១៨ អញ្ញសមានាចេតសិក ១២ (វៀរឆន្ទៈ) មោហចេតសិក នៅក្នុងមោហមូលចិត្ត ២ អហេតុកចិត្តជរូប និងអហេតុកបដិសន្ធិកម្មជរូប ពាហិរជរូប អាហារជរូប ឧតុជរូប អសញ្ញសត្តកម្មជរូប និងបវត្តិកម្មជរូប ។

### ២_អារម្មណប្បច្ច័យ

បច្ច័យធម៌ បានដល់ អារម្មណ៍ ៦ គឺ ចិត្ត ៨៩ ចេតសិក ៥២ រូប ២៨ ដែលជាតេកាលិក, និព្វាន និង

បញ្ញត្តិ ដែលកាលវិមុត្ត ។
បច្ចយុប្បន្នធម៌ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ ។
បច្ចនិកធម៌ បានដល់ រូប ៧ ពួក គឺ ចិត្តជរូប បដិសន្ធិ-កម្មជរូប ពាហិរជរូប អាហារជរូប ឧតុជរូប អសញ្ញសត្តកម្មជរូប និងបវត្តិកម្មជរូប ។

**៣_អធិបតិប្បច្ច័យ** មាន ២ យ៉ាង គឺ

១. សហជាតាធិបតិប្បច្ច័យ ២. អារម្មណាធិបតិប្បច្ច័យ

**_សហជាតាធិបតិប្បច្ច័យ**

បច្ច័យធម៌ បានដល់ ឆន្ទាធិបតីដែលនៅក្នុងជវនចិត្ត ៥២.
វីរិយាធិបតី ដែលនៅក្នុងជវនចិត្ត ៥២.
ចិត្តាធិបតី គឺ ជវនចិត្ត ៥២
វិមំសាធិបតីដែលនៅក្នុងជវនចិត្ត ៣៤ ។
បច្ចយុប្បន្នធម៌ បានដល់ សាធិបតីជវនចិត្ត ៥២ ចេតសិក ៥១( វៀរវិចិកិច្ឆា ) និងសាធិបតី ចិត្តជរូប១៧ ។

បច្ចនិកធម៌ បានដល់ ចិត្ត ៦៣ (វៀរអប្បនាជវនចិត្ត ២៦) ចេតសិក ៥២ និងរូប ៧ ពួក ។

-អារម្មណាធិបតិប្បច្ច័យ

បច្ច័យធម៌ បានដល់ និប្ផន្នរូប ១៨ ដែលជាឥដ្ឋារម្មណ៍ ចិត្ត ៨៤ (វៀរទោសមូលចិត្ត ២ មោហមូលចិត្ត ២ ទុក្ខសហគតកាយវិញ្ញាណ ១) ចេតសិក ៤៧ (វៀរទោសៈ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ វិចិកិច្ឆា) និងនិព្វាន ។

បច្ចយុប្បន្នធម៌ បានដល់ ចិត្ត ២៨ គឺ លោភមូលចិត្ត ៨ មហាកុសលចិត្ត៨ មហាកិរិយាញាណសម្បយុត្តចិត្ត ៤ លោកុត្តរចិត្ត ៨ ចេតសិក ៤៥ (វៀរទោសៈ ឥស្សា មច្ឆរិយ កុក្កុច្ច វិចិកិច្ឆា អប្បមញ្ញា ២) ។

បច្ចនិកធម៌ បានដល់ លោកិយចិត្ត ៨១ ចេតសិក ៥២ និងរូបទាំងអស់ ដែលមិនមែនជាឥដ្ឋារម្មណ៍ ។

**៤_អនន្តរៈ ៥_សមនន្តរបច្ច័យ**

បច្ច័យធម៌ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ ដែលកើតមុន (វៀរចុតិចិត្តព្រះអរហន្ត) ។

បច្ចយុប្បន្នធម៌ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ ដែលកើតក្រោយ និងចុតិចិត្តព្រះអរហន្ត ។

បច្ចនិកធម៌ បានដល់ រូបទាំងអស់ ៧ ពួក ។

**៦_សហជាតបច្ច័យ**

បច្ច័យធម៌ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ មហាភូតរូបទាំងអស់ ទាំងក្នុងបដិសន្ធិកាល និងបវត្តិកាលជាមួយនឹងបញ្ចវោការបដិសន្ធិ១៥ ចេតសិក៣៥ ។

បច្ចយុប្បន្នធម៌ បានដល់ ចិត្ត៨៩ ចេតសិក៥២ មហាភូតរូប ឧបាទាយរូប ដែលកើតពីសមុដ្ឋានទាំង ៤ ហទយវត្ថុជាមួយនឹងបញ្ចវោការបដិសន្ធិ ១៥ ចេតសិក ៣៥ ។

បច្ចនិកធម៌ មិនមាន ព្រោះមិនមានធម៌ដែលមិនមែនផល ។

### ៧-អញ្ញមញ្ញប្បច្ច័យ

បច្ច័យធម៌ បានដល់ នាមក្ខន្ធ ៤ គឺ ចិត្ត៨៩ ចេតសិក ៥២ មហាភូតរូប ដែលកើតពីសមុដ្ឋាន ៤ បញ្ចវោការ បដិសន្ធិនាមខន្ធ៤ ជាមួយនឹងបដិសន្ធិហទយវត្ថុ ។

បច្ចយុប្បន្នធម៌ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ មហាភូតរូប ដែលកើតពីសមុដ្ឋាន៤ និងបញ្ចវោការបដិសន្ធិនាមក្ខន្ធ ៤ ជាមួយនិងបដិសន្ធិហទយវត្ថុ ។

បច្ចនិកធម៌ បានដល់ ឧបាទាយរូប២៣ ( វៀរហទយវត្ថុ ) ។

### ៨-និស្សយប្បច្ច័យ មាន ៣

១- សហជាតនិស្សយប្បច្ច័យ ដូចសហជាតិប្បច្ច័យ

២- វត្ថុបុរេជាតនិស្សយប្បច្ច័យ

៣- វត្ថារម្មណបុរេជាតិនិស្សយប្បច្ច័យ

## វត្ថុបុរេជាតនិស្សយប្បច្ច័យ

បច្ច័យធម៌ បានដល់ វត្ថុ៦ មានចក្ខុវត្ថុជាដើម ដែលកើតមុន

បច្ចយុប្បន្នធម៌ បានដល់ ចិត្ត ៨៥ (វៀរអរូបវិបាក ៤) ចេតសិក៥២ ក្នុងបវត្តិកាលក្នុងបញ្ចវោការភូមិ ។

បច្ចនិកធម៌ បានដល់ ចិត្ត ៤៩ គឺ លោភមូលចិត្ត ៨ មោហមូលចិត្ត ២ មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ មនោទ្វារាវជ្ជនចិត្ត ១ លោកុត្តរចិត្ត ៧ (វៀរសោតាបត្តិមគ្គ) ក្នុងចតុវោការភូមិ បញ្ចវោការបដិសន្ធិចិត្ត ១៥ ចេតសិក ៥២ ។

## វត្ថារម្មណបុរេជាតនិស្សយប្បច្ច័យ

បច្ច័យធម៌ បានដល់ ហទយវត្ថុក្នុងមរណាសន្នកាល ។

បច្ចយុប្បន្នធម៌ បានដល់ ចិត្ត ៤៣ ក្នុងមរណាសន្នវិថី គឺ មនោទ្វារាវជ្ជនចិត្ត ១ ជវនចិត្តប្រាំគ្រាបស់កាមជវន ២៩ តទាលម្ពនៈ ១១ អភិញ្ញាចិត្ត ២ ចេតសិក ៤៤ (វៀរឥស្សា មច្ឆរិយៈ កុក្កុច្ចៈ

វិរតិ ៣ អប្បមញ្ញា ២ ) ។

បច្ចនិកធម៌ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ ក្នុងខណៈដែល
មិនមានហទយវត្ថុជាអារម្មណ៍និងរូប ៧ ពួក ។

**៩-ឧបនិស្សយប្បច្ច័យ** មាន ៣

១-អារម្មណូបនិស្សយប្បច្ច័យ ដូចអារម្មណាធិបតិប្បច្ច័យ

២-អនន្តរូបនិស្សយប្បច្ច័យ ដូចអនន្តរប្បច្ច័យ

៣-បកតូនិស្សយប្បច្ច័យ

**បកតូនិស្សយប្បច្ច័យ**

បច្ច័យធម៌ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ រូប ២៨
ដែលកើតមុន ៗ ដែលមានពលវៈ ( កម្លាំងខ្លាំង )
និងបញ្ញត្តិខ្លះ ។

បច្ចយុប្បន្នធម៌ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ ដែលកើត
ក្រោយ ៗ

បច្ចនិកធម៌ បានដល់ រូប ៧ ពួក ។

## ១០_បុរេជាតប្បច្ច័យ មាន ២

១_អារម្មណបុរេជាតប្បច្ច័យ

២_វត្ថុបុរេជាតប្បច្ច័យ ដូចវត្ថុបុរេជាត_និស្សយប្បច្ច័យ

**អារម្មណបុរេជាតប្បច្ច័យ**

បច្ច័យធម៌ បានដល់ អារម្មណ៍ ៦ គឺ និប្ផន្នរូប ១៨ ដែលជាបច្ចុប្បន្ន ។

បច្ចយុប្បន្នធម៌ បានដល់ កាមចិត្ត៥៤ អភិញ្ញា២ ចេតសិក៥០ (វៀរអប្បមញ្ញា២) ។

បច្ចនិកធម៌ បានដល់ ចិត្ត ៧៦ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣ ខណៈ ដែលមិនមានបច្ចុប្បន្ន និប្ផន្នរូប ១៨ ជាអារម្មណ៍) ។

## ១១_បច្ឆាជាតប្បច្ច័យ

បច្ច័យធម៌ បានដល់ ចិត្ត ៨៥ (វៀរអរូបវិបាក ៤) ចេតសិក ៥២ ដែលកើតខាងក្រោយ មានបឋម

ភវង្គជាដើម ដែលកើតនៅក្នុងបញ្ចវោការភូមិ ។

បច្ចយុប្បន្នធម៌ បានដល់ រូបដែលជាបិតិបត្ត ដែលកើតព្រមជាមួយខណៈទាំង ៣ របស់ចិត្តដែលកើតមុន មានបដិសន្ធិចិត្តជាដើម ។

បច្ចនិកធម៌ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ រូបដែលជាឧប្បាទខណៈ ពាហិររូប និងអសញ្ញសត្តកម្មជរូប ។

**១២_អាសេវនប្បច្ច័យ**

បច្ច័យធម៌ បានដល់ លោកិយជវនចិត្ត ៤៧ ដែលកើតមុន. ( វៀរជវនចុងក្រោយ ) ដែលជាជាតិជាមួយគ្នានឹងចេតសិក ៥២ ។

បច្ចយុប្បន្នធម៌ បានដល់ ជវនចិត្ត ៥១ ដែលកើតក្រោយ ៗ ( វៀរជវនចិត្តទី ១ និងផលជវនចិត្ត ៤ ) ចេតសិក ៥២ ។

បច្ចនិកធម៌ បានដល់ ជវនចិត្តទី ១ របស់កាមជវនចិត្ត ២៩

អាវជ្ជនចិត្ត ២ វិបាកចិត្ត ៣៦ ចេតសិក ៥២ និងរូបទាំង ៧ ពួក ។

**១៣-កម្មប្បច្ច័យ** មាន ២ : ១-សហជាតកម្មប្បច្ច័យ
២-នានក្ខណិកកម្មប្បច្ច័យ

សហជាតកម្មប្បច្ច័យ

បច្ច័យធម៌ បានដល់ ចេតនាចេតសិក ក្នុងចិត្ត ៨៩ ។

បច្ចយុប្បន្នធម៌ បានដល់ ចិត្ត ៨៩ ចេតសិក ៥១ (វៀរចេតនា) ចិត្តជរូប បដិសន្ធិកម្មជរូប ។

បច្ចនិកធម៌ បានដល់ ចេតនាចេតសិក ៨៩ ដែលនៅក្នុងចិត្ត ៨៩ និងរូប ៥ ពួក ដែលនៅសល់ពីបច្ចយុប្បន្នធម៌ ។

នានក្ខណិកកម្មប្បច្ច័យ

បច្ច័យធម៌ បានដល់ ចេតនា ៣៣ គឺ កុសលចេតនា ២១ អកុសលចេតនា ១២ ដែលរលត់ទៅហើយ ។

បច្ចយុប្បន្នធម៌ បានដល់ វិបាកចិត្ត ៣៦ ចេតសិក ៣៨ បដិសន្ធិកម្មជរូប អសញ្ញសត្តកម្មជរូប បវត្តិ-កម្មជរូប ។

បច្ចនិកធម៌ បានដល់ កុសលចេតនា ២១ អកុសលចេតនា ១២ កិរិយាចិត្ត ២០ ចេតសិក ៥២ រូប ៤ ពួក ដែលនៅសល់ពីបច្ចយុប្បន្នធម៌ ។

## ១៤_វិបាកប្បច្ច័យ

បច្ច័យធម៌ បានដល់ វិបាកចិត្ត ៣៦ ចេតសិក ៣៨ ក្នុងបដិសន្ធិកាល និងបវត្តិកាលដែលជួយឧបការៈដល់គ្នានឹងគ្នា និងដែលជួយឧបការៈ ដល់ចិត្តជរូប និងបដិសន្ធិកម្មជរូប ។

បច្ចយុប្បន្នធម៌ បានដល់ វិបាកចិត្ត ៣៦ ចេតសិក ៣៨ ខណៈដែលមិនបានជាបច្ច័យដល់ចិត្តជរូប ១៣ (វៀរវិញ្ញត្តិរូប ២) ដែលកើតពីវិបាកនាមក្ខន្ធទាំងនេះ

តាមសមគួរ និងបដិសន្ធិកម្មជរូប ។

បច្ចនិកធម៌ បានដល់ កុសលចិត្ត ២១ អកុសលចិត្ត ១២ កិរិយាចិត្ត ២០ ចេតសិក ៥២ ចិត្តជរូបដែលកើតពីកុសល អកុសល កិរិយាចិត្ត ដែលជានាមក្ខន្ធទាំងនេះ តាមសមគួរ ពាហិររូប អាហារជរូប ឧតុជរូប អសញ្ញសត្តកម្មជរូប និងបវត្តិកម្មជរូប ។

**១៥_អាហារប្បច្ច័យ** មាន ២ :

១_សហជាតាហារប្បច្ច័យ ឬនាមអាហារប្បច្ច័យ

២_រូបអាហារប្បច្ច័យ

**សហជាតាហារប្បច្ច័យ**

បច្ច័យធម៌ បានដល់ នាមអាហារ ៣ គឺ សផ្សៈ ៨៩ ចេតនា ៨៩ វិញ្ញាណ ៨៩ ។

បច្ចយុប្បន្នធម៌ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ ចិត្តជរូប និង

បដិសន្ធិកម្មជរូប ។

បច្ចនិកធម៌ បានដល់ រូប ៥ ពួក ដែលនៅសល់ ។

បច្ច័យធម៌ បានដល់ ពហិទ្ធឱជាដែលនៅក្នុងអាហារផ្សេង ៗ ឬឱជាដែលនៅខាងក្នុងចតុសមុដ្ឋានិករូប និង ឧតុជឱជាដែលនៅខាងក្រៅ គឺ ឱជាក្នុងអាហារ ផ្សេង ៗ ។

បច្ចយុប្បន្នធម៌ បានដល់ អាហារសមុដ្ឋានិករូប ១២ ឬ ចតុសមុដ្ឋានិករូប ដែលតាំងនៅក្នុងកលាបតែមួយ ជាមួយនឹងបច្ច័យ និងតាំងនៅក្នុងកលាបដទៃ (វៀរឱជាដែលតាំងនៅក្នុងកលាបតែមួយជាមួយ នឹងបច្ច័យ) ។

បច្ចនិកធម៌ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ រូប ៦ ពួក (វៀរអាហាររូប) ឬ ចិត្ត ៨៩ ចេតសិក ៥២ ពាហិររូប ។

**១៦_ឥន្ទ្រិយប្បច្ច័យ** មាន ៣ : ១-សហជាតិន្ទ្រិយប្បច្ច័យ ២-បុរេជាតិន្ទ្រិយប្បច្ច័យ ៣-រូបជីវិតិន្ទ្រិយប្បច្ច័យ

**សហជាតិន្ទ្រិយប្បច្ច័យ**

បច្ច័យធម៌ បានដល់ នាមឥន្ទ្រិយ អង្គធម៌ ៨ គឺ ជីវិតិន្ទ្រិយ ចិត្ត វេទនា សទ្ធា វិរិយ សតិ ឯកគ្គតា និង បញ្ញា ។

បច្ចយុប្បន្នធម៌ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ ចិត្តជរូប បដិសន្ធិកម្មជរូប ។

បច្ចនិកធម៌ បានដល់ រូប ៥ ពួក ដែលនៅសល់ ។

**បុរេជាតិន្ទ្រិយប្បច្ច័យ**

បច្ច័យធម៌ បានដល់ វត្ថុ ៥ (វៀរហទយវត្ថុ) ។

បច្ចយុប្បន្នធម៌ បានដល់ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ សព្វចិត្តសាធារណចេតសិក ៧ ។

បច្ចនិកធម៌ បានដល់ ចិត្ត ៧៩ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០) ចេតសិក ៥២ រូប ៧ ពួក ។

## រូបជីវិតិន្ទ្រិយប្បច្ច័យ

បច្ច័យធម៌ បានដល់ រូបជីវិតិន្ទ្រិយក្នុងបដិសន្ធិកាល និង បវត្តិកាល ។

បច្ចុប្បន្នធម៌ បានដល់ កម្មជរូបដែលនៅសល់ ៨ ឬ ៩ រូប ដែលនៅក្នុងកលាបតែមួយជាមួយបច្ច័យ ។

បច្ចនិកធម៌ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ ចិត្តជរូប ពាហិររូប អាហារជរូប ឧតុជរូប និងរូបជីវិតិន្ទ្រិយ ដែលនៅក្នុងកម្មជកលាបទាំងអស់ ។

## ១៧_ឈានប្បច្ច័យ

បច្ច័យធម៌ បានដល់ អង្គឈាន ៥ គឺ វិតក្កៈ វិចារៈ បីតិ វេទនា និងឯកគ្គតា ដែលនៅក្នុងចិត្តុប្បាទ ៧៩ (វៀរទ្វិបញ្ចវិញ្ញាណ ១០) ។

បច្ចុប្បន្នធម៌ បានដល់ ចិត្តុប្បាទ ៧៩ (វៀរទ្វិបញ្ចវិញ្ញាណ ១០) ចេតសិក ៥២ ចិត្តជរូប និងបដិសន្ធិ-

កម្មជរូប ។

បច្ចនិកធម៌ បានដល់ ទ្វិបញ្ចវិញ្ញាណ ១០ ចេតសិកដែលប្រកប ៧ ពាហិររូប អាហារជរូប ឧតុជរូប អសញ្ញសត្តកម្មជរូប និងបវត្តិកម្មជរូប ។

**១៨_មគ្គប្បច្ច័យ**

បច្ច័យធម៌ បានដល់ អង្គមគ្គ ៩ គឺ បញ្ញា វិតក្កៈ វិចារ វិរតិ ៣ វីរិយៈ សតិ ឯកគ្គតា និងទិដ្ឋិ ដែលនៅក្នុងសហេតុកចិត្ត ៧១ ។

បច្ចយុប្បន្នធម៌ បានដល់ សហេតុកចិត្ត ៧១ ចេតសិក ៥២ សហេតុកចិត្តជរូប សហេតុកបដិសន្ធិកម្មជរូប ។

បច្ចនិកធម៌ បានដល់ អហេតុកចិត្ត ១៨ អញ្ញសមានាចេតសិក ១២ (វៀរឆន្ទៈ) អហេតុកចិត្តជរូប អហេតុកបដិសន្ធិកម្មជរូប ពាហិររូប អាហារជរូប ឧតុជរូប អសញ្ញសត្តកម្មជរូប និងបវត្តិកម្មជរូប ។

## ១៩-សម្បយុត្តប្បច្ច័យ

បច្ច័យធម៌ បានដល់ នាមក្ខន្ធ៤ គឺ ចិត្ត៨៩ ចេតសិក៥២ ។

បច្ចយុប្បន្នធម៌ បានដល់ នាមខន្ធ ៤ គឺ ចិត្ត ៨៩ ចេតសិក ៥២ ។

បច្ចនិកធម៌ បានដល់ រូបទាំង ៧ ពួក ។

## ២០-វិប្បយុត្តប្បច្ច័យ មាន ៤

១- សហជាតវិប្បយុត្តប្បច្ច័យ

២- វត្ថុបុរេជាតវិប្បយុត្តប្បច្ច័យ ដូចគ្នានឹងវត្ថុបុរេជាតនិស្សយប្បច្ច័យ

៣- បច្ឆាជាតវិប្បយុត្តប្បច្ច័យដូចគ្នានឹងបច្ឆាជាតប្បច្ច័យ

៤- វត្ថារម្មណបុរេជាតវិប្បយុត្តប្បច្ច័យ ដូចគ្នានឹងវត្ថារម្មណបុរេជាតនិស្សយប្បច្ច័យ ។

**សហជាតវិប្បយុត្តប្បច្ច័យ**

បច្ច័យធម៌ បានដល់ ចិត្ត ៧៥ ( វៀរទ្វិបញ្ចវិញ្ញាណ ១០ អរូបវិបាក៤ និងចុតិចិត្តរបស់ព្រះអរហន្ត )

ចេតសិក ៥២ ក្នុងបញ្ចវោការភូមិ និងបញ្ចវោការបដិសន្ធិចិត្ត ១៥ ចេតសិក ៣៥ និងបដិសន្ធិហទយវត្ថុ ។

បច្ចយុប្បន្នធម៌ បានដល់ ចិត្តជរូប បដិសន្ធិកម្មជរូប និងបដិសន្ធិហទយវត្ថុ បញ្ចវោការបដិសន្ធិចិត្ត ១៥ ចេតសិក ៣៥ ។

បច្ចនិកធម៌ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ (វៀរបញ្ចវោការបដិសន្ធិនាមក្ខន្ធ ៤) រូប ៥ ពួកដែលនៅសល់ ។

**២១-អត្ថិប្បច្ច័យ** មាន ៥

១-សហជាតត្ថិប្បច្ច័យ ដូចគ្នាសហជាតបច្ច័យ

២-បុរេជាតត្ថិប្បច្ច័យ បែកជាអារម្មណបុរេជាតត្ថិប្បច្ច័យ ដែលដូចគ្នានឹងអារម្មណបុរេជាតបច្ច័យ, និងវត្ថុបុរេជាតត្ថិប្បច្ច័យ ដែលដូចគ្នានឹងវត្ថុបុរេជាតបច្ច័យ,

និងវត្ថារម្មណបុរេជាតត្ថិប្បច្ច័យ ដែលដូចគ្នានឹង វត្ថារម្មណបុរេជាតនិស្សយប្បច្ច័យ ។

៣-បច្ឆាជាតត្ថិប្បច្ច័យ ដូចបច្ឆាជាតប្បច្ច័យ

៤-អាហារត្ថិប្បច្ច័យ ដូចអាហារប្បច្ច័យ

៥-ឥន្ទ្រិយត្ថិប្បច្ច័យ ដូចរូបជីវិតិន្ទ្រិយប្បច្ច័យ

**២២-នត្ថិប្បច្ច័យ** អង្គធម៌ ដូចអនន្តរប្បច្ច័យ

**២៣-វិគតប្បច្ច័យ** បច្ច័យធម៌ និងបច្ចយុប្បន្នធម៌ ដូច នត្ថិប្បច្ច័យនោះឯង ។ ក្នុងវិគតប្បច្ច័យនោះ លោកឧបមាដូចភាព ងងឹត និងពន្លឺ គឺ បើភាពងងឹតបាត់ទៅ ពន្លឺក៏កើតឡើង ។

**២៤-អវិគតប្បច្ច័យ** បច្ច័យធម៌ និងបច្ចយុប្បន្នធម៌ ដូច នត្ថិប្បច្ច័យនោះ ផ្សេងគ្នាតែឈ្មោះប៉ុណ្ណោះ ។ មួយទៀត ព្រះ និព្វានជានិកធម៌របស់បច្ច័យទាំង ២៤ នុ៎ះឯង ។

## អវសានគាថា

ឥច្ចានុរុទ្ធរចិតេ អភិធម្មត្ថសង្គហេ
អដ្ឋមោ បរិច្ឆេទោយំ សមាសេនេវ និដ្ឋិតោ ។

*បរិច្ឆេទទី ៨ នេះ ឈ្មោះថា បច្ចយសង្គហវិភាគ ក្នុងបករណ៍ ដែលរួបរួមអត្ថៈនៃអភិធម្ម ដោយសង្ខេប ដែលព្រះអនុរុទ្ធាចារ្យរចនាទុក ចប់ហើយ ដោយប្រការដូច្នេះ ។*

**បរិច្ឆេទទី ៨ បច្ចយសង្គហវិភាគ ចប់**